ISSN 1560-7607 / ISBN  978-99950-52-05-8

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១០ លេខ ៣ | កក្កដា - កញ្ញា ឆ្នាំ២០០៦ | តម្លៃ ១.៥០០៛

## បញ្ហាប្រឈមនៃកិច្ចរៀបចំការបោះឆ្នោតក្នុងបីខេត្ត នៅភាគខាងលិចប្រទេសកម្ពុជា

**ដួង វីរ័ត្ន ពិភាក្សាវែកញែកពីដំណើរការបោះឆ្នោតក្នុងបីខេត្ត ក្រោយពេលដែលកម្ពុជារៀបចំការបោះឆ្នោតបាន ៥លើក ចាប់តាំងពីឆ្នាំ១៩៩៣មក ។***

ប្រទេសកម្ពុជា បានធ្វើការបោះឆ្នោត ៥ លើកហើយ តាំងពីឆ្នាំ១៩៩៣មក គឺមានការបោះឆ្នោតថ្នាក់ជាតិ ៣លើក ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ១លើក និងការបោះឆ្នោតព្រឹទ្ធសភា ១លើក ។ ការបោះឆ្នោតសំខាន់ខ្លាំងណាស់ សំរាប់ការរីកចំរើនលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ការគោរពសិទ្ធិមនុស្ស និងកំណែលំអអភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មានចីរភាព ។ម្យ៉ាងទៀត ការសិក្សាថ្មីមួយរបស់ វបសអ ព្រមទាំងរបាយការណ៍ផ្សេងៗបានបង្ហាញថា តាំងពីឆ្នាំ១៩៩៨មក ការបោះឆ្នោតនៅកម្ពុជាកាន់តែមានគេទទួលស្គាល់ច្រើនថា មានលក្ខណៈសេរី និងយុត្តិធម៌[1] ។ ពិសេសជាងនេះ ការបោះឆ្នោតគឺកម្ពុជាជាអ្នកដំណើរការ និងគ្រប់គ្រងផ្ទាល់ ដោយមានជំនួយបច្ចេកទេសតិចជាងមុនពីជំនាញការបរទេស ។ ប្រជាជនភាគច្រើនយល់ថា ការបោះឆ្នោតបានអនុវត្តឡើងដោយមានបទពិសោធន៍ច្បាស់លាស់ខាងបច្ចេកទេស ចំណាយតិចក្នុងការរៀបចំ និងក្របខ័ណ្ឌច្បាប់ដែលមានការកែលំអជាបន្តបន្ទាប់ ។



*ខប់សែល បានជួយធ្វើឱ្យការរៀបចំ និងដំណើរការបោះឆ្នោត កាន់តែមានតំលាភាព*

ទោះបីមានការរីកចំរើនដូច្នេះក្តី ក៏នៅមានបញ្ហាចោទជាច្រើន ។ ក្រៅពីចន្លោះប្រហោងផ្សេងៗក្នុងក្របខ័ណ្ឌច្បាប់ ការបោះឆ្នោតតែងជួបការលំបាកនៃអំពើហិង្សាដែលមានទាំងទង្វើពិតៗ និងគ្រាន់តែជាការគំរាមកំហែង ការបំភិតបំភ័យ ការគៃបន្លំ និងរបៀបរបបមិនប្រក្រតី/មិនសមស្របផ្សេងៗ ។ កន្លងមកគណបក្សនយោបាយ ខ្វះវប្បធម៌ទុកចិត្តគ្នាក្នុងការពិភាក្សាពីបញ្ហាបោះឆ្នោត ដែលធ្វើឱ្យកាន់តែមានការខ្វែងមតិ និងទំនាស់ច្រើនថែមទៀត ។ បើចង់ឱ្យរបបប្រជាធិបតេយ្យពហុបក្សនៅកម្ពុជាអនុវត្តបានល្អ ត្រូវមានវេទិកាមួយដែលក្នុងនោះ អ្នកពាក់ព័ន្ធក្នុងការបោះឆ្នោតទាំងអស់ អាចពិភាក្សាពីការខ្វែងមតិ និងធ្វើការងារដើម្បីរកដំណោះស្រាយដោយសន្តិភាព ។

បច្ចុប្បន្ន នៅមានបញ្ហាទាក់ទិននឹងការបោះឆ្នោតជាច្រើន ដែលត្រូវដោះស្រាយ ។ ឧទាហរណ៍ ការទាល់ច្រកខាងនយោបាយរយៈ ១១ខែ ក្រោយពេលបោះឆ្នោតជាតិនៅខែកក្កដា ២០០៣ បានបង្កើនលទ្ធភាពឱ្យមានទំនាស់បោះឆ្នោត ការប្រឈមមុខយ៉ាងជូរចត់ និងការមិនទុកចិត្តគ្នាយ៉ាងជ្រាលជ្រៅនៅក្នុងចំណោមតួអង្គអ្នកនយោបាយនានា ។ ម្យ៉ាងវិញទៀត ថ្វីបើ

### មាតិកា

បញ្ហាប្រឈមនៃកិច្ចរៀបចំការបោះឆ្នោត ....... ១
អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងបញ្ហាប្រឈមនៃរបប "កូនកាត់" ៥
កំណើនសេដ្ឋកិច្ចដ៏រឹងប៉ឹង និងការកែលំអវិធីសាស្ត្ររាយការណ៍ ....... ៩
បណ្ណាល័យ វបសអ និង មណ្ឌលព័ត៌មានបឹងទន្លេសាប ....... ១៣
តាមដានសេដ្ឋកិច្ច— ស្ថានភាពក្រៅប្រទេស ....... ១៥
— ស្ថានភាពក្នុងប្រទេស ....... ១៧
— សន្ទស្សន៍សេដ្ឋកិច្ច ....... ២១
ព័ត៌មានថ្មីៗពី វបសអ ....... ២៤

* ដួង វីរ័ត្ន ជាប្រធានកម្មវិធីសន្តិសុខមនុស្ស ការកសាងសន្តិភាព និងការបំប្លែងទំនាស់នៅ វបសអ ។ អត្ថបទនេះ ផ្អែកលើការសិក្សាមួយរបស់អ្នកនិពន្ធ សំរាប់វគ្គសិក្សាស្តីពីការវិភាគបញ្ហាអភិវឌ្ឍន៍របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ។ អ្នកនិពន្ធសូមអរគុណដល់បណ្ឌិត Brett Ballard នាយកស្រាវជ្រាវស្តីទីនៅ វបសអ លោក គីម សេតារា អ្នកស្រាវជ្រាវនៅ វបសអ លោក ឱក សេរី សោភក្តិ ទីប្រឹក្សានិងអ្នកសំរបសំរួលយន្តការខប់សែល និងក្រុម ADI ចំពោះការជួយមតិ និងព័ត៌មានត្រឡប់ផ្សេងៗលើអត្ថបទ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) បានទទួលការកោតសរសើរចំពោះលទ្ធផលការងារខាងបច្ចេកទេសក្ដី ក៏សាធារណជននៅតែចោទសួរពីឯករាជភាព និងភាពគួរឱ្យទុកចិត្តបានខាងនយោបាយរបស់ស្ថាប័ននេះ ។

ខប់សែល (យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា) គឺជាវេទិកាតុមូលមួយសំរាប់ការពិភាក្សាដោយចំហនិងត្រង់ទៅត្រង់មក លើបញ្ហាផ្សេងៗទាក់ទិននឹងការបោះឆ្នោត ។ យន្តការបានផ្ដល់ជាវេទិកាអព្យាក្រិត និងមានសុវត្ថិភាព សំរាប់ការពិភាក្សាទល់មុខគ្នារវាងអ្នកតំណាងនានារបស់គណបក្សនយោបាយ រដ្ឋាភិបាល និងសង្គមស៊ីវិល អំពីបញ្ហាបោះឆ្នោត[2] ។ នៅកំរិតជាតិ ខប់សែល ធ្វើការប្រជុំប្រចាំខែ ដែលមានការងាររៀបចំយ៉ាងច្រើនៈ ការរកមើលបញ្ហាត្រូវពិភាក្សា ការស្វែងរកចំនុចឯកភាពគ្នា ការកសាងជំនួយគាំទ្រ ការមូលមតិ ការតាមដានជាបន្ត និង ការពិភាក្សានៅក្រោយឆាក ។ គេមើលឃើញយន្តការនេះថា ជារចនាសម្ព័ន្ធមានចីរភាពល្អ សំរាប់ការកសាងទំនុកចិត្តតាមរយៈការពិភាក្សាដោយចំហ មានសុវត្ថិភាព និងក្នុងបរិយាកាសអព្យាក្រិត ។ ពីខែសីហា ១៩៩៩ ដល់ ការបោះឆ្នោតឆ្នាំ ២០០៣ ខប់សែល បានរៀបចំការប្រជុំ ៥០លើក ដោយមានអ្នកចូលរួមជាង ១០០នាក់ ដូចជា តំណាងសំខាន់ៗមកពីគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលឃ្លាំមើលការបោះឆ្នោត គជប ស្ថាប័នរក្សាសន្តិសុខ អង្គការនារី និងក្រសួងមហាផ្ទៃ ។ កំនត់ហេតុនៃការប្រជុំនីមួយៗ ក្រោយបានទទួលការឯកភាពពីអ្នកចូលរួមហើយ ត្រូវបានផ្ញើថ្វាយព្រះមហាក្សត្រ ផ្ញើជូនសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ គជប នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទាំងអស់ដែលពាក់ព័ន្ធនឹងការបោះឆ្នោត អភិបាលនិងអភិបាលរងខេត្ត-ក្រុង ស្ថានទូតបរទេសប្រហែល ២៥ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិលផ្សេងៗ ។

សំរាប់ការបោះឆ្នោតកំរិតជាតិនៅខែកក្កដា ២០០៣ ខប់សែល បានជួយឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ក្នុងគោលនយោបាយ និងដំណើរការបោះឆ្នោត តាមរយៈការពិភាក្សាលើប្រធានបទដូចជា ការពន្យារយៈពេលចុះបញ្ជីអ្នកបោះឆ្នោត នីតិវិធីមានតំលាភាព លទ្ធភាពស្មើភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ កំណែលំអការអប់រំអ្នកបោះឆ្នោត ការរៀបចំនិងពង្រឹងសន្តិសុខ នីតិវិធីនិងការជ្រើសរើសគណៈកម្មការមានតំលាភាព ។ល។ ដោយមូលហេតុនេះ នៅកម្ពុជា (និងក្នុងតំបន់នេះ) មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ខប់សែល គឺជាយន្តការសំរាប់បង្ការនិងគ្រប់គ្រងទំនាស់ និងជាវេទិកាមួយមានសុវត្ថិភាព និងអព្យាក្រឹតសំរាប់លើកកំពស់វប្បធម៌ពិភាក្សាគ្នា និងកសាងទំនុកចិត្តគ្នាទៅវិញទៅមក ។ គជប និង NGOs មួយចំនួនបានយកគំរូយន្តការនេះ ទៅដាក់បញ្ចូលក្នុងកម្មវិធីរបស់ខ្លួន ដើម្បីធ្វើការពិភាក្សាពីបញ្ហាដ៏ជាក់លាក់នានា ។

ដើម្បីបំរើដល់ការបោះឆ្នោតព្រឹទ្ធសភា ២០០៦ ការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ២០០៧ និងការបោះឆ្នោតកំរិតជាតិឆ្នាំ២០០៨ វបសអ បានចាប់ដំណើរការ ខប់សែលដំណាក់កាលទី២ តាមរយៈសន្និសីទមួយនៅខែកក្កដា ២០០៥ ដើម្បីផ្ដល់វេទិកាបើកចំហនិងអព្យាក្រឹត សំរាប់ការពិភាក្សាដោយមានសុវត្ថិភាពអំពីបញ្ហាបោះឆ្នោត ។ គោលដៅចំបងគឺ ការទប់ស្កាត់ទំនាស់អំពើហិង្សា និងការយល់ច្រឡំផ្សេងៗ ដែលផុសឡើងនៅមុននិងក្នុងពេលបោះឆ្នោត តាមរយៈការកសាងទំនុកចិត្ត និងការជំរុញវប្បធម៌ពិភាក្សាគ្នា ដែលមានសារៈសំខាន់ជាមូលដ្ឋានដើម្បីកសាងសន្តិភាព និងរបបប្រជាធិបតេយ្យដែលចាស់ចិត្តចាស់គំនិតល្អ ។ ខប់សែលដំណាក់កាលទី២ នឹងមានដំណើរការ ៣ឆ្នាំ ដោយមានជំនួយហិរញ្ញវត្ថុពី UNDP ។

ការប្រជុំខប់សែលថ្នាក់ខេត្ត (COPCELPROM) មានទិសដៅចុះធ្វើការដល់ថ្នាក់ខេត្តដើម្បីបង្កើនការចូលរួមរបស់សាធារណជន ។ ការប្រជុំខប់សែលប្រព័ន្ធផ្សព្វផ្សាយ (COPCELMED) មានទិសដៅជំរុញឱ្យមានការចូលរួមយ៉ាងច្រើនរបស់ប្រជាជនក្នុងការបោះឆ្នោត ។ តាំងពីពេលចាប់ដំណើរការមក ខប់សែលដំណាក់កាលទី២ បានរកឃើញបញ្ហាបោះឆ្នោតផ្សេងៗតែនៅកំរិតជាតិប៉ុណ្ណោះ ។ រីឯបញ្ហាប្រឈមនៅកំរិតខេត្ត គឺមិនទាន់រកឃើញទេ ហើយត្រូវតែរកឱ្យឃើញ និងដោះស្រាយឱ្យបានតាមរយៈការពិភាក្សាគ្នា ។

## វិធីសាស្ត្រស្រាវជ្រាវ

អត្ថបទនេះ ផុសចេញពីការចុះសិក្សាតូចមួយដល់មូលដ្ឋាន កាលពីថ្ងៃទី ១២-១៤ កក្កដា ២០០៦ ដោយប្រើប្រាស់សំនួរមានការណែនាំមួយចំនួន លើអ្នកផ្ដល់ព័ត៌មាន ៣០នាក់ នៅខេត្តបាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង នៅភាគខាងលិចប្រទេសកម្ពុជា ។ នៅតាមខេត្តនីមួយៗ អ្នកផ្ដល់ព័ត៌មាន គឺមានអភិបាល រឺអភិបាលរងខេត្ត ស្នងការ រឺស្នងការរងនគរបាលខេត្ត ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត ក្រុមការងារខេត្តរបស់គណបក្សប្រជាជន (CPP) ហ៊្វុនស៊ិនប៉ិច (FUNCINPEC) និង សម រង្ស៊ី (SRP) ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត (PLAU) តំណាងថ្នាក់ខេត្តរបស់អង្គការ ADHOC, COMFREL និង NICFEC ។ ការសិក្សាប្រឹងប្រែងស្វែងរកបញ្ហាបោះឆ្នោតចំបងៗ នៅតាមខេត្តដែលអាចយកមកធ្វើជាមូលដ្ឋានសំរាប់ការពិភាក្សា និងរកដំណោះស្រាយនៅក្នុងការប្រជុំខប់សែលថ្នាក់ខេត្ត ។ ការស្រាវជ្រាវ បានពិនិត្យពីចរិតនៃដំណើរការបោះឆ្នោត និងទំនាស់បោះឆ្នោតនៅក្នុងខេត្តទាំង ៣ ដោយផ្ដោតការយកចិត្តទុកដាក់លើការចុះឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងដំណើរការនៅថ្ងៃបោះឆ្នោត ។

## ការចុះឈ្មោះអ្នកបោះឆ្នោត

ច្បាប់ស្តីពីការបោះឆ្នោតឃុំ-សង្កាត់ បានផ្ទេរការចុះឈ្មោះបោះឆ្នោតទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលក្នុងនាម គជប ត្រូវពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតឡើងវិញ ចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតសំរាប់ឃុំ-សង្កាត់នីមួយៗ ។ ដើម្បីបំពេញមុខងារនេះ ក្រុមប្រឹក្សាឃុំគួរប្រគល់វាទៅឱ្យស្មៀនឃុំ ដែលដើរតួនាទីជាមន្ត្រីពិនិត្យឡើងវិញនូវបញ្ជីឈ្មោះអ្នកបោះឆ្នោត និងជាអ្នកកាន់កាប់បញ្ជីនេះ ។ ក្រុមប្រឹក្សាឃុំត្រូវបញ្ជាអោយស្មៀនឃុំបំពេញការងារនេះឱ្យបានត្រឹមត្រូវ ទៅតាមច្បាប់បោះឆ្នោត ព្រមទាំងបទប្បញ្ញត្តិ និងនីតិវិធីកំនត់ដោយ គជប[3] ។ ច្បាប់ចែងថា បញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ចាប់ពីខែតុលា ដល់ខែធ្នូនៃឆ្នាំនីមួយៗ ។ បញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវចំលងជូន គជប ដែលមានភារកិច្ចផ្ដល់សុពលភាពដល់បញ្ជីនេះឱ្យបានយ៉ាងតិច ៩០ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

យោងតាមខ្លឹមសារច្បាប់ ស្មៀនឃុំទទួលបន្ទុកចុះបញ្ជីអ្នកបោះឆ្នោត ដោយមានការត្រួតពិនិត្យពីសមាជិកក្រុមប្រឹក្សាឃុំ ហើយបញ្ជីឈ្មោះអ្នកបោះឆ្នោតក៏មានការកែលំអយ៉ាងច្រើន[4] ។ បញ្ជីមានលក្ខណៈកាន់តែត្រឹមត្រូវថែមទៀត តាមរយៈការលុបឈ្មោះអ្នកស្លាប់ និងអ្នកផ្លាស់ទីលំនៅចេញពីឃុំ ។

ជាគោលការណ៍ ការប្រគល់អំណាចទៅឱ្យអាជ្ញាធរឃុំកាន់កាប់បញ្ជីឈ្មោះអ្នកបោះឆ្នោត អាចជាវិធានការសមស្រប ពីព្រោះបានដាក់ថ្នាក់រដ្ឋបាល ដែល

សមស្របជាងគេឱ្យទទួលខុសត្រូវលើការងារនេះ[៥] ជាពិសេសនៅពេលដែលរដ្ឋាភិបាលកំពុងអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ[៦] ។

ការបែងចែកភារកិច្ចទៅឱ្យក៏រិតឃុំ ក៏អាចជួបគ្រោះថ្នាក់ដែរ ពីព្រោះក្រុមប្រឹក្សាឃុំទើបតែបង្កើតបានប្រហែលមួយឆ្នាំប៉ុណ្ណោះ នៅពេលដែលត្រូវបំពេញភារកិច្ចធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០០២ ។ នៅក្នុងការសិក្សាដំបូងៗអំពីដំណើរការក្រុមប្រឹក្សាឃុំ មានការទទួលស្គាល់ជាទូទៅថា ក្រុមប្រឹក្សាឃុំមិនទាន់យល់ច្បាស់ល្អពីនីតិវិធី និងទិសដៅផ្ទាល់របស់ខ្លួនទេ ហើយក៏មិនទាន់ទទួលបានឋវិកាសំរាប់បង្កើតប្រព័ន្ធផ្សេងៗដើម្បីជួយទ្រទ្រង់ដល់ភារកិច្ចរបស់ខ្លួនដែរ ។ ម្យ៉ាងទៀត ទំនាក់ទំនងរបស់ក្រុមប្រឹក្សាជាមួយប្រធាន និងស្មៀនរបស់ខ្លួន ព្រមទាំងទំនាក់ទំនងរវាងសមាជិកក្រុមប្រឹក្សាមកពី CPP និង SRP នៅទន់ខ្សោយនៅឡើយ ដោយខាង SRP មានអារម្មណ៍ថា ពួកខ្លួនត្រូវគេផាត់ចេញពីការធ្វើសេចក្ដីសំរេចចិត្តផ្សេងៗ ។ ដោយមូលហេតុនេះ ទើបការធ្វើប្រតិភូកម្មសិទ្ធិអំណាចចុះឈ្មោះអ្នកបោះឆ្នោតទៅឱ្យថ្នាក់ឃុំ គឺជាការផ្ទេរការងារទៅអោយស្ថាប័នមួយដែលមានការរៀបចំ និង ការសំរបសំរួលនៅទន់ខ្សោយនៅឡើយ[៧] ។

ការសិក្សាក្នុង ៣ ខេត្តនៅភាគខាងលិច បានបង្ហាញដែរថា មានកំហិត និងការលំបាកមួយចំនួននៅក្នុងរយៈពេលចុះឈ្មោះបោះឆ្នោត ដោយសារភារកិច្ចផ្សេងៗដ៏មមាញឹកដែលថ្នាក់លើនៅក្រសួងមហាផ្ទៃ (MOI) បានដាក់ចុះឱ្យស្មៀនឃុំ បានរាំងរាំងពួកគេក្នុងការចុះឈ្មោះអ្នកបោះឆ្នោតឱ្យបានសកម្មល្អនៅក្នុងរយៈពេលចុះឈ្មោះត្រៀម ៩ខែ និងក្នុងរយៈពេល ២០ថ្ងៃនៃការចុះឈ្មោះបោះឆ្នោតជាផ្លូវការ ហើយស្មៀនឃុំបានយកលេសនេះទៅបំពេញភារកិច្ចផ្សេងៗទៀតវិញ ។ រឿងនេះជួនកាលធ្វើឱ្យប្រជាជនត្រូវរង់ចាំ ពីព្រោះនៅពេលមកចុះឈ្មោះបោះឆ្នោត គាត់រកស្មៀនឃុំមិនឃើញ ហើយក៏គ្មានព័ត៌មានអ្វីសោះ ។ ក្នុងពេលជាមួយគ្នា ក៏មានការងារជាច្រើន មកពីខាងសិលា និង NGOs ព្រមទាំងការធ្វើផែនការប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃថែមទៀត ដែលកាន់តែធ្វើឱ្យយឺតយ៉ាវដល់សមាជិកក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ។

ស្មៀនឃុំនៅថ្មោងថ្មីនៅឡើយ ក្នុងរឿងនីតិវិធីចុះឈ្មោះអ្នកបោះឆ្នោត ដែលនាំឱ្យមានកំហុស និងការតវ៉ាជាច្រើនពីតំណាងគណបក្សនានា និង NGOs ។ យោងតាមបទសំភាសន៍ បញ្ហាភាគច្រើនទាក់ទិននឹងកំហុសក្នុងការសរសេរឈ្មោះ ថ្ងៃខែឆ្នាំ និងកន្លែងកំណើត ដោយសារការធ្វេសប្រហែសរបស់ស្មៀនឃុំ សមាជិកក្រុមប្រឹក្សាឃុំ រឺសាមីខ្លួនអ្នកបោះឆ្នោត ។

គេបានផ្ដល់មតិថា ត្រូវមានការចូលរួមច្រើនថែមទៀត ក្នុងការលើកទឹកចិត្តប្រជាជនឱ្យបោះឆ្នោត ។ គណបក្សនយោបាយ NGOs និងអាជ្ញាធរមូលដ្ឋាន ជាពិសេសមេភូមិដែលទើបជ្រើសតាំងថ្មី គួរបំផុសប្រជាជនឱ្យយល់ពីសារៈសំខាន់នៃការបោះឆ្នោត ជាពិសេសការធានាឱ្យមានសិទ្ធិបោះឆ្នោតតាមរយៈការចុះឈ្មោះបោះឆ្នោត ។ អ្នកឆ្លើយសំភាសន៍ និងអ្នកចូលរួមក្នុងការប្រជុំខប់សែល បាននិយាយថា គ្រប់ៗគ្នាគួរធ្វើការឱ្យជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) គណៈកម្មការខេត្តរៀបចំការបោះឆ្នោត (គខប) និង គណៈកម្មការឃុំរៀបចំការបោះឆ្នោត (គឃប) ក្នុងការជៀសវាងការយល់ខុស ជាពិសេសទាក់ទិននឹងខ្លឹមសារនៃឯកសារអប់រំ ។

ប័ណ្ណបោះឆ្នោតពុំមានឱ្យប្រើទៀតទេ ក្នុងការបោះឆ្នោតលើកក្រោយ ដោយត្រូវប្រើអត្តសញ្ញាណប័ណ្ណផ្លូវការជាតិជំនួសវិញ[៨] ។ បើសិនអ្នកបោះឆ្នោតគ្មានអត្តសញ្ញាណប័ណ្ណនេះទេ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ អត្តសញ្ញាណប័ណ្ណកងទ័ព រឺនគរបាល ក៏អាចប្រើប្រាស់ដើម្បីបោះឆ្នោតបានដែរ ។ ដំណោះស្រាយចុងក្រោយគឺ ទំរង់១០១៨[៩] មានបិទរូបថត ដែលចេញដោយមេឃុំ អាចយកទៅប្រើដើម្បីបោះឆ្នោតបាន ។ ការផ្លាស់ប្ដូរទៅប្រើអត្តសញ្ញាណប័ណ្ណវិញនេះ បានទទួលការលើកសរសើរពីអ្នកនយោបាយ និងស្ថាប័នជាច្រើន ពីព្រោះធ្វើដូច្នេះ ប្រជាជននឹងមានប័ណ្ណមួយ ដែលអាចប្រើការបានច្រើនយ៉ាង ហើយ គជប ក៏មិនចាំបាច់ចេញប័ណ្ណបោះឆ្នោតដែរ ។ ប៉ុន្តែ អ្នកនយោបាយខ្លះបានលើកពីការបារម្ភ ពីព្រោះអ្នកមានសិទ្ធិបោះឆ្នោតជាច្រើននាក់ពុំទាន់មានអត្តសញ្ញាណប័ណ្ណទេ ហើយដំណើរការចេញអត្តសញ្ញាណប័ណ្ណឱ្យប្រើប្រាស់វាយឺតយ៉ាវ និងមានអំពើពុករលួយផងក្នុងជួរនគរបាល[១០] ។ ក្នុងករណីខ្លះ អត្តសញ្ញាណប័ណ្ណអាចជាមធ្យោបាយមួយទៀតសំរាប់បំភិតបំភ័យសកម្មជនគណបក្ស ដោយគេមិនចេញអត្តសញ្ញាណប័ណ្ណឱ្យអ្នកណាដែលគាំទ្រគណបក្សផ្សេងពីគណបក្សដែលគាំទ្រដោយអាជ្ញាធរមូលដ្ឋាន ជាពិសេសក្រុម រឺថ្នាក់ដឹកនាំភូមិ ។

## ថ្ងៃឃោសនាបោះឆ្នោត

មេភូមិដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្សព្វផ្សាយព័ត៌មានបោះឆ្នោត ។ ប៉ុន្តែក៏មានការចោទប្រកាន់មេភូមិថា បានទិញសន្លឹកឆ្នោត ធ្វើការបំភិតបំភ័យដកហូតប័ណ្ណបោះឆ្នោត ធ្វើអំពើខុសច្បាប់ និងការគំរាមកំហែងជាច្រើនទៀតក្នុងរយៈពេលនៃការបោះឆ្នោត[១១] ។ ករណីបំភិតបំភ័យ ធ្វើឡើងដោយពួកមេឃុំ ដែលគាំទ្រគណបក្ស CPP មានគេលើកឡើងក្នុងខេត្តទាំង៣ នៃការសិក្សានេះ ហើយរូបភាពជាទូទៅ គឺមានការគំរាមកំហែងដល់សកម្មជននានាថានឹងរឹបអូសយកដី/ទ្រព្យសម្បត្តិ រឺធ្វើការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកដែលគាំទ្រគណបក្សមួយផ្សេង ។ គេរាយការណ៍ថា នៅ "រាត្រីឆ្កែព្រុស" (គឺយប់មុនពេលបោះឆ្នោត ដែលតាមច្បាប់មិនត្រូវធ្វើការឃោសនាទេ) ពួកមេភូមិ រឺក្រុមអ្នកដឹកនាំផ្សេងទៀត បានដើរចុះឡើង ដើម្បីផ្ដល់អំណោយ និងបញ្ចុះបញ្ចូលអ្នកបោះឆ្នោត ឱ្យគាំទ្រគណបក្សខ្លួន ។ ថ្វីបើតំណាងគណបក្សនៅតាមខេត្តបានលើកគ្រប់គ្នាពីរឿងនេះក្ដី ប៉ុន្តែពុំមានគណបក្សណាមួយបានដាក់ពាក្យបណ្ដឹងតវ៉ាជាផ្លូវការ ទៅជូនគណៈកម្មការខេត្តរៀបចំការបោះឆ្នោតទេ ។

## កិច្ចដំណើរការនៅថ្ងៃបោះឆ្នោត

នៅខេត្តទាំង ៣ មានគេរាយការណ៍យ៉ាងច្រើនពីករណីអ្នកបោះឆ្នោត ដែលរកមិនឃើញការិយាល័យបោះឆ្នោតរបស់ខ្លួននៅថ្ងៃបោះឆ្នោត ។ យោងតាមនីតិវិធី បើសិនចំនួនអ្នកបោះឆ្នោតកើនលើស ៧០០នាក់ នៅការិយាល័យបោះឆ្នោតណាមួយ ចំនួនលើសត្រូវផ្ទេរទៅការិយាល័យមួយផ្សេង ដើម្បីសំរាលការកកស្ទះ ។ ការផ្លាស់ប្ដូរការិយាល័យបោះឆ្នោតបានធ្វើឱ្យអ្នកបោះឆ្នោតជាច្រើនច្រឡំបល់អស់ ពីព្រោះពួកគេតែងគិតថាបើចុះឈ្មោះនៅកន្លែងណា ត្រូវបោះឆ្នោតនៅកន្លែងនោះ ប៉ុន្តែទៅរកឈ្មោះមិនឃើញ ដូច្នេះហើយជួនកាលក៏លែងទៅបោះឆ្នោតតែម្ដង ។ កំហុសក្នុងការសរសេរឈ្មោះ និងថ្ងៃខែឆ្នាំ ទីកន្លែងកំណើត ក៏មានញឹកញាប់ដែរក្នុងខេត្តទាំង ៣ ហើយប្រជាជន ក៏ត្រូវខកខានមិនបានបោះឆ្នោត ។ គណបក្សនយោបាយជាច្រើនបានប្ដឹងតវ៉ាពីរឿងនេះ ដោយចោទថា វាមានគោលដៅរារាំងអ្នកគាំទ្ររបស់ពួកគេមិនឱ្យបោះឆ្នោតកើត ។

វត្តមានអាជ្ញាធរមូលដ្ឋាននៅខាងមុខការិយាល័យបោះឆ្នោត ក៏ត្រូវគេរាយការណ៍ថា បានជះឥទ្ធិពលមកលើអ្នកបោះឆ្នោត ជាពិសេសអ្នកដែលមិន

**សង្ខេបដំណើរការបោះឆ្នោត**

| ការចុះឈ្មោះអ្នកបោះឆ្នោត ត្រៀមរយៈពេល ៩ខែ | រយៈពេលចុះឈ្មោះបោះឆ្នោត ២០ថ្ងៃ | ការឃោសនាបោះឆ្នោត | ថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត |
|---|---|---|---|
| ផ្ទេរការងារទៅឱ្យក្រុមប្រឹក្សាឃុំ និង ស្មៀនឃុំ ។ មានការកែលំអជាបន្តបន្ទាប់ ។ | ស្មៀនឃុំ អ្នកបោះឆ្នោត និងគជប ត្រូវគិតគូរឱ្យកាន់តែច្រើនលើភាពត្រឹមត្រូវខាងបច្ចេកទេស ជាពិសេស ពាក់ព័ន្ធនឹងបញ្ហាអក្ខរាវិរុទ្ធ និងការចុះថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត ។ | ទំនាស់ភាគច្រើនកើតឡើង ដោយសារសកម្មជនគណបក្សមិនគោរពតាមកាលវិភាគដែលបានព្រមព្រៀង និងរំលោភលើក្រមសីលធម៌បោះឆ្នោត ។ រាត្រីឆ្កែព្រុស គេរាយការណ៍ថា ជារឿង ធម្មតានៅខេត្តបាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង ។ | វត្តមានមេភូមិ មេឃុំ និង អភិបាលស្រុក នៅកន្លែងបោះឆ្នោតនៅតែជាបញ្ហាបារម្ភដ៏ធំមួយ ។ |

គាំទ្រគណបក្ស CPP ។ មេភូមិ មេឃុំ រឺអភិបាលស្រុក បានឈរវង់ចាំនៅការិយាល័យបោះឆ្នោត ទោះបីពួកគេបានបោះឆ្នោតរួចក្ដី ក្នុងរូបភាពមួយដើម្បីបំភិតបំភ័យដល់គណបក្សនយោបាយឯទៀត ។ គណបក្សទាំងនេះបានប្ដឹងតវ៉ា ហើយ NGOs ដែលឃ្លាំមើលការបោះឆ្នោត ក៏កត់ត្រាពីរឿងនេះដែរ[១២] ។

## សេចក្ដីសន្និដ្ឋាន

ការវាយតំលៃខ្នាតតូចនេះ បានបង្ហាញពីកំណែលំអក្នុងការបោះឆ្នោតនៅខេត្តបាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង ។ ស្មៀនឃុំ ដែលទទួលបន្ទុកធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះបញ្ជីអ្នកបោះឆ្នោត គេយល់ដឹងកាន់តែច្រើនពីនីតិវិធីចុះបញ្ជីអ្នកបោះឆ្នោត និងយកចិត្តទុកដាក់ខ្លាំងជាងមុនអំពីដំណើរការបោះឆ្នោត ។ ចំនួនអ្នកមកចុះឈ្មោះបោះឆ្នោត កើនឡើងគួរឱ្យកត់សំគាល់ក្នុងឃុំភាគច្រើន ។ បញ្ហាសន្តិសុខ ក៏មានការកែលំអ ឆ្លងតាមកិច្ចសហប្រតិបត្តិការដ៏ល្អ រវាងមន្ត្រី គខប អាជ្ញាធរខេត្ត និងកងទ័ព ។ ការបំភិតបំភ័យ រឺអំពើហិង្សាលើសកម្មជនគណបក្សនយោបាយ ក៏ថយចុះដែរយោងតាមរបាយការណ៍ទទួលបាន ។

ចំពោះបញ្ហាចោទវិញ បច្ចុប្បន្ននៅមានមួយចំនួនមិនទាន់ដោះស្រាយទេ ។ ដោយឡែក ការងារដ៏ច្រើនដែលប្រគល់ទៅឱ្យស្មៀនឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងអំឡុងពេលចុះបញ្ជីអ្នកបោះឆ្នោត បានធ្វើឱ្យយឺតយ៉ាវដល់ការចុះបញ្ជី និងបង្កការលំបាកដល់អ្នកបោះឆ្នោត និងស្មៀនឃុំ ។ គេបានលើកមតិថា ក្នុងរយៈ ២០ថ្ងៃ (០១-២០ តុលា) នៃការចុះបញ្ជីអ្នកបោះឆ្នោតជាផ្លូវការ គួរជៀសវាងលើកគំរោងធ្វើការងារឃុំអ្វីផ្សេងទៀត ដើម្បីទុកពេលឱ្យសមាជិកក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ផ្ដោតកំលាំងលើការចុះបញ្ជីអ្នកបោះឆ្នោត ។ ក្នុងថ្ងៃមិនឱ្យឃោសនា នៅខេត្តទាំង៣ មានគេរាយការណ៍ជាទូទៅពី "រាត្រីឆ្កែព្រុស" ដែលបង្ហាញថា គណបក្សនយោបាយនានា នៅតែព្យាយាមចែកអំណោយឱ្យអ្នកគាំទ្រដដែល ។

វត្តមានមេភូមិ និងមេឃុំនៅតាមការិយាល័យបោះឆ្នោត ក្រោយពេលពួកគាត់បានបោះឆ្នោតហើយ នៅតែជាចំនុចបារម្ភមួយសំរាប់គណបក្សនយោបាយ និង NGOs អន្តរជាតិ ពីព្រោះវាអាចជាការបំភិតបំភ័យដល់អ្នកបោះឆ្នោត ។ ដើម្បីដោះស្រាយរឿងនេះ ត្រូវមានកិច្ចសហប្រតិបត្តិការរវាងគណបក្សនយោបាយនានា ដើម្បីកុំឱ្យដំណើរការបោះឆ្នោតមានរូបភាពមិនល្អ ។ ចំពោះនីតិវិធីបច្ចេកទេស និងការចុះបញ្ជីអ្នកបោះឆ្នោត ត្រូវតែយកចិត្តទុកដាក់ច្រើនថែមទៀត ជាពិសេសអក្ខរាវិរុទ្ធ ថ្ងៃខែឆ្នាំ និង ទីកន្លែងកំណើត ត្រូវតែត្រឹមត្រូវច្បាស់លាស់ ។ ក្នុងករណីត្រូវផ្លាស់ប្ដូរការិយាល័យបោះឆ្នោតត្រូវផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ ដើម្បីជៀសវាងការរអាក់រអួល នៅថ្ងៃបោះឆ្នោត ។

## កំណត់សំគាល់

១. C. Hughes and Kim S. (2004), *The Evolution of Democratic Process and Conflict Management in Cambodia,* CDRI, and UNDP (March 2002), *Report on the Election of the Commune Council.* Speech by SAR Kheng, deputy prime minister and minister of the interior, speech by IM Suosdey, chairperson of the National Election Committee, speech by Douglas Gardner, UNDP representative and UN resident coordinator, all at the Meeting on Calling for Funding for 2007 Commune Election, Cambodiana Hotel, 8 June 2006.

២. ការសិក្សារបស់ វិបសអ ស្ដីពីចរិត និងមូលហេតុនៃទំនាស់ក្នុងការបោះឆ្នោត ឆ្នាំ១៩៩៨ បានលើកអនុសាសន៍ឱ្យបង្កើតខប់សែលឡើង ។ ចំពោះព័ត៌មានបន្ថែមស្ដីពីរចនាសម្ព័ន្ធ និងសកម្មភាពខប់សែល សូមមើលក្នុងវេបសាយរបស់ វិបសអ: www.cdri.org.kh

៣. ច្បាប់បោះឆ្នោតតំណាងរាស្ត្រ អនុម័តឆ្នាំ២០០២ (ជំពូក៦ មាត្រា៥៣)

៤. របាយការណ៍ដោយ ទេព នីថា អគ្គលេខាធិការ គជប ក្នុងការប្រជុំខប់សែលប្រចាំខែនៅភ្នំពេញ (សូមមើលកំណត់ហេតុខប់សែលដាក់លើ www.cdri.org.kh) ហើយនិងបទសំភាសន៍នានាសំរាប់ការសិក្សានេះ ។

៥. C. Hughes and Kim S. (2004), *The Evolution of Democratic Process and Conflict Management in Cambodia* (Phnom Penh: CDRI), p. 57.

៦. សុន្ទរកថាដោយ អ៊ឹម សួស្ដី, *op. cit.*

៧. C. Hughes and Kim S. *op. cit.,* p. 58,

៨. របាយការណ៍ដោយ ទេព នីថា ក្នុងការប្រជុំខប់សែលនៅភ្នំពេញ ។ សូមមើលកំណត់ហេតុប្រជុំខប់សែល មានដាក់ក្នុងវេបសាយរបស់ វិបសអ : www.cdri.org.kh

៩. ទំរង់ចេញឱ្យដោយមេឃុំនេះសំរាប់បញ្ជាក់ថា អ្នកកាន់ឯកសារជានិវាសនជន នៅក្នុងឃុំ និងមានសិទ្ធិបោះឆ្នោត បើសិនគាត់គ្មានឯកសារផ្លូវការអ្វីផ្សេងសំរាប់បញ្ជាក់ ។

១០. បទសំភាសន៍សំរាប់ការសិក្សានេះ ។

១១. C. Hughes and Kim S. *op. cit.*

១២. C. Hughes and Kim *S. op. cit.,* and interviews for this study.

# អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងបញ្ហាប្រឈមនៃរបប "កូនកាត់"

*Caroline Hughes, Joakim Öjendal និង ប៉ក់ គីមជឿន ពិភាក្សាពីការវិវត្តន៍ទស្សនៈនៃប្រជាធិបតេយ្យភាវូបនីយកម្ម និងគោលគំនិតនៃរបបកូនកាត់ នៅក្នុងប្រព័ន្ធអភិបាលកិច្ច ។**

អត្ថបទនេះបង្ហាញពីគោលគំនិតនៃរបបកូនកាត់ (hybridity) ដែលសំដៅដល់របបអភិបាលកិច្ចមួយមានគួបផ្សំគ្នានូវ សមាសធាតុផ្សេងៗនៃរបបផ្តាច់ការ និងរបបប្រជាធិបតេយ្យ (Karl 1995) ។ អត្ថបទចាប់ផ្តើមបង្ហាញពីការវិវត្តន៍គោលគំនិតស្តីពីប្រជាធិបតេយ្យភាវូបនីយកម្ម បន្ទាប់មកគឺ ប្រព័ន្ធអភិបាលកិច្ចបែបកូនកាត់ដែលមានវែកញែកពិភាក្សាក្នុងឯកសារផ្សេងៗ ។ បន្ទាប់មកទៀត អត្ថបទពិចារណាថា តើរបបកូនកាត់នេះអាចដាក់អនុវត្តយ៉ាងណាបានក្នុងបរិបទអភិបាលកិច្ចនៅកម្ពុជា ជាពិសេសក្នុងកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលទើបដំណើរការនេះ ដើម្បីយកធ្វើជាក្របខ័ណ្ឌនៃការស្រាវជ្រាវបែបវិភាគរបស់ផ្នែកអភិបាលកិច្ច និងវិមជ្ឈការនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) សំរាប់ដំណាក់កាលថ្មីនៃកម្មវិធីពីឆ្នាំ២០០៧ ដល់ ២០១០ ។

## រលកទី៣

នៅចុងទសវត្សរ៍១៩៨០ និងដើមទសវត្សរ៍១៩៩០ គេនិយាយថា មានរលកទី៣នៃប្រជាធិបតេយ្យភាវូបនីយកម្ម បានបោកបក់លើពិភពលោក (Huntington 1991) ។ បណ្តាប្រទេសនៅអឺរ៉ុបខាងត្បូង អាមេរិកឡាទីន អឺរ៉ុបខាងកើត អាហ្វ្រិក និងអាស៊ី បានចាប់ផ្តើមទទួលយកប្រព័ន្ធពហុបក្សតាមបែបណាមួយ ។ ក្នុងរលកនេះ ការរីកសាយលទ្ធិប្រជាធិបតេយ្យមានលក្ខណៈពិសេសថ្មី ២ ។ Huntington (1991) បានលើកថា កត្តាសាកល (ជាជាងកត្តាក្នុងតំបន់) មានចំណែកសំខាន់នៅក្នុងកំលាំង និងវិសាលភាពនៃការរីករាលដាលលទ្ធិប្រជាធិបតេយ្យ រីឯការសិក្សាដ៏សំខាន់របស់ O'Donnell និង Schmitter (1986) ស្តីពី *អន្តរកាលចេញពីរបបផ្តាច់ការ* បានធ្វើឱ្យការសិក្សាពីប្រជាធិបតេយ្យភាវូបនីយកម្ម ប្រែប្រួលក្រឡាប់ចក្រ ដោយសង្កត់ធ្ងន់ពីសារៈសំខាន់នៃ "កិច្ចព្រមព្រៀងរបស់ពួកឋានៈខ្ពស់" ជាជាងកំណើននៃកំលាំងសង្គមដែលគាំទ្រលទ្ធិប្រជាធិបតេយ្យ ក្នុងការពន្លឿនអន្តរកាលទៅកាន់របបប្រជាធិបតេយ្យ ។

គំនិតដែលថា អន្តរកាលទៅកាន់របបប្រជាធិបតេយ្យ អាចត្រូវបានរៀបចំ និងអនុវត្តតាមរយៈសកម្មភាពដោយចេតនារបស់អ្នកឋានៈខ្ពស់ ដើម្បីឆ្លើយតបទៅនឹង "ឥទ្ធិពលនៃការបកស្រាយបង្ហាញ" ជាលក្ខណៈអន្តរជាតិ គឺជាគំនិតថ្មីប្លែកមួយនៅក្នុងវិទ្យាសាស្ត្រនយោបាយ ដែលជាយូរមកហើយតែងផ្តោតលើរចនាសម្ព័ន្ធត្រូវមានជាមុន និងតំរូវការរយៈពេលវែង (Di Palma 1990; Lipset 1969; Moore 1968) ។ ការយកចិត្តទុកដាក់លើកិច្ចព្រមព្រៀងរបស់ពួកឋានៈខ្ពស់ បានបំផុសកម្មវិធីស្រាវជ្រាវថ្មីៗ ដែលមិនសូវផ្តោតលើបញ្ហាការវិវត្តន៍នៃកំលាំងសង្គមគាំទ្រលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានទេ ប៉ុន្តែផ្តោតខ្លាំងទៅលើវិធីដែលពួកឋានៈខ្ពស់ក្នុងប្រទេសកំពុងកសាងរបបប្រជាធិបតេយ្យ បានប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីគាំទ្រ រឺធ្វើឱ្យអន្តរាយដល់ស្ថាប័នដែលបានកសាង រឺកែទំរង់ស្របទៅតាមបញ្ញត្តិនានានៃគោលនយោបាយអន្តរជាតិ ។

ក្នុងវិស័យគោលនយោបាយ ទ្រឹស្តីថ្មីៗស្តីពីប្រជាធិបតេយ្យភាវូបនីយកម្ម បានគាំទ្រដល់ការលើកកំពស់លទ្ធិប្រជាធិបតេយ្យនៅក្នុងនយោបាយពួកបស្ចឹមប្រទេសធំៗ ។ ប្រជាធិបតេយ្យភាវូបនីយកម្ម ដែលក្លាយជាគោលដៅរបស់ពួកបរទេស និងនយោបាយផ្តល់ជំនួយ វាផុសចេញពីនិក្ខេបបទពីរដែលពាក់ព័ន្ធគ្នា ។ និក្ខេបបទទី១ អះអាងថា ការបង្កើតស្ថាប័នប្រជាធិបតេយ្យនៅថ្នាក់កំពូល នឹងជួយលើកកំពស់នយោបាយប្រជាធិបតេយ្យនៅថ្នាក់ក្រោម ទោះបី "វប្បធម៌នយោបាយប្រជាធិបតេយ្យ" មិនទាន់មាននៅឡើយក្តី ។ លោក Luckham, Goertz និង Kaldor (2003) បានពន្យល់ពីរឿងនេះ ដោយញែកដាច់ពីគ្នារវាង "ស្ថាប័នប្រជាធិបតេយ្យ" និង "នយោបាយប្រជាធិបតេយ្យ" ។ ស្ថាប័នប្រជាធិបតេយ្យ គឺមានអង្គភាពទទួលបន្ទុកលើការបោះឆ្នោត ក្រុមជំនុំ និងភាគីនានាដែលយល់ដឹងច្រើនពីគោលនយោបាយលើកកំពស់លទ្ធិប្រជាធិបតេយ្យ ។ នយោបាយប្រជាធិបតេយ្យ ផ្តោតលើបរិបទនយោបាយដែលក្នុងនោះស្ថាប័នប្រជាធិបតេយ្យត្រូវដំណើរការ និងដែលជាបរិបទនៃរចនាសម្ព័ន្ធមិនផ្លូវការនៃអំណាច អង្គភាពនានានៃសហគមន៍មូលដ្ឋាន កំលាំងសង្គមមិនមែនរដ្ឋ ហើយអាចមានទាំងកំលាំងសង្គមមិនមែនជាតិទៀតផង ។ អ្នកកសាងទ្រឹស្តីអំពីអន្តរកាលបានអះអាងថា ការរចនាតាក់តែងស្ថាប័នថ្មីមួយ ទាមទារការកែប្រែឥរិយាបថខាងនយោបាយរបស់ប្រជាជន ដែលត្រូវសំរបយុទ្ធសាស្ត្រនយោបាយរបស់ខ្លួនឱ្យកាន់តែច្រើនឡើងទៅតាមក្បួន "ល្បែង" ប្រជាធិបតេយ្យ (O'Donnell and Schmitter 1986) ។ នៅពេលដែលតួអង្គនយោបាយ "មានទំលាប់" គ្រប់គ្រាន់ ជាមួយនឹងក្បួនទាំងនេះ ហើយលទ្ធិប្រជាធិបតេយ្យ បានក្លាយជា "ល្បែងតែមួយដែលមាននៅក្នុងស្រុកភូមិ" ការពង្រឹងលទ្ធិប្រជាធិបតេយ្យមុខតែនឹងកើតមាន (Linz and Stepan 1997) ។ ក្នុងរលកសុទិដ្ឋិនិយមដែលផុសឡើងនៅចុងបញ្ចប់នៃសង្គ្រាមត្រជាក់ ការពង្រឹងលទ្ធិប្រជាធិបតេយ្យច្រើនតែជាលទ្ធផលធម្មតាៗនៃអន្តរកាលប្រជាធិបតេយ្យ ប៉ុន្តែក៏អាចមានការវិវត្តន៍ "បញ្ច្រាស" ដែរ ដោយសារអន្តរាគមន៍យោធាដែលកើតមានជាថ្មី ។

និក្ខេបបទទី២ ដែលលើកកំពស់គោលនយោបាយជំរុញ លទ្ធិប្រជាធិបតេយ្យ គឺជានិក្ខេបបទសន្តិភាពប្រជាធិបតេយ្យ ។ និក្ខេបបទនេះផ្សារភ្ជាប់លទ្ធិប្រជាធិបតេយ្យទៅនឹងសន្តិភាព ដោយផ្អែកតាមការអះអាងរបស់ Kantian ដែលថា តួអង្គដែលមានវិចារណញ្ញាណផ្ទាល់ខ្លួន នឹងមិនធ្វើសង្គ្រាមទេ ពីព្រោះវាមិនស្របនឹងផលប្រយោជន៍របស់ពួកគេ ហើយរបបប្រជាធិបតេយ្យ គឺជាទំរង់មួយនៃរដ្ឋាភិបាលដែលរក្សាការពារបានប្រសើរ

---

* អត្ថបទនេះ ផ្អែកលើទស្សនៈ "កូនកាត់" ដែលជាក្របខ័ណ្ឌស្រាវជ្រាវដ៏មានប្រយោជន៍សំរាប់កម្មវិធីកំណែទំរង់វិស័យសាធារណៈ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៃ វបសអ ។ លោកស្រី Caroline Hughes ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និងការសិក្សាអន្តរជាតិនៃសាកលវិទ្យាល័យ Birmingham ប្រទេសអង់គ្លេស ។ លោក Joakim Öjendal ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យស្រាវជ្រាវខាងសន្តិភាព និងអភិវឌ្ឍន៍នៃសាកលវិទ្យាល័យ Goteborg ប្រទេសស៊ុយអែត លោក ប៉ក់ គីមជឿន ជាអ្នកស្រាវជ្រាវនៅ វបសអ ។

បំផុតនូវស្វ័យភាពរបស់តួអង្គមានវិចារណញាណ ។ ឧទាហរណ៍ លោក Boutros Boutros-Ghali អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ក្នុង *របៀបវារៈដើម្បីសន្តិភាព* ឆ្នាំ១៩៩២ របស់លោក បានផ្អែកតាមទ្រឹស្ដីសន្តិភាពប្រជាធិបតេយ្យរបស់ Kantian នេះ ដើម្បីអះអាងថា:

> *"មានទំនាក់ទំនងជាក់ស្ដែងរវាងរបៀបរបបប្រជាធិបតេយ្យ ដូចជា នីតិរដ្ឋ និងតំលាភាពក្នុងការធ្វើសេចក្ដីសំរេចចិត្តជាដើម ហើយនិងការទទួលបានសន្តិភាព និងសន្តិសុខពិតៗនៅក្នុងរបបនយោបាយថ្មី និងមានស្ថិរភាពល្អណាមួយ "(Boutros-Ghali, 1995) ។*

ក្នុងពេញមួយទសវត្សរ៍១៩៩០ ដំណោះស្រាយរឿងនយោបាយកាន់តែស្មុគស្មាញ ដែលជំរុញដោយអង្គការអន្តរជាតិដើម្បីដោះស្រាយសង្គ្រាមស៊ីវិលនានា បានដាក់បញ្ចូលការងារលើកកំពស់លទ្ធិប្រជាធិបតេយ្យ ជាពិសេសការបោះឆ្នោតពហុបក្ស ដើម្បីធ្វើជាមធ្យោបាយសំរាប់ពង្រឹងសន្តិភាព ។ ការបារម្ភក្នុងចំណុចនេះ បានបំប្លែងការលើកកំពស់លទ្ធិប្រជាធិបតេយ្យ ឱ្យទៅជាយុទ្ធសាស្ត្រសន្តិសុខជាតិយ៉ាងចំហមួយសំរាប់ពួកបស្ចិមប្រទេស (Evans, 1994) ។

គោលជំហរនេះ បានជំរុញឱ្យមានការបញ្ជូនទីប្រឹក្សាខាងលទ្ធិប្រជាធិបតេយ្យ ទៅជួយរដ្ឋាភិបាលនានានៅទូទាំងពិភពលោក ក្នុងការតាក់តែងច្បាប់ បង្កើតស្ថាប័ន និងរៀបចំការបោះឆ្នោត ។ និន្នាការនេះ ដែលសង្គ្រាមត្រជាក់បានជួយពង្រឹងឡើង វាត្រូវដោះស្រាយជំលោះផ្ទៃក្នុងជាច្រើន និងបង្កើតឡើងវិញនូវរដ្ឋាភិបាល ដែលអាចធ្វើការងារបាន ព្រមទាំងគោរពសិទ្ធិមនុស្ស និងប្រឹងប្រែងកសាងលទ្ធិប្រជាធិបតេយ្យ ។ ជារឿយៗ រឿងនេះធ្វើឡើងតាមរយៈអន្តរាគមន៍ពីអន្តរជាតិដើម្បី "ដាក់បញ្ចូល" ទៅក្នុងប្រព័ន្ធនយោបាយនានានូវនីតិវិធីប្រជាធិបតេយ្យ ដែលបានមកពីខាងក្រៅ និងមកពីថ្នាក់លើ (e.g. Doyle and Orr 1996) ។ ការបោះឆ្នោតក្រោយពេលបញ្ចប់សង្គ្រាមស៊ីវិល ដើម្បីផ្ដល់ភាពស្របច្បាប់ដល់របបដឹកនាំមានរដ្ឋធម្មនុញ្ញ បានក្លាយជាលក្ខណៈសំគាល់មួយនៃសឹងតែគ្រប់ដំណើរការកសាងសន្តិភាពដែលជួយឧបត្ថម្ភដោយអន្តរជាតិក្នុងទសវត្សរ៍១៩៩០ ។

## និយមន័យប្រជាធិបតេយ្យ

បញ្ហាមួយក្នុងការលើកកំពស់លទ្ធិប្រជាធិបតេយ្យ នៅក្រោយសម័យសង្គ្រាមត្រជាក់ គឺការកំណត់និយមន័យលទ្ធិប្រជាធិបតេយ្យ ។ ក្នុងការសិក្សាឯកសារខាងទ្រឹស្ដី មានការចាត់ទុកជាទូទៅថា "លទ្ធិប្រជាធិបតេយ្យ" គឺជា "ទស្សនៈមួយដែលមានការជជែកតវ៉ាច្រើន" ។ គេមិនអាចកំនត់និយមន័យនេះឱ្យបានគួរជាទីពេញចិត្តទេ ពីព្រោះវាបង្ហាញពីការវាយតំលៃផង និងការពិពណ៌នាផង (Gallie 1956) ។ ប៉ុន្តែការយកចិត្តទុកដាក់លើកកំពស់ និងវាយតំលៃលទ្ធិប្រជាធិបតេយ្យនៅជុំវិញពិភពលោក បានជំរុញឱ្យមានការប្រើប្រាស់ជាទូទៅនូវនិយមន័យសាមញ្ញៗក្នុងទសវត្សរ៍១៩៩០ ។ អន្តរកាលប្រជាធិបតេយ្យ មាននិយមន័យថាជាដំណើរការមួយដែលក្នុងនេះ ស្ថាប័នដែលធ្វើការគ្រប់គ្រងតាមបែបផ្ដាច់ការ រឺកុំម្មុយនីស្ដ ត្រូវបានជំនួស ឬកែទំរង់ដើម្បីឱ្យស្របទៅតាមការតំរូវឱ្យមានរបបពហុបក្សមួយក៏រីត ដែលមានដាក់បញ្ចូលលទ្ធភាពជ្រើសរើសអ្នកតំណាង លទ្ធភាពចូលរួមកសាងរបៀបវារៈនយោបាយ និងការគោរពសិទ្ធិពលរដ្ឋ សិទ្ធិខាងនយោបាយ និងសេរីភាព ។ ទស្សនៈ "ខ្នាតតូច" នៃលទ្ធិប្រជាធិបតេយ្យនេះ ដែលយកចេញពីការកំណត់របស់ Dahl ដែលថា "របបពហុបក្ស" ត្រូវមានជំរើស ការចូលរួម និងការគោរពសិទ្ធិមនុស្ស (Dahl 1971) វាបានដើរតួជានិយមន័យស្នូលសំរាប់អ្នកកសាងគោលនយោបាយអន្តរជាតិនានា ដោយពុំចាំបាច់មានការពិភាក្សាវែកញែកច្រើនទេ ។

ការសង្កត់ធ្ងន់លើវិធាន នីតិវិធី និងស្ថាប័ននានា ជាជាងលើវប្បធម៌ គុណតំលៃ និងក្រឹត្យក្រមនៃការធ្វើអន្តរកម្ម បានញុំាំងឱ្យការសិក្សាពីអន្តរកាលនានាក្លាយជាលែងមានបញ្ហាចោទ ពីព្រោះវាផ្ទេរការពិបាកផ្សេងៗក្នុងការបង្ហាញពីនយោបាយប្រជាធិបតេយ្យកាន់តែទូលំទូលាយ ទៅកាន់ដំណាក់កាលក្រោយនៃ "ការពង្រឹង" វិញ (Luckham etal. 2003:15") ។ ប៉ុន្តែនិយមន័យតាមបែបនីតិវិធីនៃលទ្ធិប្រជាធិបតេយ្យនេះ ត្រូវបានគេរិះគន់ក្នុងពីរចំណុច ។ ទី១ វាកាត់ផ្ដាច់ការចូលរួមធ្វើនយោបាយជាផ្លូវការចេញពីបញ្ហាយុត្តិធម៌ក្នុងសង្គមដ៏សំខាន់ ។ ទី២ និយមន័យទាំងនេះច្រើនតែបញ្ចេញប្រើដោយមានយោងតិចតួចទៅដល់ការពិតជាក់ស្ដែងដែលថា នៅក្នុងរបបប្រជាធិបតេយ្យដែលចាក់ឫសរឹងមាំនៃបស្ចិមប្រទេស នីតិវិធីផ្លូវការច្រើនមានដំណើរការមិនល្អទេ ក្នុងការកេណ្ឌប្រមូលការចូលរួមខាងនយោបាយដ៏ផុសផុលដោយមានការយល់ដឹងគ្រប់គ្រាន់ ។

## របបកូនកាត់ ក្នុងលក្ខណៈជាលទ្ធផលអន្តរកាលមួយបែបផ្សេង

ក្រៅពីបញ្ហាកំណត់និយមន័យលទ្ធិប្រជាធិបតេយ្យ ការពិតជាក់ស្ដែងក្នុងទសវត្សរ៍១៩៩០ ក៏បានចោទបញ្ហាដល់លំនាំនៃអន្តរកាលដែរ ។ គំនិតដែលថាបណ្ដាស្ថាប័នប្រជាធិបតេយ្យតាមបែបពីលើចុះក្រោម នឹងបង្កឱ្យមាននយោបាយប្រជាធិបតេយ្យតាមបែបពីក្រោមឡើងលើវិញ គឺហាក់ដូចមិនសូវពិតសោះនៅក្នុងការអនុវត្តន៍ជាក់ស្ដែង ។ ខណៈដែលប្រទេសមួយចំនួនតូចដែលធ្វើអន្តរកាលតាម "រលកទី៣" បានក្លាយជាប្រទេសមានប្រជាធិបតេយ្យដ៏ពេញលេញ ក៏មានប្រទេសជាច្រើនដែលបានជាប់ផុងនៅក្នុង "តំបន់ប្រផេះ" រឺក៏ "របបកូនកាត់" រឺ "ប្រជាធិបតេយ្យពាក់កណ្ដាល" រឺ "ប្រជាធិបតេយ្យក្លែងក្លាយ" ដែលមានគួបផ្សំ "សមាសធាតុនានានៃរបបផ្ដាច់ការ និងរបបប្រជាធិបតេយ្យ" (Karl 1995) ។ នៅក្នុងតំបន់ប្រផេះទាំងនេះ ទំរង់ផ្សេងៗនៃអន្តរកម្មនយោបាយ ដែល (បើគិតតាមទស្សនៈលើកកំពស់លទ្ធិប្រជាធិបតេយ្យ) ហាក់ដូចជា "លិ្វតល្វង់ខ្លាំងណាស់" ក៏បែរជានៅស្ថិតស្ថិរបានយូរគួរសម (Carothers 2002; Inoguchi and Bacon 2003) ។ នៅក្នុងរបបប្រជាធិបតេយ្យកូនកាត់ ចរិតប្រជាធិបតេយ្យនៃស្ថាប័ននានា មិនបានបង្កើតចេញនូវនយោបាយប្រជាធិបតេយ្យនៅស្រទាប់ក្រោមនោះទេ ហើយគេបានផ្ដល់សេចក្ដីពន្យល់មួយចំនួនដូចតទៅ ។

***ភាពមិនស្មោះត្រង់យ៉ាងផ្ដាច់ការ:*** ការធ្វើអន្តរកាលមួយចំនួនត្រូវបានគេចាត់ទុកថាជារឿងសើៗតែសំបកក្រៅ ដែលក្នុងនោះពួកឋានៈខ្ពស់បានផ្ដល់សេរីភាវូបនីយកម្មមួយក៏រីត ដើម្បីសំរាលការព្រួយបារម្ភរបស់អ្នកផ្ដល់ជំនួយ ប៉ុន្តែខំធ្វើយ៉ាងណាឱ្យស្ថាប័នប្រជាធិបតេយ្យនានា មានតួនាទីតូចតាចដដែលនៅក្នុងការងារនយោបាយពិតៗ ដូច្នេះហើយវាមិនអាចប្រើប្រាស់សំរាប់ពង្រឹងនយោបាយប្រជាធិបតេយ្យនៅថ្នាក់ក្រោមបានទេ ។

***ឆន្ទៈនយោបាយអន្តរជាតិមិនគ្រប់គ្រាន់:*** ការសិក្សាជាច្រើនបានថ្កោលទោសតួអង្គអន្តរជាតិដែលមិនបានផ្ដល់ធនធាន និងការយកចិត្តទុកដាក់គ្រប់គ្រាន់ ដើម្បីជំរុញសន្ទុះប្រជាធិបតេយ្យនៅប្រទេសជាក់លាក់មួយចំនួន ។

*វប្បធម៌នយោបាយមិនសមស្រប រឺខុសគ្នា:* កត្តាខាងវប្បធម៌ ដែលជួយពង្រឹងលទ្ធិប្រជាធិបតេយ្យមួយចំនួន ដូចជា របបប្រជាធិបតេយ្យបែបផ្សេរសិទ្ធិ (O'Donnel 1995) ហើយនិងរបបប្រជាធិបតេយ្យបែបអាស៊ី (Neher 1993) ត្រូវបានគេចាត់ទុកថា ជាលទ្ធផលនៃកង្វះខាតវប្បធម៌នយោបាយប្រជាធិបតេយ្យសំរាប់បំពេញបន្ថែមលើស្ថាប័នប្រជាធិបតេយ្យនានា ។ វប្បធម៌ឆ្លើយតបទៅនឹង "ស្នេហ៍មុខ"របស់បុគ្គល បានជំរុញអ្នកបោះឆ្នោតនៅអាមេរិកឡាទីន ឱ្យបោះឆ្នោតឱ្យបុរសខ្លាំង (តាមទ្រឹស្តីរបស់ O'Donnel) រីឯការគោរពដល់ឋានានុក្រម និងការផ្តល់អាទិភាពដល់ស្ថិរភាពសហគមន៍ ជាជាងឱកាសល្អរបស់បុគ្គលម្នាក់ៗ បានបង្កើតជាប្រព័ន្ធគណបក្សស្មៀមស្ពឹក ដែលកាត់បន្ថយសេរីភាពមួយចំនួននៅអាស៊ី (យោងតាម Neher) ។

*ចំណាប់អារម្មណ៍មិនសមស្របចំពោះសហគមន៍នយោបាយ:* Luckham *et al.* (2003) បានវែកញែកថា "បញ្ហាសំខាន់ក្នុងរយៈពេលវែង" គឺ តើត្រូវធ្វើយ៉ាងណាដើម្បីរៀបចំកំលាំងមិនមែនរដ្ឋទាំងនេះឱ្យទៅជា "សហគមន៍នយោបាយតែមួយដែលឈរលើការព្រមព្រៀងយ៉ាងទូលំទូលាយ និងទស្សនៈរាប់បញ្ចូលជាមួយគ្នានៃភាពជាពលរដ្ឋរួមគ្នា" ដែលត្រូវមានជាចាំបាច់សំរាប់អភិបាលកិច្ចបែបប្រជាធិបតេយ្យ ។ តាមរយៈការអះអាងបែបនេះ អ្នកនិពន្ធបានផ្តល់គំនិតថា បញ្ហាដ៏ធំបំផុត គឺការបែកបាក់គ្នាក្នុងសង្គម ដោយសារចំណងទាក់ទងខាងជនជាតិ រឺនិន្នាការនយោបាយ ។ រឿងនេះធ្វើឱ្យមានការផាត់ចេញពីស្ថាប័នប្រជាធិបតេយ្យជាតិជាផ្លូវការ ដែលមិនសូវមានការពាក់ព័ន្ធច្រើននឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

*ប្រភេទមិនសមស្របនៃលទ្ធិប្រជាធិបតេយ្យដែលត្រូវបានជំរុញឡើង:* Gills and Rocamora (1997) វែកញែកថា ទស្សនៈខ្វាតតូចនៃលទ្ធិប្រជាធិបតេយ្យ ដែលត្រូវបានជំរុញឡើងជាទូទៅនៅបណ្តាប្រទេសខាងត្បូង ដោយផ្អែកលើការកំនត់របស់ Robert Dahl នៅឆ្នាំ១៩៧១ គួរចាត់ទុកជា "លទ្ធិប្រជាធិបតេយ្យសន្ទុះខ្សោយ (low-intensity democracy)" ពោលគឺបណ្តាស្ថាប័នប្រជាធិបតេយ្យ "ផ្លូវការ" ដែលត្រូវបានរៀបចំឱ្យស៊ីគ្នានឹងតំរូវការនៃរបបមូលធនសាកល និងដាច់ចេញពីរបៀបវារៈយុត្តិធម៌សង្គមដែលជួយឱ្យវាមានលក្ខណៈទាក់ទាញចំពោះអ្នកក្រ ។ ប្រជាធិបតេយ្យប្រភេទនេះ វាទប់ស្កាត់ និងរាំងស្ទះ មិនមែនជួយសំរួលដល់តំរូវការនៅតាមមូលដ្ឋានឱ្យមានកំណែទំរង់សង្គមកិច្ចទូលំទូលាយនោះទេ ។ វាក៏នាំឱ្យមានការផាត់សាធារណជនចេញ ពីព្រោះការរំពឹងថានឹងមានជីវភាពប្រែប្រួលប្រសើរឡើង គឺត្រូវបរាជ័យអស់ ។ អ្នកនិពន្ធមានទស្សនៈថា ការលើកកំពស់លទ្ធិប្រជាធិបតេយ្យ គឺជាការចាប់យក "ស្តង់ដារមាសសាកល" នៃលទ្ធិប្រជាធិបតេយ្យ ដោយសារកំលាំងអនុត្តរភាពនានា (forces of hegemony) ។ (see also Robinson 1996; Abrahamsen 2000; Mkandwire 1999).

*ការយកចិត្តទុកដាក់មិនគ្រប់គ្រាន់ចំពោះអន្តរកម្មរវាងរដ្ឋ និងសង្គម:* Kohli (1997) បានដាក់ស្នើនូវសេណារីយ៉ូមួយផ្សេងទៀត នៅក្នុង "របបប្រជាធិបតេយ្យធ្វើតាមគេ" ដោយបង្ហាញថា ស្ថាប័នប្រជាធិបតេយ្យ ដែលខ្សោយ និងនាំចូលពីក្រៅប្រទេស អាចទទួលបរាជ័យដោយសារកំលាំងសង្គមដែលផ្អែកលើលក្ខណៈផ្សេងៗនៃសហគមន៍ ដូចជា ចំនងទាក់ទងមេកើយ-កូនចៅ សាច់ញាតិ ខ្សែរយៈខាងកុលសម្ព័ន្ធ រឺអត្តសញ្ញាណជនជាតិ ។ ម្យ៉ាងទៀត ការលើកកំពស់លទ្ធិប្រជាធិបតេយ្យ បានលើកទឹកចិត្តពួកឋានៈខ្ពស់ឱ្យប្រើប្រាស់លក្ខណៈសហគមន៍ទាំងនេះ ធ្វើជាមធ្យោបាយកេណ្ឌប្រមូលកំលាំងខាងនយោបាយ ដែលអាចនាំឱ្យមានការប៉ះទង្គិចអត្តសញ្ញាណ ការខូចខាតដល់រចនាសម្ព័ន្ធអាជ្ញាធរជាប្រពៃណី និងការសាបរលាបក្រឹត្យក្រមនៃសហគមន៍ ហើយទាំងអស់នេះ នឹងធ្វើឱ្យអាក់រអួល ដល់សណ្តាប់ធ្នាប់សង្គម ។ ការឆ្លើយតបរបស់ក្រុមផ្សេងៗចំពោះបញ្ហានេះនៅក្នុងការប្រកួតគ្នាមួយដែលក្នុងនោះ គំរូនយោបាយនាំចូល និងលក្ខខណ្ឌនៃវប្បធម៌ប្រជាជនដើម វាធ្វើអន្តរកម្មទៅលើគ្នា និងសំរបខ្លួនទៅតាមគ្នាចុះឡើង នឹងជំរុញឱ្យមានចលាចលខាងនយោបាយ ។

ជំហរទាំងឡាយខាងលើនេះ យល់ស្របនឹងសារណោសន្តិភាពបែបប្រជាធិបតេយ្យ ។ ក្នុងរឿងនេះដែរ ជំនឿជាទូទៅនៅក្រោយសម័យសង្គ្រាមត្រជាក់ បានទទួលការរិះគន់នៅចុងទសវត្សរ៍១៩៩០ ។ ឯកសារប្រៀបធៀបមួយបានផុសឡើង ដែលចងភ្ជាប់អន្តរកាលនយោបាយ (ក្នុងនេះមានទាំងអន្តរកាលទៅកាន់របបប្រជាធិបតេយ្យផង) ទៅនឹងអំពើហិង្សាកំរិតខ្ពស់ជាងអ្វីដែលធ្លាប់បានពិនិត្យឃើញ នៅក្នុងរបបប្រជាធិបតេយ្យដែលបានពង្រឹងហើយ រឺរបបផ្តាច់ការដែលបានពង្រឹងហើយ (Huntington 1991; Bratton and van de Walle 1996) ។ ការសិក្សានានាពីការកសាងឡើងវិញក្រោយពេលបញ្ចប់ទំនាស់ បានផ្តល់គំនិតថា ការដាក់បញ្ចូលនយោបាយប្រកួតប្រជែងគ្នារបស់គណបក្ស ទៅក្នុងស្ថានភាពមួយដែលក្នុងនោះ ទាំងសង្គមស៊ីវិល និងស្ថាប័នរដ្ឋ នៅមិនទាន់រឹងប៉ឹងដើម្បីទប់ស្កាត់ការផ្ទុះអំពើហិង្សាថ្មីៗទៀត វាផ្តល់លទ្ធភាពឱ្យក្រុមអ្នកប្រព្រឹត្តអំពើហិង្សាអាចច្បាមយកឱកាសធ្វើសកម្មភាពបាន (Huntington 1996; Paris 2003; Ottaway 2003) ។ ឥទ្ធិពលដ៏អាក្រក់នៃការបោះឆ្នោតនៅក្នុងដំណើរការសន្តិភាពនៅប្រទេស Angola និង Rwanda ដែលនៅក្រោយពេលចុះកិច្ចព្រមព្រៀងសន្តិភាព មានប្រជាជនស្លាប់ច្រើនជាងនៅមុនពេលចុះកិច្ចព្រមព្រៀងនោះ វាបានកាត់បន្ថយតំលៃនៃការប្រើប្រាស់ដោយជោគជ័យនូវការបោះឆ្នោត ដើម្បីផ្តល់លក្ខណៈពេញច្បាប់ដល់របបគ្រប់គ្រងថ្មីៗដែលគោរពរដ្ឋធម្មនុញ្ញ ដូចជានៅប្រទេស Mozambique ជាដើម ។ ទោះបីនៅតាមកន្លែងដែលការបោះឆ្នោត បានទទួលជោគជ័យក្នុងការកេណ្ឌប្រមូលការគាំទ្រឱ្យមានលក្ខណៈពេញច្បាប់ក្តី ប៉ុន្តែគេយល់ថាវាមានជោគជ័យតិចតួចណាស់ ក្នុងការជួយសំរួលឱ្យមានការចូលរួមខាងនយោបាយ ការលើកកំពស់ការគោរពសិទ្ធិមនុស្ស និងការកាត់បន្ថយសកម្មភាពរបស់រដ្ឋនៅក្នុងបញ្ហាមួយចំនួន ដូចជា អំពើពុករលួយជាដើម ។ សរុបមកគេយល់ថាទាំងអស់នេះ ហាក់ដូចបានរក្សាទុកដដែលនូវលក្ខខណ្ឌនានាដែលនឹងបង្កឱ្យមានទំនាស់ហិង្សាទៅអនាគតទៀត ។

## ការប្រើប្រាស់ទស្សនៈកូនកាត់ ដើម្បីស្វែងយល់ពីការលូតលាស់របបប្រជាធិបតេយ្យនៅកម្ពុជា

ក្នុងប៉ុន្មានឆ្នាំកន្លងទៅ ប្រទេសកម្ពុជាហាក់មានបង្ហាញនូវលក្ខណៈជាច្រើននៃរបបប្រជាធិបតេយ្យកូនកាត់ ។ ឧទាហរណ៍ ប្រព័ន្ធអភិបាលកិច្ចខាងនយោបាយនៅកម្ពុជា បានរក្សាទំរង់មួយចំនួននៃនីតិវិធី និងស្ថាប័នជាផ្លូវការរបស់របបប្រជាធិបតេយ្យសេរី ប៉ុន្តែគុណតំលៃស្នូលនានានៃលទ្ធិប្រជាធិបតេយ្យ មិនបានជ្រៀតជ្រាបចូលទៅក្នុងទំនាក់ទំនងរដ្ឋ-សង្គមទេ ។ ស្ថាប័នគន្លឹះៗ ក៏មិនទាន់មានសមត្ថភាពការពាររបបនយោបាយបែបប្រជាធិបតេយ្យ ការផ្តល់សេវាដ៏សក្តិសិទ្ធិ រឺធនធានធម្មជាតិដ៏សំខាន់ៗនោះដែរ ។ ប្រព័ន្ធដែលដំណើរការតាមខ្សែរយៈបុគ្គលជាមេកើយ ក៏បានផុសឡើងដោយបានលាយឡំប្រទាក់ក្រឡាជាមួយនឹងសេដ្ឋកិច្ចនយោបាយ ដែលស្វែង

រកប្រយោជន៍ និងស្ទើរតែមានលក្ខណៈពេញច្បាប់ហើយក៏ផ្ទេរចូលទៅក្នុងបរិបទថ្មីនៃនយោបាយមហាជនដើរតាមទីផ្សារសេរី (Hughes 2003; Un 2005) ។ ដូច្នេះហើយទំនាក់ទំនងរដ្ឋ-សង្គម អាចធ្វើឱ្យពុករលួយបាន អាចធ្វើអាជីវកម្មកេងយកប្រយោជន៍ រឺក៏គ្មានសោះតែម្ដងនៅក្នុងស្ថានភាពខ្លះ ។ ឥរិយាបថមន្ត្រីចំពោះពលរដ្ឋ និងឥរិយាបថរបស់ពលរដ្ឋចំពោះមន្ត្រី ក៏ប្រែប្រួលទៅតាមនោះដែរ ។

ចំពោះការស្រាវជ្រាវខាងគោលនយោបាយ គួរមានក្របខ័ណ្ឌមួយ ដែលក្នុងនោះ ត្រូវពិនិត្យនិងវិភាគ មិនត្រឹមតែពីចរិតនៃស្ថាប័នប្រជាធិបតេយ្យកម្ពុជា និងឥទ្ធិពលរបស់វាទៅលើនយោបាយនៅថ្នាក់ក្រោមប៉ុណ្ណោះទេ ប៉ុន្តែពីចរិតនៃនយោបាយនៅថ្នាក់ក្រោម និងឥទ្ធិពលរបស់វាទៅលើស្ថាប័នទាំងនោះទៀតផង ។ អន្តរកម្មរវាងរចនាសម្ព័ន្ធប្រជាធិបតេយ្យ និងមិនមែនប្រជាធិបតេយ្យ (ដែលមិនមែនមានតែរចនាសម្ព័ន្ធផ្ដាច់ការនោះទេ) នៃអំណាច និងរបៀបរបបអនុវត្តន៍នាបច្ចុប្បន្ននៃការចូលធ្វើនយោបាយរបស់ថ្នាក់ក្រោម បានបង្កើតជាទំនាក់ទំនងរដ្ឋ-សង្គមដ៏ស្មុគស្មាញមួយ ។ ម្យ៉ាងទៀត នៅក្នុងប្រព័ន្ធកូនកាត់ ដើម្បីវិភាគពីទំនាក់ទំនងបែបនេះ គេត្រូវធ្វើការស្រាវជ្រាវស្ទួលមួយដើម្បីកំណត់ លាតត្រដាង ស្វែងយល់ និងវិភាគពីឌីណាមិក និងឥទ្ធិពលនៃការរួមរស់ជាមួយគ្នា ព្រមទាំងទំនាក់ទំនងរវាងស្ថាប័នផ្លូវការ-ស្ថាប័នក្រៅផ្លូវការ ដំណើរការប្រជាធិបតេយ្យ-ដំណើរការមិនមែន (រឺប្រឆាំង) ប្រជាធិបតេយ្យ ការរៀបចំផ្អែកលើភាពសមហេតុផល-ផ្អែកលើប្រពៃណី ព្រមទាំងទស្សនៈវិស័យបែបនយោបាយ-បែបបច្ចេកទេស ។ ក្របខ័ណ្ឌនេះ ដែលសំរាប់ស្វែងយល់ពីទំនាក់ទំនងរដ្ឋ-សង្គម បានបង្ហាញនូវ ៣ វិស័យពាក់ព័ន្ធគ្នាសំរាប់ធ្វើការស្រាវជ្រាវឱ្យច្បាស់លាស់នៅកម្ពុជា ។

## ការអភិវឌ្ឍន៍ខាងស្ថាប័ន

ការងារនេះ ត្រូវផ្ដោតលើសមាសភាពខាងស្ថាប័នរបស់រដ្ឋ ។ ដំណើរការខាងក្នុងនៃម៉ាស៊ីនរដ្ឋ ការបែងចែកអំណាច និងតួនាទីរបស់តួអង្គផ្សេងៗ គួរយកធ្វើជាគោលដៅសំរាប់ការស្រាវជ្រាវ ។ គួរផ្ដោតជាពិសេសទៅលើការអនុវត្តន៍ និងបែបបទនៃកំណែទំរង់ស្ថាប័នសំខាន់ៗរបស់កម្ពុជា នៅក្នុងដំណើរការធ្វើវិមជ្ឈការនិងវិសហមជ្ឈការ ក្នុងនេះ មានទាំងប្រព័ន្ធបោះឆ្នោត ការផ្ដល់សេវា និងហិរញ្ញវត្ថុសាធារណៈផង ។ ដោយពិនិត្យពីបញ្ហាទាំងនេះក្នុងក្របខ័ណ្ឌប្រព័ន្ធកូនកាត់ ការស្រាវជ្រាវជាបឋមគួរស្វែងរក និងពន្យល់ពីអន្តរកម្មរវាងទិដ្ឋភាព ប្រជាធិបតេយ្យ-មិនមែនប្រជាធិបតេយ្យ ផ្លូវការ-មិនផ្លូវការ បច្ចេកទេស-នយោបាយ សមហេតុផល-ប្រពៃណី នៃនយោបាយ និងរដ្ឋបាល ។ បន្ទាប់មក គួរព្យាយាមវាយតំលៃពីឥទ្ធិពលនៃកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ ក្នុងបញ្ហាលើកកំពស់សមត្ថភាពរបស់រដ្ឋក្នុងការបង្កើត និងពង្រឹងការអនុវត្តន៍ច្បាប់ ការទាញយក និងបែងចែងទៅវិញនូវធនធាន ព្រមទាំងការបំផុសគំនិត និងកិច្ចការពារ "សីលធម៌សាធារណៈ" ។

## ទំនាក់ទំនងរដ្ឋ-សង្គម និងអន្តរការីនានា

សមត្ថភាពរដ្ឋដើម្បីបំពេញមុខងារស្នូលរបស់ខ្លួន ត្រូវកំនត់ឡើងទៅតាមការរៀបចំស្ថាប័ន ព្រមទាំងទំនាក់ទំនងរដ្ឋ-សង្គម ។ នៅកម្ពុជា មានឯកសារច្រើនណាស់បង្ហាញថា គំលាតរវាងអ្នកត្រួតត្រា និងអ្នកគេត្រួត គឺជាចំនុចខ្សោយចំបងជាប្រវត្តិសាស្ត្រ ក្នុងការបង្កើតទំនាក់ទំនងរដ្ឋ-សង្គម ដែលជួយសំរួលដល់មុខងារស្នូលរបស់រដ្ឋ និងបង្កើតបានជាគោលនយោបាយវិជ្ជមាន (Chandler 1998; Mabbet and Chandler 1996; Peang Meth 1991) ។ ការស្រាវជ្រាវពីចំនុចទាំងនេះ ផ្ដោតជាចំបងទៅលើបែបបទដែលតួអង្គ ក្នុងរដ្ឋ គេយល់ដឹងពីតួនាទីរបស់ខ្លួន វិធីដែលពួកគេព្យាយាមដោះស្រាយបញ្ហាដែលរដ្ឋមិនអាចលូកដៃបានជ្រៅ ដោយសារមានការតែងតាំងអន្តរការីផ្សេងៗ និងបែបបទដែលរឿងនេះជះឥទ្ធិពលដល់ការបង្កើត និងអនុវត្តន៍គោលនយោបាយ (ផ្លូវការ និងក្រៅផ្លូវការ) ។ ដូច្នេះត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើតំលាភាព គណនេយ្យភាព ភាពជាតំណាងឱ្យសាធារណជន និងការឆ្លើយតប ក៏ដូចជាការពិចារណាស៊ីជំរៅពីទំនាក់ទំនងនៃលក្ខណៈទាំងនេះទៅនឹងបទប្បញ្ញត្តិ និងនីតិវិធីជាផ្លូវការ លំនាំក្រៅផ្លូវការនៃអន្តរកម្មរវាងរដ្ឋ-សង្គម និងអន្តរការីនានា ព្រមទាំងគុណតំលៃខាងវប្បធម៌ និងក្រឹត្យក្រមផ្សេងៗដែលគ្រប់គ្រង និងកំនត់លំនាំទាំងអស់នេះ ។

## ការចូលរួមរបស់ពលរដ្ឋ

ការចូលរួមរបស់ពលរដ្ឋ ត្រូវបានកំនត់ថាជាដែនមួយ ដែលក្នុងនោះ បុគ្គល គ្រួសារ សហគមន៍ និងតួអង្គមិនមែនរដ្ឋ ធ្វើអន្តរកម្មជាមួយគ្នា និងជាមួយតំណាងរដ្ឋ ។ ម្យ៉ាងទៀត វាក៏ជាដែនដែលគ្រប់គ្រងដោយបទប្បញ្ញត្តិ និងនីតិវិធីផ្លូវការ (ការបោះឆ្នោត) ទំនាក់ទំនងក្រៅផ្លូវការ ព្រមទាំងគុណតំលៃ និងក្រឹត្យក្រមខាងវប្បធម៌ ។ ក្នុងអត្ថបទនេះ វាសំដៅដល់ការសិក្សាអំពីដំណើរការពីក្រោមឡើងលើដែលផ្ដោតលើគុណតំលៃ និងឥរិយាបថផ្សេងៗដែលគ្រប់គ្រងលើយុទ្ធសាស្ត្រនយោបាយប្រើប្រាស់ដោយសង្គមស៊ីវិលដើម្បីធ្វើការពាក់ព័ន្ធជាមួយរដ្ឋ ។ ប្រធានបទស្រាវជ្រាវជាក់លាក់មួយចំនួនអាចមានជាបញ្ហាអត្ថន័យនៃភាពជាពលរដ្ឋនៅកម្ពុជា តួនាទីនៃសង្គមស៊ីវិលក្នុងការបំពេញគំលាតរបស់រដ្ឋ ហើយនិងផលប៉ះពាល់នៃការចូលរួមតិចតួចរបស់ពលរដ្ឋនៅកម្ពុជាទៅលើសមត្ថភាពរបស់រដ្ឋក្នុងការបំពេញមុខងាររដ្ឋ ។

## សេចក្ដីសន្និដ្ឋាន

ក្របខ័ណ្ឌខាងលើ បង្ហាញពីរបៀបវារៈស្រាវជ្រាវថ្មីមួយសំរាប់ "របបកូនកាត់" ដែលផ្ដោតទៅលើទាំងនយោបាយថ្នាក់ខ្ពស់ខាងស្ថាប័ននៃអភិបាលកិច្ចបែបប្រជាធិតេយ្យ ហើយនិងអន្តរកម្មរវាងរដ្ឋ និងកំលាំងសង្គមនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។ វាក៏ផ្ដោតផងដែរទៅលើបញ្ហាថា តើនយោបាយបែបប្រជាធិបតេយ្យជួយជំរុញរឺទេ និងជំរុញយ៉ាងណាដល់ការផ្លាស់ប្ដូរសង្គមនៅថ្នាក់មូលដ្ឋាន ហើយការផ្លាស់ប្ដូរនេះ វាជួយជំរុញនយោបាយបែបប្រជាធិបតេយ្យវិញយ៉ាងដូចម្ដេច ។ ក្នុងក្របខ័ណ្ឌនេះ របៀបវារៈស្រាវជ្រាវសំរាប់ពិនិត្យមើលពីមធ្យោបាយផ្សេងៗ ដែលបុគ្គលធ្វើសេចក្ដីសំរេចជ្រើសរើស ព្រមទាំងចូលរួមធ្វើការពាក់ព័ន្ធជាផ្លូវការ និងក្រៅផ្លូវការជាមួយរដ្ឋ គឺត្រូវពិនិត្យមើលទាំងបទប្បញ្ញត្តិ និងនីតិវិធីជាផ្លូវការ ព្រមទាំងគុណតំលៃនិងក្រឹត្យក្រមសង្គមដែលបង្កើតបានជា វិធានមិនមែនលាយលក្ខណ៍អក្សរខាងនយោបាយនោះផង ។ វិធានមិនមែនលាយលក្ខណ៍អក្សរទាំងនេះ ជួយពន្យល់ពីជំរើសដែលបុគ្គលបានធ្វើឡើង វិធីអនុវត្តជំរើសរបស់ពួកគេ ហេតុផលដែលពួកគេសំរេចចិត្តបែបនេះ និង បែបបទដែលរដ្ឋនិងវប្បធម៌សហគមន៍ ជះឥទ្ធិពលទៅលើសេចក្ដីសំរេចចិត្តក្នុងការជ្រើសរើស ។

## ឯកសារយោង

*ឯកសារយោង សូមមើលក្នុងអត្ថបទជាភាសាអង់គ្លេស ។*

# កំណើនសេដ្ឋកិច្ចដ៏រឹងប៉ឹង និង ការកែលំអវិធីសាស្ត្ររាយការណ៍: ការសើរើកែតំរូវឡើងវិញនូវការប៉ាន់ស្មានក្នុងគណនីជាតិកម្ពុជា ឆ្នាំ២០០៥

*កញ្ញា អ៊ួច ច័ន្ទតារានី និងបណ្ឌិត **Keith Carpenter** ពិពណ៌នាពីលទ្ធផលគន្លឹះ និងបញ្ហាកើតឡើង បន្ទាប់ពីការចេញផ្សាយតួលេខប៉ាន់ស្មាននៃគណនីជាតិឆ្នាំ២០០៥ ដោយវិទ្យាស្ថានជាតិស្ថិតិ នៅខែកក្កដា ឆ្នាំ២០០៦ ។ **

អត្ថបទនេះរៀបរៀងឡើងបន្ទាប់ពីវិទ្យាស្ថានជាតិស្ថិតិ បានផ្សព្វផ្សាយនៅខែកក្កដា ២០០៦ នូវតួលេខប៉ាន់ស្មាននៃគណនីជាតិឆ្នាំ២០០៥ ។ អត្ថបទរៀបរាប់ពីចំនុចសំខាន់ៗខ្លះនៃការប៉ាន់ស្មានទាំងនោះ ព្រមទាំងបកស្រាយពីបញ្ហាមួយចំនួនដែលផុសឡើង ដូចជា អន្តរកម្មរវាងរចនាសម្ព័ន្ធសេដ្ឋកិច្ច និងលទ្ធភាពកាត់បន្ថយភាពក្រីក្រ ការបញ្ចូលតួលេខសើរើកែតំរូវក្នុងគណនីជាតិទៅក្នុងបណ្ដាឆ្នាំកន្លងមក និងការធានាកិរិតសមត្ថភាព សំរាប់រក្សាគុណភាពបច្ចុប្បន្ននៃគណនីជាតិ ។ ការវិភាគស៊ីជំរៅពីតួលេខប៉ាន់ស្មាន នៃគណនីជាតិនឹងមានចុះផ្សាយក្នុងឯកសារផ្សេងៗទៀតរបស់ វបសអ ។

នៅប្រទេសកម្ពុជា គេប្រើប្រាស់បញ្ជីឈ្មោះជាក់លាក់សំរាប់វិស័យសេដ្ឋកិច្ចទាំងបី គឺមាន កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ដោយមិនប្រើពាក្យវិស័យទី១ វិស័យទី២ និងវិស័យទី៣ នោះទេ ។ អត្ថបទនេះប្រើប្រាស់បញ្ជីឈ្មោះរបស់កម្ពុជា ប៉ុន្តែប្រើពាក្យថា "អនុវិស័យ" សំរាប់សំគាល់សមាសភាគនានាដែលមាននៅក្នុងវិស័យនីមួយៗ ដើម្បីជៀសវាងការភាន់ច្រឡំគ្នារវាងវិស័យទាំងមូល និងសកម្មភាពជាក់លាក់នានាដែលមាននៅក្នុងវិស័យនីមួយៗ ។

## កំណើនទូទៅ

វិទ្យាស្ថានជាតិស្ថិតិ (NIS) បានផ្សព្វផ្សាយនៅខែកក្កដា ២០០៦ នូវតួលេខប៉ាន់ស្មានដំបូងៗនៃគណនីជាតិសំរាប់ឆ្នាំ២០០៥ និងតួលេខប៉ាន់ស្មានសំរាប់ឆ្នាំ២០០១-២០០៤ ដែលបានសើរើកែតំរូវឡើងវិញ[1] ។ យោងតាម NIS សេដ្ឋកិច្ចកម្ពុជាកើនយ៉ាងច្រើននៅឆ្នាំ២០០៥ ។ ផសស ពិត គិតតាមថ្លៃថេរ

**តារាង ១. កំណើន ផសស លំអិតតាមវិស័យចំបងៗ (%) គិតតាមថ្លៃថេរ ឆ្នាំ២០០០**

| វិស័យ | 2004 | 2005 |
|---|---|---|
| **ផសស** | **10.0** | **13.4** |
| កសិកម្ម | 1.2 | 16.6 |
| ឧស្សាហកម្ម | 16.4 | 12.1 |
| សេវាកម្ម | 11.7 | 12.1 |

ឆ្នាំ២០០០ កើនបាន ១៣,៤% នៅឆ្នាំ២០០៥ ធៀបនឹងកំណើនកែតំរូវ ១០,០% នៅឆ្នាំ២០០៤ ។

កសិកម្ម ជាវិស័យមានចំណែកធំជាងគេ នៅក្នុងកំណើនឆ្នាំ២០០៥ ដោយកើនបាន ១៦,៦% នៅឆ្នាំ២០០៥ ធៀបនឹងអត្រាកំណើនកែតំរូវ ១,២% នៅឆ្នាំ២០០៤ ។ ប៉ុន្តែកំនើនក្នុងវិស័យឧស្សាហកម្ម បានថយចុះដោយមានកំរិត ១២,១% ធៀបនឹង ១៦,៤% នៅឆ្នាំ២០០៤ ។ វិស័យសេវាកម្ម កើនបាន ១២,១% ធៀបនឹងកំណើនកែតំរូវ ១១,៧% នៅឆ្នាំ២០០៤ ។

តួលេខដែលប៉ាន់ស្មានដំបូងៗ សំរាប់ឆ្នាំ២០០៥ មានចុះសង្ខេបនៅក្នុងតារាង ២ ។

## កំណើនក្នុងវិស័យកសិកម្ម

យោងតាម NIS ចំនុចគួរកត់សំគាល់ជាងគេនៅឆ្នាំ២០០៥ គឺកំណើនយ៉ាងច្រើនក្នុងវិស័យកសិកម្ម បើធៀបនឹងឆ្នាំ២០០៤ (តារាង៣) ដោយក្នុងនេះផលដំណាំមានចំណែកធំជាងគេ ។ ស្រូវដែលតំណាងឱ្យ ៤៨,៩% នៃតំលៃបន្ថែមដុលសំរាប់ផលដំណាំកសិកម្មគិតតាមថ្លៃថេរឆ្នាំ២០០០ បានកើនយ៉ាងខ្លាំងដល់ ៤៣,៥% នៅឆ្នាំ២០០៥ ធៀបនឹងការរួមចុះដល់ទៅ ១២,២% នៅឆ្នាំ២០០៤ ។ យោងតាម NIS សន្ទុះកំណើននេះបណ្ដាលមកពីធាតុអាកាសល្អ គួបផ្សំនឹងការកែលំអប្រព័ន្ធស្រោចស្រព ការពង្រីកផ្ទៃដីដាំដុះ និងកត្តាផ្សេងទៀត ដូចជា ការផ្លាស់ប្តូរបច្ចេកទេស និងការផ្សព្វផ្សាយ

**តារាង ២. តួលេខប៉ាន់ស្មាននៃ ផសស ឆ្នាំ២០០៥**

| | រៀល | កំណើន គិតជារៀល | ដុល្លារ | កំណើន គិតជាដុល្លារ |
|---|---|---|---|---|
| ផសស ចារីក | 25,350ពាន់លាន | 19.9% | 6195លាន | 17.7% |
| ផសស ចារីក គិតក្នុង១នាក់ | 1.833លាន | 17.5% | 448 | 15.3% |
| ផសស ពិត | 21,812ពាន់លាន | 13.4% | 5,330លាន | 11.3% |
| ផសស ពិត គិតក្នុង១នាក់ | 1.577លាន | 11.1% | 385 | 9.0% |

* អ៊ួច ច័ន្ទតារានី គឺជាជំនួយការស្រាវជ្រាវនៅ វបសអ ហើយបច្ចុប្បន្នបានផ្អាកការងារទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិត នៅសាលាគោលនយោបាយសាធារណៈ លី ក្វាន់យូ នៅសាកលវិទ្យាល័យជាតិសិង្ហបុរី ។ Dr Keith Carpenter ជាទីប្រឹក្សាខាងស្រាវជ្រាវនៅ វបសអ ។

**តារាង ៣. កំណើន ផសស ក្នុងវិស័យកសិកម្ម (%) គិតតាមថ្លៃថេរ ឆ្នាំ២០០០**

| អនុវិស័យ | 2004 | 2005 |
|---|---|---|
| ផលដំណាំ | 1.7 | 28.0 |
| ស្រូវ | -12.2 | 43.5 |
| សត្វចិញ្ចឹម គិតទាំងមាន់ទា | 4.5 | 5.8 |
| ផលនេសាទ | -1.7 | 5.6 |
| ព្រៃឈើ និងការកាប់ឈើ | 2.2 | 5.4 |

បច្ចេកទេសកសិកម្មជាដើម[២] ។

ធាតុអាកាសអំណោយផលនៅឆ្នាំ២០០៥ បានជួយឱ្យផលស្រូវវស្សាកើនយ៉ាងច្រើនដល់ទៅ ៧៩% នៃផលស្រូវសរុប រីកើន ៥១% ធៀបនឹងផលស្រូវឆ្នាំ២០០៤ ។ ភ្លៀងបានធ្លាក់ចុះចំពេលល្អក្នុងរយៈពេលដាំដុះ (ដើមរដូវវស្សា) នៅឆ្នាំ២០០៥ ថ្វីបើតំបន់ខ្លះជួបការរាំងស្ងួតនៅពាក់កណ្ដាលរដូវវស្សាក្ដី[៣] ។ ដោយមូលហេតុនេះ NIS ប៉ាន់ស្មានថា ៣១,១% នៃកំណើនផលស្រូវសរុបនៅឆ្នាំ២០០៥ ទទួលបានដោយសារធាតុអាកាសល្អ ។ ម្យ៉ាងទៀត យោងតាមរបាយការណ៍ក្រសួងកសិកម្ម គឺមានការវិនិយោគយ៉ាងច្រើនក្នុងការស្ដារជួសជុល និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ព្រមទាំងការដាក់អនុវត្តនីបច្ចេកទេសគ្រប់គ្រងទឹកកាន់តែប្រសើរឡើង ក្នុងប៉ុន្មានឆ្នាំកន្លងទៅ ។

យោងតាមទិន្នន័យទទួលបានពីក្រសួងកសិកម្ម កំណែលំអនេះ បានចូលរួមមួយចំណែកដល់កំណើន ២១% នៃផលស្រូវប្រាំងនៅឆ្នាំ២០០៥ និងរួមចំណែក ១,៣% ដល់កំណើនផលស្រូវសរុបនៅឆ្នាំ២០០៥ បើតាមការប៉ាន់ស្មានរបស់ NIS ។ លើសពីនេះទៅទៀត ផ្ទៃដីដាំដុះស្រូវបានពង្រីក ២,៧% នៅឆ្នាំ២០០៥ ដោយសារដីខ្លះដែលនៅទំនេរចោលកាលពីឆ្នាំមុន បានយកមកដាំស្រូវនៅឆ្នាំ២០០៥ ហើយដីព្រៃខ្លះ ក៏ត្រូវបានកាប់រានយកមកដាំស្រូវដែរ ។

**តារាង ៤. កំណើនក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម (%) គិតតាមថ្លៃថេរឆ្នាំ២០០០**

| វិស័យ/អនុវិស័យ | 2004 | 2005 |
|---|---|---|
| **ឧស្សាហកម្ម** | | |
| កម្មន្តសាលកម្ម | 17.6 | 9.7 |
| *កាត់ដេរ* | *24.9* | *10.3* |
| សាងសង់ | 13.2 | 20.1 |
| **សេវាកម្ម** | | |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 23.4 | 17.3 |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | 7.5 | 13.1 |
| អចលនទ្រព្យ និងសេវាបំរើអាជីវកម្ម | 12.6 | 6.9 |
| **ពន្ធប្រយោល** | **21.4** | **11.4** |
| **កំណើន ផសស សរុប** | **10.0** | **13.4** |

## កំណើនក្នុងវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម

អត្រាកំណើននៃអនុវិស័យសំខាន់ៗ នៅក្នុងវិស័យមិនមែនកសិកម្ម មានចុះក្នុងតារាង ៤ ។

កំណើនខាងកម្មន្តសាលធ្លាក់ចុះពី ១៧,៦% នៅឆ្នាំ២០០៤ ដល់ ៩,៧% នៅឆ្នាំ២០០៥ ដោយសារជាសំខាន់មកពីការធ្លាក់ចុះក្នុងឧស្សាហកម្មកាត់ដេរដែលមានអត្រាកំណើនពិត ថយចុះពី ២៤,៩% ដល់ ១០,៣% ។ ផលិតផលខាងសាងសង់កើន ២០,១% នៅឆ្នាំ២០០៥ ធៀបនឹង ១៣,២% នៅឆ្នាំ២០០៤ ដោយសារជាសំខាន់មកពីកំណើនសកម្មភាពសាងសង់នៅភ្នំពេញដែលផុសចេញពីកំណើនដ៏ខ្ពស់ក្នុងសេដ្ឋកិច្ចទាំងមូល ។

## របាយសកម្មភាពសេដ្ឋកិច្ច

របាយសកម្មភាពសេដ្ឋកិច្ច មានចុះក្នុងតារាង ៥ ។

សេវាកម្មនៅតែជាវិស័យធំបង់គេ ប៉ុន្តែបានថយចុះបន្តិចដោយសារការស្ទុះឡើងវិញនៃវិស័យកសិកម្មនៅឆ្នាំ២០០៥ ដូចមានបង្ហាញនៅក្នុងតួលេខកំណើន ។ តារាង៦ បង្ហាញពីអនុវិស័យសំខាន់ៗនៅក្នុងវិស័យនីមួយៗ ។

តារាង ៦ មិនបានបូកបញ្ចូលវិស័យ "ទេសចរណ៍" ទេ ពីព្រោះនៅក្នុងគណនីជាតិ គេមិនបានទទួលស្គាល់វាថាជាអនុវិស័យ ។ ក្នុងការប្រើប្រាស់ធម្មតា វិស័យ "ទេសចរណ៍" សំដៅដល់ទេសចរបរទេសចូលមកទស្សនាប្រទេសកម្ពុជា ដែលតែងប្រើប្រាស់សេវាដឹកជញ្ជូន សណ្ឋាគារ ភោជនីយដ្ឋាន សេវាផ្ទាល់ខ្លួនផ្សេងៗ និងទិញទំនិញនៅតាមហាងនានា ។ ចំណាយទាំងនេះត្រូវបានបូកបញ្ចូលក្នុងគណនីជាតិ ប៉ុន្តែយោងតាមរបាយការណ៍របស់ NIS គណនីជាតិមិនបានបែងចែក ចំណាយរបស់ទេសចរបរទេស ឱ្យដាច់ចេញពីចំណាយរបស់អ្នកដំណើរជានិវាសនជនកម្ពុជា ដែលកំពុងកើនឡើង រីក៏ចំណាយរបស់និវាសនជនកម្ពុជា ដែលធ្វើដំណើរចុះឡើងដើម្បីធ្វើការរកស៊ីនៅក្នុងប្រទេសកម្ពុជាទេ ។

អនុវិស័យនីមួយៗដែលរៀបរាប់នៅក្នុងតារាង ៦ តំណាងឱ្យប្រហែល ៦៣% នៃសកម្មភាពសេដ្ឋកិច្ចសរុប ហើយភាគរយនេះ សឹងគ្មានការប្រែប្រួលក្នុង ២ឆ្នាំចុងក្រោយ ។ តារាងនេះបង្ហាញថា មាន ៣ អនុវិស័យបានគ្របដណ្ដប់លើសេដ្ឋកិច្ច (ផលដំណាំ ផលនេសាទ និងកាត់ដេរ) ដែលបច្ចុប្បន្នតំណាងឱ្យជិត ៤០% នៃសកម្មភាពសេដ្ឋកិច្ចសរុប ។ ផលដំណាំតំណាងឱ្យប្រហែល ៥០% នៃតំលៃបន្ថែមដុលក្នុងវិស័យកសិកម្ម ហើយស្រូវតំណាង

**តារាង ៥. របាយសកម្មភាពសេដ្ឋកិច្ច តាមវិស័យ (%) គិតតាមថ្លៃថេរ ឆ្នាំ២០០០**

| វិស័យ | 2004 | 2005 |
|---|---|---|
| កសិកម្ម | 30.6 | 31.4 |
| ឧស្សាហកម្ម | 27.3 | 27.0 |
| សេវាកម្ម | 36.7 | 36.2 |
| ពន្ធប្រយោល | 6.5 | 6.3 |
| កំណៃតំរូវលើសេវាហិរញ្ញវត្ថុ | -1.0 | -1.0 |
| **សរុប** | **100** | **100** |

**តារាង ៦. ចំណែកអនុវិស័យសំខាន់ៗ នៅក្នុងវិស័យនីមួយៗ (%) គិតតាមថ្លៃថេរ ឆ្នាំ២០០០**

| វិស័យ/អនុវិស័យ | 2004 | 2005 |
|---|---|---|
| *កសិកម្ម* | ***30.6*** | ***31.4*** |
| ផលដំណាំ | 15.9 | 16.9 |
| ផលនេសាទ | 8.4 | 7.8 |
| *ឧស្សាហកម្ម* | ***27.3*** | ***27.0*** |
| កាត់ដេរ | 15.3 | 14.9 |
| *សេវាកម្ម* | ***36.7*** | ***36.2*** |
| ពាណិជ្ជកម្ម | 8.8 | 8.4 |
| អចលនទ្រព្យ និង សេវាបំរើអាជីវកម្ម | 7.0 | 6.6 |
| សេវាកម្មផ្សេងទៀត | 8.0 | 8.3 |

ឱ្យប្រហែលពាក់កណ្តាលនៃតំលៃបន្ថែមនេះ វីប្រហែល ២៥% នៃតំលៃបន្ថែមខាងវិស័យកសិកម្ម ។

ជិតបីភាគបួននៃតំលៃបន្ថែមក្នុងវិស័យឧស្សាហកម្ម បានមកពីកម្មន្តសាល ហើយជាងពាក់កណ្តាលនៃតំលៃបន្ថែមផ្នែកឧស្សាហកម្ម បានមកពីខាងកាត់ដេរ ។ វិស័យសេវាកម្មរួមមាន ចំណូលពីទេសចរណ៍ ហើយសំខាន់គឺទេសចរបរទេស ប៉ុន្តែភាគច្រើននៃចំណូលក្នុងវិស័យនេះ បានមកពីសកម្មភាពក្នុងវិស័យមិនរៀបរយ ពោលគឺសកម្មភាពដែលនៅខាងក្រៅចរន្តធំនៃសេដ្ឋកិច្ច ។ វិស័យនេះ មិនមែនជាក្បាលម៉ាស៊ីនដ៏មានសន្ទុះដែលផ្តល់សេវាជឿនលឿន ដូចក្នុងបណ្តាប្រទេសមានឧស្សាហកម្មទំនើបៗនោះទេ ប៉ុន្តែភាគច្រើន គឺជាពួកឈ្មួញតូចតាចដែលរកស៊ីក្នុងវិស័យសេដ្ឋកិច្ចបន្ទាប់បន្សំប៉ុណ្ណោះ ។

បើសិនដកវិស័យសេវាកម្មចេញ គេអាចនិយាយថា សេដ្ឋកិច្ចកម្ពុជា ត្រូវបានគ្របដណ្តប់ដោយអនុវិស័យនានាដែលពឹងផ្អែកលើធាតុអាកាស រឺមួយលើលទ្ធភាពមានទីផ្សារអំណោយផលនៅក្នុងប្រទេសអភិវឌ្ឍន៍ ព្រមទាំងសមត្ថភាពកាត់បន្ថយបន្ទុកចំណាយ ឱ្យទាបជាងប្រទេសកំពុងអភិវឌ្ឍន៍ឯទៀតៗ ។ ដូច្នេះវាមិនមែនជាមូលដ្ឋានរឹងមាំ សំរាប់កសាងសេដ្ឋកិច្ចមួយដែលអាចលើកស្ទួយប្រជាជនជនបទក្នុងចំនួនច្រើនៗ ឱ្យបានរួចផុតពីភាពក្រីក្រនោះទេ ។ ប៉ុន្តែសំនួរថា តើមូលដ្ឋានដ៏សមស្របនោះជាអ្វី វាស្ថិតក្នុងការគិតគូរជាប់ជានិច្ចរបស់សេដ្ឋវិទូខាងអភិវឌ្ឍន៍ និងស្ថាប័នជាច្រើនដែលយកចិត្តទុកដាក់ពីការរីកចំរើនទៅអនាគតរបស់ប្រទេសកម្ពុជា ដូចជាវិបសអ ជាដើម ។ ជាឧទាហរណ៍ សូមពិនិត្យពីបញ្ហានានាដែលធនាគារពិភពលោក បានធ្វើការស្ទាបស្ទង់មតិ ដូចមានចុះក្នុងឯកសារ *Cambodia: Halving poverty by 2015?* (*កម្ពុជា: កាត់បន្ថយភាពក្រីក្រ បានពាក់កណ្តាលនៅឆ្នាំ២០១៥?*)[៤] ។

## ការសើរើកែតំរូវលើគណនីជាតិ

ការសើរើកែតំរូវលើគណនីជាតិឆ្នាំ២០០៥ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការវាស់វែងសំខាន់ៗនៃសកម្មភាពសេដ្ឋកិច្ច ។ ការសើរើកែតំរូវ មានពីរប្រភេទធំៗ: ការពង្រីកដែនគ្របដណ្តប់ និងការកែលំអវិធីសាស្ត្រប្រមូលចងក្រងទិន្នន័យ ។ ការគ្របដណ្តប់ បានពង្រីកថែមទៀតតាមការដាក់បញ្ចូលកសិ-ពាណិជ្ជកម្ម ការយករ៉ែមាស ការរុករកប្រេងកាត ការផ្គត់ផ្គង់ឧស្ម័ន សកម្មភាពធានារ៉ាប់រង មីក្រូ-ហិរញ្ញវត្ថុ និងសកម្មភាពបូររប្រាក់ ។ ការគ្របដណ្តប់ ត្រូវបានកែលំអសំរាប់ការជីកយកត្បូង ការដឹកជញ្ជូនទំនិញ ការថែទាំសុខភាពឯកជន និងអ្នកផ្តល់សេវាថែទាំសុខភាពឯកជន ។ បច្ចុប្បន្ន NIS ជឿជាក់ថា ក្រៅពីការផលិត និងជួញដូរគ្រឿងញៀនខុសច្បាប់ចេញ គណនីជាតិ បានគ្របដណ្តប់លើសកម្មភាពសេដ្ឋកិច្ចគ្រប់បែបនៅកម្ពុជា ។ នេះជាការជឿនលឿនមួយយ៉ាងធំ ហើយ NIS គួរទទួលបានការលើកសរសើរចំពោះលទ្ធផលដ៏សំខាន់នេះ ។

ការធ្វើកំណែលំអវិធីសាស្ត្រប្រមូលចងក្រងទិន្នន័យ រួមមានការស្វែងរកប្រភពកាន់តែសមស្របនិងត្រឹមត្រូវសំរាប់ថ្លៃទំនិញ ការកែលំអសន្ទស្សន៍បរិត្តផរណា (price deflators) សំរាប់អនុវិស័យមួយចំនួន ការប៉ាន់ស្មានឱ្យកាន់តែត្រឹមត្រូវ នូវចំណាយប្រើប្រាស់ចុងក្រោយក្នុងគ្រួសារ (HFCE) និងការសើរើកែតំរូវវិធីសាស្ត្រ ដើម្បីបញ្ចូលចំណាយលើបរិក្ខារជាប់លាប់ ។ ការផ្លាស់ប្តូរខ្លះ គឺជាលទ្ធផលនៃការដាក់បញ្ចូលនូវ ការផ្លាស់ប្តូរចំពោះលំនាំចំណាយ និងផលិតកម្ម ដែលបានរកឃើញតាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៤ ។ CSES នឹងក្លាយទៅជាអង្កេតធ្វើឡើងជាប្រចាំចាប់តាំងពីឆ្នាំ២០០៧ តទៅ គឺមិនមែនប្រាំឆ្នាំធ្វើម្តងនោះទេ ហើយគេរំពឹងថា វិធីសាស្ត្រប្រមូលចងក្រងទិន្នន័យ នឹងអាចវិវត្តបានកាន់តែស៊ីសង្វាក់គ្នាល្អជាមួយនឹងការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច ។ លទ្ធផលនៃ CSES 2004 បានប៉ះពាល់ជាពិសេសដល់ការប៉ាន់ស្មានពី HFCE និងការប្រើប្រាស់បរិក្ខារជាប់លាប់ ។ តួលេខប៉ាន់ស្មានធ្វើឡើងកាលពីមុនក្នុងគណនីជាតិ វាយតំលៃលើការសន្មតថា ទំនិញជាប់លាប់ដែលនាំចូលត្រូវបានយកទៅប្រើប្រាស់នៅក្នុងផលិតកម្មឧស្សាហកម្មជាច្រើនប្រភេទ ។ CSES 2004 បង្ហាញថា អ្នកប្រើប្រាស់នៅទីក្រុង បានទិញទំនិញជាប់លាប់សំរាប់ប្រើប្រាស់ក្នុងគ្រួសារច្រើនជាងអ្វីដែលគេធ្លាប់បានគិតឃើញ ។ តួលេខប៉ាន់ស្មានចុងក្រោយលើ HFCE បានយកលទ្ធផលរកឃើញក្នុង CSES 2004 នេះមកប្រើប្រាស់ ហើយវានឹងបន្តជះឥទ្ធិពលទៅលើ ការប៉ាន់ស្មានក្នុងគណនីជាតិ នៅពេលអនាគតទៀតជាមិនខាន ។

ជាបន្ថែមពីលើ ការសើរើកែតំរូវដោយសារមានការផ្លាស់ប្តូរចំពោះការគ្របដណ្តប់ និងការប្រមូលចងក្រងទិន្នន័យ NIS ក៏បានធ្វើការផ្លាស់ប្តូរមួយចំនួនទាក់ទិននឹងប្រភពទិន្នន័យផងដែរ ក្នុងនេះ មានទាំងលទ្ធផលនៃ CSES 2004 ផង ។ លទ្ធផលបានពីការគន់គូរពិសេសលើកទី២ ស្តីពីប្រជាជនក៏បានដាក់បញ្ចូលទៅក្នុងការប៉ាន់ស្មានដែរ ។ ការគន់គូរពីប្រជាជនបានប៉ះពាល់ខ្លាំងជាងគេ ដល់បែបបទដែលលទ្ធផលបានពីគំរូតាង CSES អាចយកទៅប្រើប្រាស់ដើម្បីធ្វើការកំណត់តួលេខប៉ាន់ស្មាននៃធាតុចេញ និងចំណាយសំរាប់ប្រទេសកម្ពុជាទាំងមូល ។ ចំពោះទិន្នន័យសើរើកែតំរូវ គេក៏ទទួលបានពីក្រសួងជំនាញ និងធនាគារជាតិនៃកម្ពុជា មកដាក់បញ្ចូលនៅក្នុងគណនីជាតិដែរ ។ ទិន្នន័យសើរើកែតំរូវ ថែមទាំងមានបញ្ចូលនូវការសិក្សាពិសេសៗមួយចំនួនលើអនុវិស័យជាក់លាក់ ដូចជា វារីវប្បកម្មនេសាទសមុទ្រ សត្តឃាត និង កាស៊ីណូ ។ ដើម្បីធ្វើការប្រមូលទិន្នន័យសំរាប់គណនីជាតិ NIS ក៏បានធ្វើអង្កេតជាច្រើនដងមកហើយលើ អ្នកលក់ដុំ អ្នកលក់រាយ ផ្ទះសំណាក់ និងអាជីវករដឹកជញ្ជូន ដែលមាននៅក្នុងវិស័យមិនរៀបរយដែរ ។

## ការផ្ដល់មតិអំពី ការផ្លាស់ប្ដូរវិធីសាស្ត្រដើម្បីផ្សព្វផ្សាយតួលេខសើរើកែតំរូវនៃគណនីជាតិ

កាលពីមុន NIS បានដាក់បញ្ចូលការផ្លាស់ប្ដូរក្នុងការគ្រប់ដណ្ដប់ និងការប្រមូលចងក្រងទិន្នន័យ ទៅក្នុងតួលេខសើរើកែតំរូវនៃគណនីជាតិ នៅឆ្នាំមុនៗថយក្រោយមករហូតដល់ឆ្នាំ១៩៩៣ ។ ដោយមានការផ្ដល់មតិជំទាស់ពីអ្នកប្រើប្រាស់ទិន្នន័យ ជាពិសេសអ្នកប្រើប្រាស់ទិន្នន័យសំរាប់ធ្វើវិភាគពីមួយឆ្នាំទៅមួយឆ្នាំ NIS ក៏បានផ្លាស់ប្ដូររបៀបនេះចេញ ។ ដោយចាប់អនុវត្តពីត្រឹម តួលេខប៉ាន់ស្មានបច្ចុប្បន្ននៃគណនីជាតិនេះតទៅ កំរងទិន្នន័យនឹងត្រូវសើរើកែតំរូវ ដោយដាក់បញ្ចូលតួលេខកែតំរូវថយក្រោយតែត្រឹមឆ្នាំ២០០១ ។

គេអាចយល់បានពីវិធីធ្វើការសើរើកែតំរូវរបស់ NIS ប៉ុន្ដែរឿងតំរូវការធ្វើដូច្នេះ គឺជាចំងល់មួយ ។ គណនីជាតិមាន គោលដៅរាយការណ៍ឱ្យបានត្រឹមត្រូវ និងពិតប្រាកដជានិច្ច ។ បើសិនជាមានការរីកចំរើនខាងចំណេះដឹងអំពីដំណើរការសេដ្ឋកិច្ច ការរីកចំរើននេះគួរតែផ្សព្វផ្សាយឱ្យបានទំលំទូលាយ ដើម្បីជំរុញឱ្យមានការប្រើប្រាស់ទិន្នន័យល្អៗបំផុត ។ វាជាការមិនសមរម្យសោះ ដែលទៅធ្វើការរារាំង រឺបំភ្លេចចោលនូវកំណែលំអនានានៅក្នុងការគ្រប់ដណ្ដប់ និងវិធីសាស្ត្រ ពីព្រោះតែរឿងនេះ វាអាចនាំឱ្យគំរូសេដ្ឋកិច្ចជាក់លាក់ណាមួយ ត្រូវតែធ្វើការប៉ាន់ស្មាន គិតគូរ រឺក៏កសាងឡើងវិញនោះ ។

គណនីជាតិ គឺជាតួលេខប៉ាន់ស្មាន ហើយនឹងនៅតែជាការប៉ាន់ស្មានដូច្នេះជារៀងរហូត ប៉ុន្ដែអ្នកប្រើប្រាស់ទិន្នន័យ គួរតែអាចរំពឹងថា វាជាការប៉ាន់ស្មានដ៏ល្អបំផុត ដែលធ្វើឡើងដោយអ្នកមានវិជ្ជាជីវៈ និងមានការយល់ដឹងអំពីបច្ចេកទេសដ៏ចាំបាច់នានា ។ តួលេខប៉ាន់ស្មាននៃគណនីជាតិ គឺជាការប៉ាន់ស្មាន "ជួរទី១" ដែលធ្វើឡើងមុនគេ ក្រោយពេលប្រមូលចងក្រងបាននូវទិន្នន័យសេដ្ឋកិច្ចដើម ។ គំរូនានាក៏ជាការប៉ាន់ស្មានដែរ ហើយវាពឹងផ្អែកលើទិន្នន័យដែលកសាងចេញពីតួលេខប៉ាន់ស្មាននៃគណនីជាតិ ដូច្នេះ វាស្ថិតនៅឆ្ងាយមួយដំណាក់ថែមទៀតអំពីទិន្នន័យដើម ។ តាមលក្ខណៈនេះ វាជាការប៉ាន់ស្មាន "ជួរទី២" ។

គំនិតដែលថា អ្នកកសាងគំរូក្នុងឋានៈជាអ្នកប៉ាន់ស្មាននៅជួរទី២ គួរមាន "សិទ្ធិវេតូ" ចំពោះលទ្ធផលការងាររបស់គណនេយ្យករជាតិដែលជាអ្នកប៉ាន់ស្មានជួរទី១ វាបង្ហាញថា អ្នកខ្លះអាចភ្លេចពីគោលដៅនៃគណនីជាតិ ដែលត្រូវធ្វើការស្វែងយល់ឱ្យបានកាន់តែប្រសើរអំពីរចនាសម្ព័ន្ធ និងដំណើរការនៃសេដ្ឋកិច្ច ។ ក្នុងករណីធ្ងន់ធ្ងរបំផុត គេអាចប្រមើលឃើញពីស្ថានភាពមួយដែលក្នុងនោះ កំណែលំអផ្សេងៗចំពោះគណនីជាតិ គឺមិនបានផ្សព្វផ្សាយទេ ពីព្រោះវាអាចប៉ះពាល់ដល់កំរងតួលេខប៉ាន់ស្មាន ក្នុងច្រើនឆ្នាំកន្លងមក ។ ស្ថានភាពនេះអាចនាំឱ្យមានការកសាងគំរូប៉ាន់ស្មានផ្សេងៗ ដែលមិនមានភាពត្រឹមត្រូវដូចគ្នា ហើយដែលនឹងក្លាយជាមូលដ្ឋាននៃការជួយមតិយោបល់មិនសមស្រប ព្រមទាំងធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាជនកម្ពុជាជាទូទៅ ។

*មានការបារម្ភក្នុងរយៈពេលវែងថា តើការងារនឹងទៅជាយ៉ាងណានៅពេលសមាជិកកម្ពុជាចាកចេញពីក្រុម ទៅទទួលតួនាទីផ្សេងទៀត ។ គេសង្ឃឹមថា NIS មានផែនការបន្តតំណែង និងផែនការអន្តរកាលយ៉ាងសមស្រប ដើម្បីឱ្យអ្នកមកបន្តតំណែងអាចទទួលបានការផ្ទេរជំនាញនិងបទពិសោធន៍ពីក្រុមបច្ចុប្បន្ន ។ ទុនចំណេះដឹង ដែលបានកសាងឡើងយ៉ាងយកចិត្តទុកដាក់ក្នុងក្រុមគណនីជាតិ ត្រូវតែផ្ទេរទៅឱ្យពួកអ្នកវិជ្ជាជីវៈគណនីជាតិជំនាន់ក្រោយនៅពេលមានការចាំបាច់ ។*

## ការសង្ឃឹមទៅអនាគត

ការប៉ាន់ស្មាននៅក្នុងគណនីជាតិឆ្នាំ២០០៥ សំរាប់ប្រទេសកម្ពុជា បានបន្តការងារកំណែលំអបច្ចេកទេសប៉ាន់ស្មាន ដែលគេអាចមើលឃើញយ៉ាងច្បាស់នៅក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ កំណែលំអនេះ មួយចំណែកបានមកពីការកសាងសមត្ថភាពនៅក្នុង NIS ដោយក្រុមបច្ចុប្បន្នបានធ្វើការរួមគ្នា ៥ ឆ្នាំមកហើយលើការប៉ាន់ស្មាន ។ ក្នុងមួយឆ្នាំៗ ក្រុមនេះអាចកែលំអគុណភាពតួលេខប៉ាន់ស្មានរបស់ខ្លួន ដោយផ្អែកលើបទពិសោធន៍ពីឆ្នាំមុន ។

ជារឿយៗ ការរីកចំរើន គឺជាដំណើរការកែលំអម្ដងបន្តិចៗ ដោយឈរលើគ្រឹះដ៏រឹងមាំនៃការងារបានធ្វើពីមុនមក និងមិនមែនជាដំណើរការបែបលោតផ្លោះនោះទេ ។ កំណែលំអដែលកំពុងអនុវត្ត នៅក្នុងគណនីជាតិកម្ពុជា គឺជាឧទាហរណ៍ដ៏ល្អមួយចំពោះកំណែទំរង់ម្ដងបន្តិចៗ ដែលបានផ្ដល់នូវផលប្រយោជន៍ដល់ប្រទេសកម្ពុជា ។ ក្រុមបច្ចុប្បន្ន រួមមានទីប្រឹក្សាស្ថិតិពហុវិស័យម្នាក់របស់ IMF និងសមភាគីកម្ពុជាមួយចំនួន ។ រយៈពេលដែលក្រុមគណនីជាតិ បានធ្វើការងារជាមួយគ្នា ជាកត្តាដ៏ល្អដែលនឹងជួយឱ្យមានការបន្តការងារដ៏រលូន នៅពេលទីប្រឹក្សា IMF ត្រូវចប់បេសកកម្មរបស់ខ្លួន ។ មានការបារម្ភក្នុងរយៈពេលវែងថា តើការងារនឹងទៅជាយ៉ាងណានៅក្រោយពេលសមាជិកកម្ពុជាចាកចេញពីក្រុម ហើយទៅទទួលតួនាទីផ្សេងទៀត ។ គេសង្ឃឹមថា NIS មានផែនការបន្តតំណែង និងផែនការអន្តរកាលយ៉ាងសមស្របផ្សេងទៀត ដើម្បីធ្វើឱ្យអ្នកមកបន្តតំណែងអាចទទួលបានការផ្ទេរជំនាញ និងបទពិសោធន៍ពីក្រុមបច្ចុប្បន្ន ។ ទុនចំណេះដឹងដែលបានកសាងឡើងយ៉ាងយកចិត្តទុកដាក់ក្នុងក្រុមគណនីជាតិ ត្រូវតែផ្ទេរទៅឱ្យពួកអ្នកជំនាន់ក្រោយដែលមានវិជ្ជាជីវៈខាងគណនីជាតិដែរ នៅពេលមានការចាំបាច់ ។

## កំណត់សំគាល់

១. ការបកស្រាយក្នុងអត្ថបទនេះ ផ្អែកលើឯកសារដែល NIS ចែកអោយនៅពេលផ្សព្វផ្សាយទិន្នន័យ ព្រមទាំងការបកស្រាយដែល NIS បានធ្វើឡើងនៅពេលនោះ ។ NIS បោះពុម្ពផ្សាយនូវតួលេខគណនីជាតិជារៀងរាល់ឆ្នាំ ហើយចំពោះតួលេខសំរាប់ឆ្នាំ២០០៥ កំពុងរៀបចំបោះពុម្ពផ្សាយ ។

២. ការបកស្រាយរបស់ NIS នាឱកាសរាយការណ៍ប្រាប់អ្នកប្រើប្រាស់ទិន្នន័យ នៅពេលផ្សព្វផ្សាយតួលេខប៉ាន់ស្មានឆ្នាំ២០០៥ ។

៣. របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ខែមីនា ឆ្នាំ២០០៦) ។

៤. Phnom Penh (World Bank) February 2006.

# បណ្ណាល័យ វបសអ និង មណ្ឌលព័ត៌មានបឹងទន្លេសាប



### ការបង្កើតមណ្ឌលព័ត៌មានបឹងទន្លេសាប

គេតែងអធិប្បាយពីបឹងទន្លេសាប ដែលមានធនធានសំបូរស្តុកស្តម ថាជាសរសៃឈាមនៃប្រទេសកម្ពុជា ។ ដូចគ្នាដែរ បណ្ណាល័យ ដែលសំបូរឯកសារក៏ត្រូវគេចាត់ទុកថាជាសរសៃឈាមនៃវិទ្យាស្ថានស្រាវជ្រាវដ៏សក្តិសិទ្ធិដែរ ។ ការបង្កើតមណ្ឌលព័ត៌មានបឹងទន្លេសាប (TSI) នៅក្នុងបណ្ណាល័យនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) ធ្វើឡើងក្នុងចន្លោះពេលពីដើមខែមករា ដល់ចុងខែមិថុនា ២០០៦ ដោយបានទទួលជំនួយហិរញ្ញវត្ថុពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។

មណ្ឌលព័ត៌មានបឹងទន្លេសាប ក្រោមកិច្ចផ្តួចផ្តើមពី ADB បានចាប់ផ្តើមធ្វើក្នុងឆ្នាំ២០០២ ក្នុងលក្ខណៈជាគំរោងដៃគូគ្នា រវាងអង្គការ និងបុគ្គលនានា ដែលធ្វើការងារដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចមានចិរភាពនៅតំបន់អាងទន្លេសាប និងតំបន់ជុំវិញ ។ គំរោងរយៈពេល ១០ឆ្នាំនេះ មានទិសដៅការពារធនធានដ៏វិសេសនៃបឹងទន្លេសាប និងជួយឱ្យប្រជាជនកម្ពុជាបានយល់ដឹងកាន់តែច្បាស់ពីធនធានដ៏មានតំលៃរបស់កម្ពុជា ។ វបសអ រីករាយណាស់ ដោយបានចូលរួមក្នុងកម្មវិធីនេះ ដើម្បីផ្តល់ឱ្យអ្នកស្រាវជ្រាវ និងសាធារណជនទូទៅ នូវព័ត៌មាន និងលទ្ធផលនៃការងារអភិវឌ្ឍន៍ជាច្រើនរបស់មណ្ឌលព័ត៌មានបឹងទន្លេសាប ។

មណ្ឌលព័ត៌មានបឹងទន្លេសាបថ្មីនេះ ត្រូវបានបង្កើតឡើងជាចំណែកមួយនៃបណ្ណាល័យ វបសអ ដើម្បីបំរើការងារកសាងសមត្ថភាពនៃកម្មវិធីផ្តល់ព័ត៌មានបឹងទន្លេសាប ។ ធនធាននៃមណ្ឌលព័ត៌មានបឹងទន្លេសាប វាបំពេញបន្ថែមទៅលើលទ្ធភាព និងបណ្តាញការងារដែលមានស្រាប់នៅ វបសអ និងជាចំណែកមួយនៃសកម្មភាពដែល វបសអ កំពុងអនុវត្ត ។ ធនធានដ៏មានតម្លៃនៅបណ្ណាល័យ វបសអ សព្វថ្ងៃ រួមមានបណ្តុំសព្វគ្រប់នៃឯកសារបោះពុម្ពទាំងអស់របស់ វបសអ ព្រមទាំងបណ្តុំឯកសារពិសេសៗ ដូចជា :

- បណ្ណាល័យឯកសារធនាគារអភិវឌ្ឍន៍អាស៊ី
- បណ្តុំឯកសារវិទ្យាស្ថានស្រាវជ្រាវសហប្រជាជាតិ ដើម្បីការអភិវឌ្ឍន៍សង្គម
- បណ្តុំឯកសារនៃគម្រោងអន្តរស្ថាប័នសហប្រជាជាតិ ស្តីពីការជួញដូរមនុស្ស
- បណ្ណាល័យធនាគារពិភពលោក

ធនធានឯកសារទាំងនេះ ត្រូវបានបង្កើនឡើងយ៉ាងទៀងទាត់ ហើយវាជួយឱ្យបណ្ណាល័យ វបសអ មានបណ្តុំឯកសារប្រសើរជាងគេ ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍នៅកម្ពុជា ។

ក្នុងអំឡុងពេលបង្កើតមណ្ឌលព័ត៌មាន បុគ្គលិកបណ្ណាល័យ វបសអ បានធ្វើការរួមគ្នាកសាងបណ្តុំឯកសារ ដោយដាក់បញ្ចូលព័ត៌មានថ្មីៗទៀត ជាពិសេស ឯកសារទាក់ទងនឹងកម្មវិធីព័ត៌មានបឹងទន្លេសាប និងតំបន់ទីជំរាលអាងទន្លេសាប ។ បុគ្គលិកបណ្ណាល័យ បានធ្វើទស្សនកិច្ចជាទៀងទាត់នៅតាមស្ថាប័ននានា ដើម្បីប្រមូលធនធានបន្ថែមសំរាប់បណ្ណាល័យ ដូចជា សៀវភៅ ប័ណ្ណផ្សព្វផ្សាយ ស៊ីឌីរ៉ូម និងផែនទី ។ ម្យ៉ាងទៀត ពួកគេបានចំណាយពេលច្រើនណាស់ ដើម្បីស្វែងរកឯកសារផ្សេងៗ ដែលមានលើអ៊ិនធឺណិត ។ ធនធានទាំងអស់នេះ បានដាក់បញ្ចូលទៅក្នុងកាតាឡុកថ្មី លើអ៊ិនធឺណិតនៃឯកសារក្នុងបណ្ណាល័យ វបសអ សំរាប់ឱ្យសាធារណជនមានលទ្ធភាពប្រើប្រាស់វាបានយ៉ាងងាយស្រួល ។

ឯកសារសំខាន់ៗនៅក្នុងមណ្ឌលព័ត៌មាន រួមមាន :

- អត្ថបទផ្សេងៗ របស់ ADB ស្តីពីតំបន់បឹងទន្លេសាប
- ប្រព័ន្ធទិន្នន័យជីវមណ្ឌលនៅទន្លេសាប
- ប្រព័ន្ធទិន្នន័យស្តីពីរបាយការណ៍ទាក់ទងនឹង TSI
- សៀវភៅ ទស្សនាវដ្តី និងឯកសារទាក់ទងនឹងអាងទន្លេសាប
- សៀវភៅ និងប័ណ្ណផ្សព្វផ្សាយ របស់ ADB ស្តីពី TSI
- ផែនទី
- ឯកសារផ្សព្វផ្សាយជាស៊ីឌីរ៉ូម របស់ ADB គណៈកម្មាធិការទន្លេមេគង្គ (MRC) និងអង្គការផ្សេងៗទៀត
- ឯកសារបោះពុម្ពរបស់ World Fish Centre
- ឯកសារបោះពុម្ពរបស់គណៈកម្មាធិការទន្លេមេគង្គ
- ឯកសារដាក់លើអ៊ិនធឺណិត
- របាយការណ៍ស្រាវជ្រាវ និងនិក្ខេបបទ

### ការតុបតែងបណ្ណាល័យជាថ្មី និងបំពាក់គ្រឿងបន្ថែម

ក្រុមការងារបណ្ណាល័យ ដែលរួមមានលោក ហឺ ហ៊ិន លោកស្រី អ៊ុន ស៊ីណុច និងកញ្ញា ស៊ន ម៉ាដែន រួមជាមួយទីប្រឹក្សា និងអ្នកស្ម័គ្រចិត្ត បានធ្វើការរួមគ្នារៀបចំកែលំអបណ្ណាល័យឡើងវិញ ដោយបំពាក់ឧបករណ៍ គ្រឿងសង្ហារឹម និងរបស់ប្រើប្រាស់ថ្មីៗមួយចំនួន ។ ការរៀបចំជាថ្មី បានជួយបណ្ណាល័យ

ឱ្យផ្ដល់សេវាបានកាន់តែប្រសើរ ហើយក្នុងពេលជាមួយគ្នាក៏ផ្ដោតការយកចិត្តទុកដាក់ចំពោះមណ្ឌលព័ត៌មានបឹងទន្លេសាប ក្រោមជំនួយឧបត្ថម្ភរបស់ ADB ដែលជាផ្នែកដ៏សំខាន់មួយនៃបណ្ណាល័យ ។

ក្រៅពីកំណែលំអរបៀបរៀបចំបណ្ណាល័យ ក៏មានការដាក់សញ្ញាសំគាល់ជាច្រើនបន្ថែមទៀត ដើម្បីជួយដល់អ្នកមកបណ្ណាល័យ ឱ្យងាយស្រួលក្នុងការរកឯកសារតាមវិស័យនីមួយៗ ។ ម្យ៉ាងទៀត បានដាក់ប្រើកុំព្យូទ័រ ៤គ្រឿង សំរាប់ឱ្យអ្នកមកបណ្ណាល័យ ស្រាវជ្រាវរកឯកសារតាមកម្មវិធី OPAC ក្នុងនេះកុំព្យូទ័រ ២គ្រឿងបានភ្ជាប់នឹងអ៊ីនធឺណិត ។ នៅគ្រប់ពេលតែងមានទីប្រឹក្សាមួយរូបប្រចាំការ សំរាប់ជួយដល់អ្នកអានក្នុងការស្វែងរកឯកសារ និងជួយណែនាំពីប្រព័ន្ធក្នុងបណ្ណាល័យផងដែរ ។

## ប្រព័ន្ធ NewGenLib

បណ្ណាល័យទំនើបៗ និងមណ្ឌលព័ត៌មាន អាចផ្ដល់លទ្ធភាពខ្ពស់ ក្នុងការស្វែងរកព័ត៌មាន តាមរយៈការប្រើប្រាស់ សូហ្វវែរសំរាប់គ្រប់គ្រងប្រព័ន្ធបណ្ណាល័យ ។ ក្នុងករណីភាគច្រើន សូហ្វវែរនេះមានតម្លៃខ្ពស់ ហើយបណ្ណាល័យជាច្រើន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ពុំមានលទ្ធភាពទិញវាមកប្រើប្រាស់ទេ ។ វបសអ បានជាវប្រព័ន្ធគ្រប់គ្រងបណ្ណាល័យដ៏ទំនើបជា "បច្ចេកវិទ្យាឈានមុខ" ហៅថាប្រព័ន្ធ NewGenLib ដែលជាចំណុចស្នូលនៃការអភិវឌ្ឍន៍បណ្ណាល័យ និងការបង្កើតមណ្ឌលព័ត៌មានបឹងទន្លេសាប ។ បុគ្គលិក វបសអ បានប្រើប្រាស់ប្រព័ន្ធ NewGenLib នេះសំរាប់គ្រប់គ្រងប្រព័ន្ធជាប់ពាក់ព័ន្ធទាំងអស់ រួមទាំង ឯកសារទទួលបាន ការចែកចាយទៅឱ្យអ្នកខ្ចី បញ្ជីឈ្មោះឯកសារ និងកាតាឡុកលើអ៊ីនធឺណិត (OPAC) ។ ប្រព័ន្ធ NewGenLib បានបង្កើតឡើងនៅប្រទេសឥណ្ឌា ដោយប្រើបច្ចេកវិទ្យាមានប្រភពបើកទូលាយ ដើម្បីផលិតកម្មវិធីប្រព័ន្ធគ្រប់គ្រងបណ្ណាល័យតាមស្តង់ដារអន្តរជាតិមួយសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ ។ ប្រព័ន្ធថ្មីនេះមានចំនុចពិសេសជាច្រើន ដែលជួយដល់បុគ្គលិកក្នុងការផ្ដល់ "គុណភាពបន្ថែម" ដល់អ្នកប្រើប្រាស់សេវាបណ្ណាល័យ ។ ប្រព័ន្ធ NewGenLib ផ្ដល់លទ្ធភាពឱ្យរកបានដោយងាយនូវធនធានគ្រប់បែបយ៉ាង មានទាំង សៀវភៅនៅលើធ្នើ ទូ ឯកសារលើអ៊ីនធឺណិត ឬឯកសារជាឌីជីថល ដែលមាននៅតាមកន្លែងផ្សេងៗទៀត ក៏ដូចជាព័ត៌មានលំអិតជាងមុនលើឯកសារនីមួយៗ ។

ដើម្បីជួយសំរួលដល់ការប្រើប្រាស់ប្រព័ន្ធ NewGenLib នៅក្នុងបណ្ណាល័យ វបសអ ក្រុមការងារបណ្ណាល័យបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយលោក ឡឹង វណ្ណា ប្រធានផ្នែកបច្ចេកវិទ្យាព័ត៌មាន (IT) របស់ វបសអ និងក្រុម NewGenLib នៅឥណ្ឌា ។ មុនពេលធ្វើការផ្លាស់ប្ដូរកម្មវិធី បញ្ជីឯកសារជាឌីជីថល ដែលប្រើកម្មវិធី WINISIS បានផ្ញើទៅកាន់ប្រទេសឥណ្ឌា ដើម្បីបំលែងកំណត់ត្រាឯកសារ ទៅជារចនាសម្ព័ន្ធស្តង់ដារអន្តរជាតិ MARC 21 សំរាប់ត្រៀមតំលើងប្រព័ន្ធ NewGenLib ។ កុំព្យូទ័រថ្មីៗ និង server ក៏បានទិញ និងដាក់តំលើងកាលពីចុងខែមីនាដែរ ។

លោក Meher Siddhartha វិស្វករផ្នែកប្រព័ន្ធ NewGenLib បានមកធ្វើទស្សនកិច្ច ២សប្ដាហ៍ នៅ វបសអ កាលពីចុងខែមីនា ២០០៦ ដើម្បីតំលើងសូហ្វវែរ និងបណ្ដុះបណ្ដាលដល់ប្រធានផ្នែក IT និងបុគ្គលិកបណ្ណាល័យវបសអ ក្នុងការប្រើប្រាស់ និងគ្រប់គ្រងប្រព័ន្ធថ្មី ។ បណ្ណាល័យបានបិទទ្វារអស់ ២សប្ដាហ៍ ក្នុងពេលមានការបណ្ដុះបណ្ដាលពីប្រព័ន្ធ NewGenLib ។ ក្រោយការបណ្ដុះបណ្ដាលពីប្រព័ន្ធ NewGenLib បុគ្គលិកបណ្ណាល័យរួមជាមួយអ្នកស្ម័គ្រចិត្ត និងបុគ្គលិកអណ្ដែត បានធ្វើការងារយ៉ាងខ្លាំងក្លា ដើម្បីដាក់លេខកូដសៀវភៅ និងរៀបចំកំណត់ត្រាបញ្ជីឈ្មោះសៀវភៅសំរាប់ចែកចាយឱ្យបានត្រឹមត្រូវ ។ ការកសាងបណ្ដុំឯកសារកំពុងបន្តទៅមុខទៀត ហើយបុគ្គលិកមានការយល់ដឹងកាន់តែច្រើនពី ប្រភេទឯកសារដែលត្រូវមាន ដើម្បីឱ្យបណ្ដុំឯកសារមានលក្ខណៈពាក់ព័ន្ធនឹងតំរូវការ ។ បុគ្គលិកទាំងអស់បន្តការរៀនសូត្រពីជំនាញថ្មី ដោយផ្ដោតការប្រឹងអភិវឌ្ឍន៍សមត្ថភាពខ្លួនក្នុងការរៀបចំបញ្ជីឈ្មោះ និងធ្វើចំណាត់ថ្នាក់សៀវភៅ ដោយមានការជួយណែនាំពីទីប្រឹក្សាបណ្ណាល័យ ។



## បណ្ណាល័យរៀបចំថ្មី

បណ្ណាល័យរៀបចំថ្មីរបស់ វបសអ ដែលមានរួមបញ្ចូលទាំងមណ្ឌលព័ត៌មានបឹងទន្លេសាបផង គឺជាកន្លែងទាក់ទាញ និងជាទីចំណាប់អារម្មណ៍នៃមិត្តអ្នកអាន ។ បណ្ណាល័យផ្ដល់ឱ្យអ្នកប្រើប្រាស់នូវព័ត៌មានសំខាន់ៗទាក់ទងនឹងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ជាពិសេសព័ត៌មានស្ដីពីទន្លេសាប ក្រោមជំនួយឧបត្ថម្ភរបស់ ADB ។ ការកែលំអសេវាបណ្ណាល័យរួមមានទាំង ការដាក់សញ្ញាសំគាល់តាមប្រព័ន្ធ Dewey Decimal System ការដាក់តុធ្វើការរបស់ទីប្រឹក្សា អ្នកអាននៅកន្លែងសាធារណៈ ការបង្កើតកាតាឡុកលើអ៊ីនធឺណិត (OPAC) និងបណ្ដុំឯកសារយោង ។ បុគ្គលិកបណ្ណាល័យបានរៀនសូត្រជំនាញថ្មី និងបានទទួលស្វាគមន៍ភ្ញៀវថ្មីៗជាច្រើននាក់ ដែលមកអានឯកសារ រឺជាអ្នកស្រាវជ្រាវជារៀងរាល់ថ្ងៃ ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

ក្នុងកំឡុងត្រីមាសទី១ ២០០៦ ផសស ពិត នៅ US កើនខ្ពស់ជាងកាលពីមួយឆ្នាំមុន ៥,៦% ធៀបនឹងកំណើន ១,១% នៅត្រីមាសទី៤ ២០០៥ ។ សន្ទុះកំណើន ផសស ពិត នៅត្រីមាសទី១នេះ សំខាន់គឺដោយសារកំណើននៃចំណាយប្រើប្រាស់ផ្ទាល់ខ្លួន វិនិយោគក្នុងស្រុករបស់ឯកជន និងចំណាយរដ្ឋាភិបាលសហព័ន្ធ ។

នៅត្រីមាសទី១ ២០០៦ ផសស ពិត នៅតំបន់អឺរ៉ូ កើនឡើងតាមអត្រាប្រចាំឆ្នាំ ២,០% រឺកើន ០,៦% ធៀបនឹងត្រីមាសមុន ។ ផសស ពិត នៅជប៉ុន កើនតាមអត្រាប្រចាំឆ្នាំ ៣,០% រឺកើន ០,៥% ធៀបនឹងត្រីមាសមុន ។

ចិន នៅតែមានកំណើនសេដ្ឋកិច្ចកំរិតខ្ពស់ នៅត្រីមាសទី១ ២០០៦ ដោយមានកំណើន ផសស ពិត ១០,៩% រឺ ១,០% ខ្ពស់ជាងនៅត្រីមាសមុន ។ វិស័យទី២ (ឧស្សាហកម្ម) មានកំណើនខ្ពស់បំផុត គឺ ១៣,២% រីឯ វិស័យទី១ និងទី៣ មានអត្រាកំណើនទាបជាងត្រឹម ៩,៤% និង ៥,១% ។ ផសស ពិត នៅកូរ៉េខាងត្បូង នៅត្រីមាសទី១ ២០០៦ កើនតាមអត្រាប្រចាំឆ្នាំ ៦,១% ធៀបនឹងកំណើន ៥,២% នៅត្រីមាសទី៤ ២០០៥ ។ ផសស ពិត នៅហុងកុង កើនតាមអត្រាប្រចាំឆ្នាំ ៨,២% ហើយនៅតៃវ៉ាន់ វាកើន ៤,៩% ។

នៅត្រីមាសទី១ ២០០៦ សេដ្ឋកិច្ចម៉ាឡេស៊ី មានអត្រាកំណើន ៥,៣% ធៀបនឹងកំណើន ៥,២% នៅត្រីមាសទី៤ ២០០៥ ។ នៅខាងផលិតកម្មវិញ ផ្នែកកម្មន្តសាល មានកំណើនយ៉ាងខ្ពស់ដល់ ៨% ។ រីឯនៅខាងផ្នែកចំណាយ ចំណាយឯកជនបាននាំមុខគេដោយកើន ៧,៥% ។ សេដ្ឋកិច្ចសិង្ហបុរី នៅត្រីមាសទី១ ២០០៦ បន្តកើនឡើងយ៉ាងខ្លាំងដល់ទៅ ១០,៧% ។ ខាងកម្មន្តសាល កើនបាន ២០,២% រីឯវិស័យសេវាកម្ម កើនបាន ៧% ។ ផសស ពិត នៅថៃ នៅត្រីមាសទី១ ២០០៦ កើនបាន ៦,០% ធៀបនឹងកំណើន ៤,៧% នៅត្រីមាសមុន ។ វិស័យកសិកម្ម មានកំណើនយ៉ាងខ្ពស់ដល់ ៧,១% ធៀបនឹងការធ្លាក់ចុះ ០,២% នៅត្រីមាសទី៤ ២០០៥ ។ វិស័យមិនមែនកសិកម្មកើនបាន ៥,៩% ធៀបនឹងកំណើន ៥,៣% នៅត្រីមាសមុន ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី១ ២០០៦ ថ្លៃទំនិញប្រើប្រាស់នៅ US កើនតាមអត្រាប្រចាំឆ្នាំ ៣,៧% ដែលបណ្ដាលជាសំខាន់មកពីកំណើនថ្លៃថាមពល និងម្ហូបអាហារ ។ នៅតំបន់អឺរ៉ូ អតិផរណាថយចុះមកត្រឹម ២,៣% ធៀបនឹង កំរិត ២,៤% នៅត្រីមាសទី៤ ២០០៥ ដែលជាសំខាន់បណ្ដាលមកពីការថយចុះអតិផរណាថ្លៃថាមពល និងការថយចុះអត្រាកំណើនប្រចាំឆ្នាំនៃថ្លៃម្ហូបមិនកែច្នៃ ។ ក្នុងកំឡុងពេលដដែល បំរែបំរួលពីមួយឆ្នាំទៅមួយឆ្នាំនៃថ្លៃទំនិញប្រើប្រាស់នៅជប៉ុន មានកំណើន ០,៤% ធៀបនឹងការធ្លាក់ចុះ ០,៥% នៅត្រីមាសមុន ហើយផលិតផលឥន្ធនៈជាមូលហេតុចំបងនាំឱ្យមានកំណើននេះ ។ អតិផរណានៅថេរគួរសមក្នុងប្រទេសផ្សេងទៀតនៅអាស៊ី ។ ឧទាហរណ៍ នៅកូរ៉េខាងត្បូង និងសិង្ហបុរី អតិផរណាមានកំរិត ២,៤% និង ១,១% នៅត្រីមាសទី១ ឆ្នាំ២០០៦ ។

នៅត្រីមាសទី១ ២០០៦ ក្នុងទីផ្សារប្ដូរប្រាក់ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗ បន្ទាប់ពីការឡើងថ្លៃនៅត្រីមាសទី៤ ២០០៥ ។ ទល់នឹងប្រាក់យ៉េនជប៉ុន និងប្រាក់អឺរ៉ូ ដុល្លារUS ប្ដូរបាន ១១៤,៥យ៉េន/ដុល្លារ និង ០,៨០អឺរ៉ូ/ដុល្លារ ដោយធ្លាក់ថ្លៃពី ១១៧,២យ៉េន/ដុល្លារ និង ០,៨៤អឺរ៉ូ/ដុល្លារ នៅត្រីមាសទី៤ ២០០៥ ។ ទល់នឹងប្រាក់វ៉ុនកូរ៉េខាងត្បូង និងប្រាក់យ៉ុនចិន វាប្ដូរបាន ៩៧៦វ៉ុន/ដុល្លារ និង៨,០៥យ៉ុន/ដុល្លារ ដោយធ្លាក់ថ្លៃពី ១០៣៦វ៉ុន/ដុល្លារ និង ៨,០៨យ៉ុន/ដុល្លារ នៅត្រីមាសមុន ។ ការធ្លាក់ថ្លៃប្រាក់ដុល្លារUS ប្រហែលទទួលឥទ្ធិពលពីការរំពឹងទុកនៅទីផ្សារ ស្ដីពីគោលនយោបាយរូបិយវត្ថុនៅ US និងឱនភាពគណនីចរន្តរបស់ US ដែលឡើងខ្ពស់បំផុតនៅឆ្នាំ២០០៥ ។

## ថ្លៃផលិតផលនៅទីផ្សារពិភពលោក

នៅត្រីមាសទី១ ២០០៦ ថ្លៃអង្ករ ពោត ប្រេងឆា និងប្រេងឆៅ កើនឡើង រីឯ ថ្លៃស័ាំង ធ្លាក់ចុះ ។ ថ្លៃអង្ករ Thai 100%B លេខ២ នៅទីផ្សារបាងកក គឺ ២៧៥,១២ដុល្លារ/តោន ធៀបនឹង ២៥៩,៤០ដុល្លារ/តោន នៅត្រីមាសទី៤ ២០០៥ ។ ប្រេងឆាលក់បាន ៣៩៥,៧៧ដុល្លារ/តោន នៅត្រីមាសទី១

តារាង១. កំនើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 6.7 | 4.8 | 7 | 7.7 | - | - | - | - | - | 13.4 |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 6.4 | 5.5 | 5.3 | 4.9 | 4.6 | 5.6 |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7 | 5.7 | 4.4 | 5.3 | 5.2 | 5.3 | 5.2 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 2.5 | 5.4 | 7 | 7.7 | 10.7 | 5.7 |
| ថៃ | 1.9 | 6.1 | 6.9 | 6 | 3.3 | 4.6 | 5.3 | 4.7 | 6.0 | 4.5 |
| វៀតណាម | 6.0 | 6.7 | 7 | 7.5 | - | - | - | - | - | 8.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.5 | 9.5 | 9.4 | 9.9 | 10.9 | 9.6 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 2.7 | 7.3 | 8.2 | 7.6 | 8.2 | 6.5 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3 | 4.7 | 6 | 3.3 | 4.4 | 5.2 | 6.1 | 4.7 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | 2.7 | - | - | 6.0 | 4.9 | - |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.3 | 1.2 | 1.5 | 1.8 | 2.0 | 1.5 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 1.3 | 1.4 | 2.9 | 4.5 | 3.0 | 2.5 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 3.5 | 3.3 | 4.1 | 1.1 | 5.6 | 3.0 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*

២០០៦ រឺ កើន ១% ធៀបនឹងត្រីមាសមុន ។ ពោតលក់បាន ៩៥,៣៣ដុល្លារ/តោន រឺ កើន ៥% ធៀបនឹងត្រីមាសទី៤ ២០០៥ ។ ថ្លៃសណ្តែកសៀង នៅថេរ ដោយលក់បានដូចគ្នានឹងត្រីមាសមុន គឺ ២១០,៩៦ដុល្លារ/តោន ។ ថ្លៃប្រេងឆៅ នៅត្រីមាសទី១ ២០០៦ កើនឡើង ៩% រីឯ ថ្លៃសាំងធ្លាក់ចុះ ៣% ធៀបនឹងត្រីមាសទី៤ ២០០៥ ។ នៅត្រីមាសទី១ ប្រេងឆៅលក់បាន ៥៧,៨៩ដុល្លារ/ធុង រីឯសាំងលក់បាន ៤១,១៨សេន/លីត្រ ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភីម វុនស៊ីណារិទ្ធិ*

**តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៦ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.6 | 3.2 | 1.2 | 4.0 | 5.6 | 6.4 | 4.6 | 6.6 | 5.9 | 5.8 |
| ឥណ្ឌូនេស៊ី | 11.5 | 13.2 | 8.3 | 8.3 | 10.7 | 10.8 | 12 | 17.3 | - | 10.5 |
| ម៉ាឡេស៊ី | 1.4 | 1.8 | 1.1 | 1.6 | 2.5 | 3.0 | 3.4 | 3.4 | 3.9 | 3.1 |
| សិង្ហបុរី | 1.0 | -0.4 | 0.5 | 1.7 | 0.4 | 0.1 | 0.5 | 1.1 | 1.1 | 0.5 |
| ថៃ | 1.7 | 0.6 | 1.8 | 2.7 | 2.8 | 3.7 | 5.6 | 6.0 | 5.7 | 4.5 |
| វៀតណាម | -0.4 | 3.8 | 3.2 | 8.3 | 9.0 | 8.0 | 7.5 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.9 | -0.7 | 1.2 | 3.9 | 2.8 | 1.7 | 1.3 | 1.4 | 1.2 | 1.8 |
| ហុងកុង | -1.3 | -3.0 | -2.6 | -0.4 | 0.4 | 0.8 | 1.4 | 1.8 | 2.0 | 1.1 |
| កូរ៉េខាងត្បូង | 4.4 | 2.7 | 3.5 | 3.5 | 3.2 | 3.0 | 2.4 | 2.5 | 2.4 | 2.8 |
| តៃវ៉ាន់ | -0.01 | -0.2 | -0.3 | 1.6 | 1.6 | 2.1 | - | 2.4 | - | - |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.6 | 2.2 | 2.1 | 2.2 | 2.1 | 2.1 | 2.3 | 2.4 | 2.3 | 2.2 |
| ជប៉ុន | -0.6 | -0.9 | -0.3 | Nil | -0.2 | -0.1 | -0.3 | -0.5 | 0.4 | -0.3 |
| សហរដ្ឋអាមេរិក | 2.8 | 1.6 | 2.3 | 2.7 | 3.0 | 2.9 | 3.8 | 3.7 | 3.7 | 3.4 |

*Source: International Monetary Fund, Economist and National Institute of Statistics*

**តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៦ ( មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា ( រៀល) | 3,916.3 | 3,912.1 | 3,973 | 4,016.3 | 4,027.0 | 4,054.3 | 4134.3 | 4154.3 | - | 4,092.5 |
| ឥណ្ឌូនេស៊ី ( រ៉ូពីយ៉ា) | 10,261 | 9,311 | 8,577 | 8,938 | 9,274 | 9,550 | 9,994 | 9,999 | - | 9,705 |
| ម៉ាឡេស៊ី ( រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.77 | 3.78 | 3.73 | 3.79 |
| សិង្ហបុរី ( ដុល្លារសិង្ហបុរី) | 1.79 | 1.79 | 1.74 | 1.69 | 1.63 | 1.66 | 1.68 | 1.69 | 1.63 | 1.66 |
| ថៃ ( បាត) | 44.4 | 42.9 | 41.5 | 40.2 | 38.6 | 40.1 | 41.3 | 41.02 | 39.3 | 40.2 |
| វៀតណាម ( ដុង) | 14,725 | 15,280 | 15,510 | - | 15,809 | 15,842 | 15,878 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន ( យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.14 | 8.08 | 8.05 | 8.19 |
| ហុងកុង ( ដុល្លារហុងកុង) | 7.80 | 7.80 | 7.78 | 7.79 | 7.80 | 7.79 | 7.77 | 7.75 | 7.76 | 7.78 |
| កូរ៉េខាងត្បូង ( វ៉ុន) | 1,291 | 1,251 | 1,192 | 1,145 | 1,022 | 1,008 | 1,029 | 1,036 | 976 | 1,024 |
| តៃវ៉ាន់ ( ដុល្លារតៃវ៉ាន់-NT$) | 33.8 | 34.5 | 34.4 | 33.6 | 31.5 | 31.4 | 32.3 | 33.4 | 32.3 | 32.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ ( អឺរ៉ូ) | 1.12 | 1.06 | 0.89 | 0.80 | 0.76 | 0.79 | 0.81 | 0.84 | 0.80 | 0.80 |
| ជប៉ុន ( យ៉េន) | 121.5 | 125.4 | 115.9 | 108.2 | 104.7 | 107.4 | 111.2 | 117.2 | 114.5 | 110.2 |

*Source: International Monetary Fund and Economist and National Bank of Cambodia*

**តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០០-២០០៦ ( មធ្យមភាគតាមការិយបរិច្ឆេទ)**

| | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | |
| ពោត (US No. 2) - US ( $/តោន) | 81.18 | 89.98 | 95.42 | 110.65 | 87.98 | 87.53 | 90.61 | 90.64 | 95.37 | 89.19 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ( $/តោន) | 259.13 | 353.91 | 402.03 | 427.47 | 374.86 | 382.48 | 376.41 | 391.52 | 395.75 | 381.32 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 602.0 | 768.3 | 1050 | 1252.2 | - | - | - | - | - | - |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 160.81 | 178.59 | 182.22 | 221.67 | 268.11 | 268.20 | 255.77 | 259.40 | 275.12 | 262.88 |
| សណ្តែកសៀង (US No. 1) – US ( $/តោន) | 163.89 | 182.58 | 218.86 | 262.03 | 208.52 | 263.66 | 214.37 | 210.42 | 210.96 | 224.25 |
| ប្រេងឆៅ-ឌូបៃ ( $/ធុង) | 22.8 | 23.9 | 26.8 | 33.5 | 42.6 | 47.7 | 57.27 | 52.99 | 57.89 | 50.14 |
| សាំង – US Gulf coast ( សេន/លីត្រ) | 19.5 | 19.1 | 23 | 30.9 | 34.4 | 39.7 | 52.37 | 42.29 | 41.18 | 42.19 |

*Sources: Food and Agriculture Organisation and US Energy Information Administration.*
*Note: All prices have been converted from US$/ton to US$/tonne, which 1 ton = 0.907 tonne.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សេចក្ដីផ្ដើម

ធនាគារពិភពលោក បានធ្វើចំណាត់ថ្នាក់កម្ពុជាជា ប្រទេសមានចំណូលទាប នៅតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក យោងតាមលទ្ធផលសេដ្ឋកិច្ចក្នុងពេលថ្មីៗ ។ នៅកំឡុងឆ្នាំ២០០១-២០០៥ ផសស ពិត មានអត្រាកំណើនជាមធ្យម ១១,២% និងអត្រាកំណើនគិតក្នុងមនុស្សម្នាក់ ៩,៣% ។ នេះជាលទ្ធផលសេដ្ឋកិច្ចដ៏ល្អមួយ ធៀបនឹងកំណើនពិតជាមធ្យម ៣,0% នៅកំឡុងឆ្នាំ ១៩៩៧-២០០១ ។

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ ២០០៦ វិនិយោគឯកជន និងទេសចរណ៍ មានចំណែកយ៉ាងធំនៅក្នុងសេដ្ឋកិច្ចកម្ពុជា រីឯវិស័យសាងសង់ និងពាណិជ្ជកម្មក្រៅប្រទេសមានការធ្លាក់ចុះ បើធៀបនឹងត្រីមាសមុន ។

វិនិយោគឯកជនសរុបក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម បានរីកចំរើនលូតលាស់នៅក្នុងត្រីមាសនេះ ដោយសារការពង្រីកគំរោង បន្ទាប់ពីមានកំណើន ផសស កំរិតខ្ពស់នៅឆ្នាំ២០០៥ (អត្រាចារិក ១៩,៩% និងអត្រាពិត ១៣,៤%) ដែលបានទាក់ទាញវិនិយោគិន ប៉ុន្តែកំណើននេះមិនរំពឹងថា នឹងបន្តបានយូរទេ ។ ការអនុមតិវិនិយោគឯកជន គិតជាទ្រព្យសកម្មជាប់លាប់ កើនដល់ ៩១% ដល់ ២២៧,៣លានដុល្លារ នៅត្រីមាសទី១ ។ បើតាមទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា (CDC) ការអនុមតិវិនិយោគខាងកសិកម្ម គិតជាទ្រព្យសកម្មជាប់លាប់បានចុះបញ្ជី មាន ១២៦,៥លានដុល្លារ នៅត្រីមាសទី១ រឺកើនជិតដល់ ១៣ដង ធៀបនឹងត្រីមាសមុន ។ វិនិយោគក្នុងវិស័យសេវាកម្ម កើនទ្វេមួយជាពីរ ដល់ ៦0,៧លានដុល្លារ រីឯវិនិយោគខាងឧស្សាហកម្ម បានធ្លាក់ចុះអស់ ៥១% ពី ៨២,0លានដុលារ មកដល់ត្រឹម ៤0,១លានដុល្លារ ។ម្យ៉ាងវិញទៀត នៅត្រីមាសទី១ ២០០៦ ការអនុមតិគំរោងវិនិយោគឯកជន សរុបគិតជាទ្រព្យសកម្មជាប់លាប់ រួមទាំងគំរោងពង្រីកបន្ថែមផង បានធ្លាក់ចុះមកដល់ ៥២% ពីកំរិត ៤៧៥,៣លានដុល្លារ នៅត្រីមាសដូចគ្នា ឆ្នាំ២០០៥ (នៅឆ្នាំនោះកំណើនកើតចេញពីវិនិយោគខាងឧស្សាហកម្ម) ។ ប៉ុន្តែកំណើនវិនិយោគឯកជន បានជួយដល់សេដ្ឋកិច្ចកម្ពុជា ក្នុងត្រីមាសនេះ ។

ជាច្រើនឆ្នាំកន្លងទៅ ទេសចរណ៍កើនឡើងជាប់ជានិច្ច ។កម្ពុជាទាក់ទាញភ្ញៀវទេសចរបរទេសបានកាន់តែច្រើន ដោយសារសៀមរាប (អង្គរ) កាន់តែមានគេស្គាល់ច្រើន ស្ថានភាពសន្តិសុខក៏មានស្ថិរភាព ហើយហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ក៏ប្រសើរជាងមុន។ នៅត្រីមាសទី១ ២០០៦ ភ្ញៀវមកដល់កម្ពុជា មានសរុប ៤៥៧.៣00នាក់ រឺកើន ៩,៩% ធៀបនឹងត្រីមាសមុន និងកើន ២0% ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ។ ក្នុងនោះ ៨៨% (៤00.៤១៧នាក់) មកសំរាកលំហែរិសមកាល ហើយ ៥,៦% (២៥.៣៨៦នាក់) មកធ្វើការងារផ្លូវការរដ្ឋ និងកិច្ចការជំនួញ ។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលភ្ញៀវបរទេស ១0៣.២0៣នាក់ នៅត្រីមាសទី១ (ធៀបនឹង ១១៧.៥១៦នាក់ នៅត្រីមាសមុន) រីឯអាកាសយានដ្ឋានអន្តរជាតិសៀមរាប ទទួលភ្ញៀវកើនឡើង ២៩% ដល់ ១៧២.១៨៨នាក់ ធៀបនឹង ១៣៣.៩៨៤នាក់ នៅត្រីមាសទី៤ ២០០៥ ។ ភ្ញៀវមកតាមផ្លូវគោក និងផ្លូវទឹក កើន ១១% ដល់ ១៨១.៩00នាក់ ក្នុងនេះ ៩៣% មកតាមផ្លូវគោក (ធៀបនឹង ៩៥% នៅ ត្រីមាសមុន) ។ កូរ៉េ ជាប្រភពភ្ញៀវច្រើនជាងគេបង្អស់ គឺ ១00.១៨៧នាក់ រឺ ២២% នៃភ្ញៀវចូលសរុប បន្ទាប់មកគឺ ជប៉ុន (៤៣.៦១៧នាក់) និងសហរដ្ឋអាមេរិក (៣៣.៤0៤នាក់) ។

ជនចំណាកស្រុកចូល គិតទាំងអ្នកចូលមកពីប្រទេសក្រៅផង បានបង្កើនចំនួនប្រជាជននៅភ្នំពេញ ។ កំនើនប្រជាជន គួបនឹងកំនើនសេដ្ឋកិច្ចកំរិតខ្ពស់ នាំឱ្យមានកំណើនសកម្មភាពសាងសង់នៅភ្នំពេញ ក្នុងជាច្រើនឆ្នាំកន្លងមកនេះ ។ ប៉ុន្តែ នៅត្រីមាសទី១ វិស័យសាងសង់នៅភ្នំពេញបានបន្តនិន្នាការធ្លាក់ចុះ ដែលបានចាប់ផ្ដើមតាំងពីត្រីមាសទី២ ២០០៥ ។ គេហាក់ពិនិត្យឃើញថា គំរោងសាងសង់ដែលអនុម័តពីមុន បានអនុវត្តរួចហើយ ប៉ុន្តែសន្ទុះកំនើននោះ មិនអាចរក្សាបានជាបន្តមកទៀតទេ ។ យោងតាមទិន្នន័យពីនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រក្រុងភ្នំពេញ ការអនុមតិគំរោងសាងសង់មាន ៦៧,៣លានដុល្លារ រឺ ធ្លាក់ចុះ ៦,៣% ធៀបនឹងកំរិត ៧១,៨លានដុល្លារ នៅត្រីមាសមុន និងធ្លាក់ចុះយ៉ាងខ្លាំងធៀបនឹងកំរិត ១0៦,១លានដុល្លារ នៅត្រីមាសដូចគ្នា ឆ្នាំ២០០៥ ។ ការអនុមតិសំណង់ផ្ទះល្វែងគឺ ៣៩,៩លានដុល្លារ រឺ ១២% ទាបជាងនៅត្រីមាសមុន ហើយការអនុមតិសំណង់ផ្សេងៗ ធ្លាក់ចុះ ១៨% មកត្រឹម ១៧,៤លានដុល្លារ ប៉ុន្តែការអនុមតិសំណង់ភូមិគ្រឹះ និងផ្ទះកើនជិតទ្វេដងពី ៥,៤លានដុល្លារ ដល់ ១0,១លានដុល្លារ ។ នៅឆ្នាំ២០០៥ សកម្មភាពសាងសង់នៅភ្នំពេញ កើនឡើង ៣៦% ដល់ ៣៥៨,៨លានដុល្លារ ធៀបនឹង ២៦៣,៤លានដុល្លារ នៅឆ្នាំ២០០៤ ។ កំណើននេះនាំមុខគេដោយសំណង់ផ្ទះល្វែង ដែលមានតំលៃដល់ ២0៤,២លានដុល្លារ និងដែលនៅតែនាំមុខគេក្នុងកំឡុងពេលនេះទៀត ។

ក្នុងកំឡុងពេលនេះដែរ ការអនុមតិគំរោងសាងសង់នៅភ្នំពេញធ្លាក់ចុះ រីឯវិនិយោគឯកជន និងវិស័យទេសចរណ៍ កើនឡើង ។ ម្យ៉ាងទៀត ឱនភាពពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា បានកើនដល់ ៨៧,៥លានដុល្លារ ធៀបនឹង ៤៦,៣លានដុល្លារ នៅត្រីមាសមុន បន្ទាប់ពីមាន អតិរេក ៩៧,៧លានដុល្លារ នៅត្រីមាសទី៣ ឆ្នាំ២០០៥ ។ នៅត្រីមាសទី១ ២០០៦ ទោះបីការនាំចូលបានធ្លាក់ចុះ ប៉ុន្តែការនាំចេញសរុប ក៏ធ្លាក់ចុះអស់ ៦,៥% ដែរ មកត្រឹម ៦0៣,២លានដុល្លារ ដែលផ្ទុយពីកំណើន ៣0% នៅត្រីមាសដូចគ្នាឆ្នាំមុន ។ ក្នុងចំណោមផលិតផលនាំចេញចំបងៗ ការនាំចេញសំលៀកបំពាក់ ធ្លាក់ចុះអស់ ៥,៤% ពី ៦0១,0លានដុល្លារ មកត្រឹម ៥៦៨,៥លានដុល្លារ ក្នុងនេះ ការនាំចេញសំលៀកបំពាក់ទៅសហរដ្ឋអាមេរិក និងអឺរ៉ុបបានធ្លាក់ចុះអស់ ១,៤% និង ២៤% ។ ការនាំចេញកៅស៊ូ ធ្លាក់ចុះ ៤២% មកត្រឹម ៧,៨លានដុល្លារ ការនាំចេញត្រីចុះអស់ ៧១% មកត្រឹម ១,៩លានដុល្លារ ប៉ុន្តែ ការនាំចេញឈើ និងផលិតផលផ្សេងទៀត កើនបាន ៥,0% និង ៤,៦% ។ កំនើនការនាំចេញ អាចផ្ដល់ចំនូលបន្ថែមដល់កម្ពុជា ប៉ុន្តែនៅត្រីមាសទី១ ការនាំចេញតែងតែធ្លាក់ចុះ ដោយសារកត្តារដូវកាល ពីព្រោះសំលៀកបំពាក់មួយភាគធំលក់ទៅបណ្ដាប្រទេសខាងជើង ដែលមានរដូវទិញដូរចំបងនៅត្រីមាសទី៣ និង ទី៤ ។ តាមធម្មតាការនាំចេញសំលៀកបំពាក់ តែងជាកត្តាកំនត់ចំពោះលទ្ធផលការនាំចេញ ។ ការនាំចេញផលិតផលកសិកម្ម ក៏ពាក់ព័ន្ធនឹងកត្តារដូវកាលដែរ ហើយមូលហេតុមួយនៃការធ្លាក់ចុះ គឺការបង្វែរផលិតផលទៅតាមច្រក "មិនផ្លូវការ" ពោលគឺការលក់ដូរដោយផ្ទាល់នូវផលិតផលកសិកម្មក្នុងតំបន់ព្រំដែន ទៅឱ្យឈ្មួញនៅប្រទេសជិតខាង ដែលជួនកាលប្រជាជនអាចលក់បានថ្លៃជាងតាមវិធីនេះ ។

នៅត្រីមាសទី១ ២០០៦ ការនាំចូលសរុបដែលរាយការណ៍ឡើងដោយទីចាត់ការគយនិងរដ្ឋាករ ស្ទើរគ្មានការប្រែប្រួលដោយមានតំលៃសរុប

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

៦៩០,៧លានដុល្លារ ធៀបនឹង ៦៩១,១លានដុល្លារនៅត្រីមាសទី៤ ២០០៥ ។ ការនាំចូលម្ហូបអាហារ និងក្រណាត់ ធ្លាក់ចុះអស់ ១,0% និង ៩,0% មកត្រឹម ១0,0លានដុល្លារ និង ២,0លានដុល្លារ ។ ការនាំចូលសាំង និងម៉ាស៊ូត កើន ១,៩% និង ៥៤% ដល់ ១0,៩លានដុល្លារ និង ៣២,៥លានដុល្លារ (ស្មើនឹងសាំង ៣៤.៧៥៥តោន និងម៉ាស៊ូត ១១៥.៨២0តោន ធៀបនឹងកំរិត ៣៤.៤៥៦តោន និង ៧៦.៦៤៥តោន នៅត្រីមាសទី៤ ២០០៥) ។ ការនាំចូលសំភារៈសំណង់ កើន ៤១% ដល់ ៣៧,0លានដុល្លារ ធៀបនឹង ២៦,២លានដុល្លារ នៅត្រីមាសមុន ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ២០០៦ ឱនភាពថវិកាជាទូទៅរបស់រដ្ឋ មានសភាពកាន់តែធ្ងន់ធ្ងរ ។ តាមទិន្នន័យបានកែតំរូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱនភាពថវិកាទូទៅ កើនដល់ ២៥៩,៨ពាន់លានរៀល ធៀបនឹង ១៧១,0ពាន់លានរៀលនៅត្រីមាសមុន និង ១៥៤,៧ពាន់លានរៀល នៅត្រីមាសដូចគ្នាឆ្នាំ២០០៥ ។ ចំណាយថវិកា និងចំណូលថវិការដ្ឋ បានថយចុះដូចគ្នា ប៉ុន្តែការថយចុះចំណាយ វាមិនធំគ្រប់គ្រាន់អាចជួយកែលំអដល់តុល្យភាពថវិការដ្ឋបានទេ ។ ចាប់តាំងពីត្រីមាសទី២ ២០០៥ ចំណូល និងចំណាយថវិការដ្ឋបានកើនឡើង ប៉ុន្តែវាធ្លាក់ចុះវិញនៅត្រីមាសនេះ ។

ការធ្លាក់ចុះការនាំចូល-នាំចេញ នាំឱ្យការប្រមូលពន្ធនាំចូលនាំចេញធ្លាក់ចុះដែរ ។ ចំណូលសរុប ដែលមានចំណូលពន្ធ ចំណូលមិនមែនពន្ធ និងចំណូលមូលធន ធ្លាក់ចុះអស់ ២៨% មកត្រឹម ៥៩៥,៩ពាន់លានរៀល ធៀបនឹង ៨២៧,៨ពាន់លានរៀល នៅត្រីមាសមុន ។ ចំណូលពន្ធធ្លាក់ចុះអស់ ១៣% មកត្រឹម ៤៨៤,៧ពាន់លានរៀល ដែលនាំមុនគេដោយការធ្លាក់ចុះអាករលើតំលៃបន្ថែម (VAT) អាករពិសេស និងពន្ធគយ ។ ម្យ៉ាងទៀត ចំណូលខាងប្រៃសណីយ៍ និងទូរគមនាគមន៍ ធ្លាក់ចុះអស់ ៧0% ពី ៣៨,0ពាន់លានរៀល មកត្រឹម ១១,៤ពាន់លានរៀល ហើយចំណូលពីអាកាសចរណ៍ស៊ីវិល ធ្លាក់ចុះអស់ ៩៥% មកត្រឹម 0,៤ពាន់លានរៀល ។ ចំណូលមូលធនក្នុងស្រុក ដែលបានពីការធ្វើឯកជនភាវូបនីយកម្ម និងប្រភពផ្សេងទៀត បានធ្លាក់ចុះយ៉ាងខ្លាំង មកត្រឹម ២,៧ពាន់លានរៀល ធៀបនឹង ១២៦,៣ពាន់លានរៀល នៅត្រីមាសមុន ។ ពីខែមករា ដល់ មីនា ២០០៦ ចំណូលថវិកាសរុប សំរេចបាន ២១% នៃផែនការក្នុងច្បាប់ថវិកាឆ្នាំ២០០៦ (២៨១២,៧ពាន់លានរៀល) ធៀបនឹងកំរិត ២៤% ក្នុងកំឡុងពេលដូចគ្នាឆ្នាំ២០០៥ (២២៩៨,៦ពាន់លានរៀល) ។ ចំណូលសរុប ឆ្នាំ២០០៥ (រយៈ ១២ខែ) សំរេចបាន ១១៤% នៃផែនការ (២៦២៥,៣ពាន់លានរៀល) ។ ចំនួលនេះចាំបាច់បំផុតសំរាប់សងបំណុលរដ្ឋ និងសំរាប់ដោះស្រាយចំណាយសាធារណៈ ។ ក្នុងករណីនេះ ចំណូលបានថយចុះ និងបានកាត់បន្ថយសមត្ថភាពសងបំណុល នឹងដោះស្រាយថវិកាសំរាប់ចំណាយសាធារណៈ ។

ក្នុងរយៈពេលនេះដែរ ចំណាយខាងអប់រំ និងសុខាភិបាល បានថយចុះ រីឯចំនាយខាងការពារជាតិ និងសន្តិសុខ កើនឡើងបន្តិច ។ នៅត្រីមាសទី១ ២០០៦ ចំណាយរបស់រដ្ឋ រួមទាំងការកែតំរូវចំណាយផង មានកំរិត ១៤% តិចជាងត្រីមាសមុន ដែលមានដល់ ៨៥៥,៦ពាន់លានរៀល ។ ចំណាយចរន្តគិតលើមូលដ្ឋានសាច់ប្រាក់ ធ្លាក់ចុះ ៩,២% មកត្រឹម ៥៨៨,៨ពាន់លានរៀល ហើយចំណាយមូលធន ធ្លាក់ចុះអស់ ២៤% ។ ចំណាយខាងអប់រំ និងសុខាភិបាល ធ្លាក់ចុះយ៉ាងខ្លាំងអស់ ៦៥% រីឯចំណាយខាងការពារជាតិ និងសន្តិសុខ កើន ៩,៤% ធៀបនឹងត្រីមាសមុន ។ ចំណាយចរន្តខាងសេវាកម្មសាធារណៈផ្សេងទៀត ក៏កើនឡើងដែរ ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ចំណាយថវិកាសរុបកើន ២១% ពីកំរិត ៧0៦,៣ពាន់លានរៀល ។ ការថយចុះហិរញ្ញប្បទានបរទេស (ចុះ ៣២%) បានធ្វើឱ្យធ្លាក់ចុះចំណាយមូលធន ។

## អតិផរណា និងអត្រាប្តូរប្រាក់

តាមទិន្នន័យប្រចាំខែចេញផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ទូទៅនៅភ្នំពេញ នៅត្រីមាសទី១ ២០០៦ កើន ៦,១% ធៀបនឹងមួយឆ្នាំមុន ។ នៅត្រីមាសមុន អត្រាកំណើនប្រចាំឆ្នាំគឺ ៦,៦% ។ ធៀបនឹងត្រីមាសទី៤ ២០០៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់ប្រភេទ ធ្លាក់ចុះ 0,២% ក្នុងនេះ ថ្លៃម្ហូបអាហារធ្លាក់ចុះ ១,0% រីឯថ្លៃទំនិញប្រើប្រាស់ចំបងផ្សេងទៀត ដូចជា ការដឹកជញ្ជូននិងទូរគមនាគមន៍ ការថែទាំសុខភាព ផលិតផលថែទាំកាយ ការអប់រំ លំហែកំសាន្ត សំភារៈប្រើប្រាស់ក្នុងផ្ទះ សំលៀកបំពាក់ និងស្បែកជើង កើនតិចតួច ។ ថ្លៃម្ហូបអាហារ កើន ១១% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៥ ដែលស្មើនឹងកំណើននៅត្រីមាសមុន និងខ្ពស់ជាងកំណើន ៧,៩% នៅត្រីមាសទី១ ឆ្នាំមុន ។ ថ្លៃដឹកជញ្ជូន កើន ៩,៧% ធៀបនឹងឆ្នាំ ២០០៥ រីតិចជាងកំណើន ១0% នៅត្រីមាសមុន ។ ក្នុងត្រីមាសនេះ ការឡើងថ្លៃទំនិញប្រើប្រាស់សំខាន់ៗ ធ្វើឱ្យអ្នកក្រ មានជីវភាពកាន់តែលំបាកថែមទៀត ។ ដូច្នេះកំនើនអតិផរណា វាប៉ះពាល់ជាពិសេសដល់ជីវភាពអ្នកក្រ និងអ្នកមានចំនួលទាប ។

ប្រាក់រៀល ប្តូរបាន ៤0៩៤,៨រៀល/ដុល្លារ រឺឡើងថ្លៃ ១,៥% ធៀបនឹងត្រីមាសមុន ។ ប្រាក់រៀលឡើងថ្លៃ ២,៧% ទល់នឹងប្រាក់ដុងវៀតណាម ដោយប្តូរ ២៥,៤រៀល/១០០ដុង ប៉ុន្តែធ្លាក់ថ្លៃទល់នឹងប្រាក់បាតថៃ ដោយប្តូរ ១0៣,៥រៀល/បាត ធៀបនឹង ១0១,៤រៀល/បាតនៅត្រីមាសមុន ។

## ការវិវត្តន៍រូបិយវត្ថុ

តាមអង្កេតហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា រូបិយវត្ថុទូទៅ (M2) នៅចុងត្រីមាសទី១ ២០០៦ កើនបាន ១៤% ដល់ ៥៧១១,0ពាន់លានរៀល (១៣៩២,៩លានដុល្លារUS) ធៀបនឹងត្រីមាសមុន ។ រឿងនេះ បណ្តាលមកពីកំណើនបញ្ញើជារូបិយវត្ថុបរទេស ១៦% ដល់ ៤១៤៦,0ពាន់លានរៀល (១0១១,0លានដុល្លារ) និងកំណើនប្រាក់រៀលក្រៅធនាគារ ៩,៥% ឡើងដល់ ១៤0៣,៥ពាន់លានរៀល (៣៤២,៣លានដុល្លារ) ។ ព្រមជាមួយគ្នា ប្រាក់រៀលក្នុងធនាគារ ដែលរួមមានប្រាក់បញ្ញើចរន្ត ប្រាក់បញ្ញើមានកាលកំណត់ និងប្រាក់បញ្ញើសន្សំ កើន ៥,១% ដល់ ១៦១,0ពាន់លានរៀល (៣៩,៣លានដុល្លារ) ។

រូបិយវត្ថុទូទៅ កើនបាន ៧២% ពីកំរិត ៣៣២៩,0ពាន់លានរៀល (៨១២,0លានដុល្លារ) នៅកំឡុងពេល ១២ខែ ។ សមាសភាគប្រាក់រៀល កើន ៥៤% ក្នុងនេះ ប្រាក់រៀលក្រៅធនាគារកើនបាន ៥៥% ។ នៅពេលជាមួយគ្នា បញ្ញើជារូបិយវត្ថុបរទេស កើន ៨0% ។ គ្រោះថ្នាក់នៃការផ្គត់ផ្គង់រូបិយវត្ថុច្រើនគឺ កំណើនអតិផរណា ពីព្រោះមានលុយច្រើនពេកសំរាប់ដោះស្រាយតំរូវការទំនិញនៅលើទីផ្សារ ។ ម្យ៉ាងទៀត កំណើនបញ្ញើជារូបិយវត្ថុបរទេស បង្ហាញពីទំនុកចិត្តកាន់តែខ្ពស់ទៅលើវិស័យធនាគារ និងគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ការប្រាក់លើកំចីជាដុល្លារ នៅថេរក្នុងពេលកន្លងមក ។ បច្ចុប្បន្ន វាមាន

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

កំរិត ១៦,៤%/ឆ្នាំ ធៀបនឹង ១៦,៧%/ឆ្នាំ នៅឆ្នាំ២០០៤ ។ អត្រាការប្រាក់សំរាប់បញ្ញើជាដុល្លារ ក៏មានស្ថិរភាពដែរ ប្រហែល ៣,៩% ។ នៅត្រីមាសនេះឥណទានសំរាប់វិស័យឯកជនកើន ១៦% ដល់ ២៧៧៨,០ពាន់លានរៀល រីឯឥណទេយ្យសុទ្ធលើរដ្ឋាភិបាល ធ្លាក់ចុះដល់ ៤៥៦,០ពាន់លានរៀល រឺថយចុះ ៤៩% ធៀបនឹងត្រីមាសទី៤ ២០០៥ ដោយសារកំណើនបញ្ញើរបស់រដ្ឋាភិបាល ក្នុងធនាគារ ។ ពិតណាស់ កំណើនឥណទានសំរាប់វិស័យឯកជនវាផុសចេញពីកំណើនសេដ្ឋកិច្ចរឹងប៉ឹង និងបរិយាកាសអត្រាការប្រាស់មានស្ថិរភាព ។ អប្បហារការប្រាក់របស់ធនាគារ (គឺ ផលដករវាងអត្រាការប្រាក់លើប្រាក់ឱ្យខ្ចី និងប្រាក់បញ្ញើ) នៅខ្ពស់នៅឡើយ ដល់ទៅ ១២,៥% ។ អប្បហារ ចុះទាបជាងនេះ នឹងជំរុញឱ្យមានការផ្តល់កំចីកាន់តែច្រើន ហើយវិស័យឯកជន នឹងមានសកម្មភាពសេដ្ឋកិច្ចកាន់តែខ្លាំង ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

យោងតាមអង្កេតលើពលករងាយរងគ្រោះ ១០ក្រុម ធ្វើឡើងដោយ វបសអ នៅខែឧសភា ចំណូលប្រចាំថ្ងៃពិតជាមធ្យមធ្លាក់ចុះអស់ ៩,៦% ធៀបនឹងពេលដូចគ្នាឆ្នាំ២០០៥ ។ ចំណូលរបស់អ្នកលក់បន្លែតូចតាច អ្នករើសសំរាម អ្នកបំរើតាមភោជនីយដ្ឋាន អ្នករត់ម៉ូតូឌុប កម្មករគ្មានជំនាញ និងកម្មករសំណង់មានជំនាញ បានធ្លាក់ចុះ រីឯចំណូលរបស់ ៤ ក្រុមផ្សេងទៀត មានអ្នកធាក់ស៊ីក្លូ អ្នកលីសែង កម្មករធ្វើស្រែ និងកម្មករកាត់ដេរ បានកើនឡើង ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ២៣,១% មកត្រឹម ៨.៨០០រៀល ធៀបនឹង ១១.៤០០រៀល នៅខែឧសភា ២០០៥ ប៉ុន្តែ វាមានលក្ខណៈស្រដៀងគ្នានឹងអង្កេតនៅខែកុម្ភៈ ឆ្នាំនេះ ។ ក្នុងអង្កេតនេះ អ្នករត់ម៉ូតូឌុប ៦៨% បានរាយការណ៍ពីការធ្លាក់ចុះចំណូល ១៨% រាយការណ៍ថា គ្មានការប្រែប្រួល និង ១៥% ថាចំណូលកើនឡើង ។ អង្កេតនេះបង្ហាញពីផលប៉ះពាល់នៃការ ឡើងថ្លៃសាំងដល់ ៤.១០០រៀល/លីត្រ នៅខែឧសភា រឺកំណើន ១៩% ធៀបនឹងពេលដូចគ្នាឆ្នាំមុន ។ អ្នករត់ម៉ូតូឌុប ចំណាយពេលប្រហែល ២៤ថ្ងៃ/ខែ និងប្រហែល ១០ម៉ោង/ថ្ងៃ ក្នុងការរត់ម៉ូតូ ហើយពួកគេចំណាយប្រាក់ជាមធ្យម ៤.២០០រៀល/ថ្ងៃលើម្ហូបអាហារ ។ អ្នករត់ម៉ូតូឌុប ៦៣% ត្រូវជួលកន្លែងស្នាក់នៅ ពីព្រោះពួកគេជាជនចំណាកស្រុកមកពីខេត្ត ដើម្បីរកការងារធ្វើនៅភ្នំពេញ ។

ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ២០,២% មកត្រឹម ៩.៨០០រៀល នៅខែឧសភា ឆ្នាំ២០០៦ ធៀបនឹង ១២.៣០០រៀល នៅពេលដូចគ្នាឆ្នាំ២០០៥ ហើយនេះជាតួលេខទាបបំផុតសំរាប់កម្មករសំណង់មានជំនាញ គិតចាប់តាំងពីពេលធ្វើអង្កេតដំបូង នៅឆ្នាំ២០០០ ។ ប៉ុន្តែ មូលហេតុនាំឱ្យចំណូលធ្លាក់ចុះ គេមិនអាចដឹងច្បាស់ទេ ពីព្រោះរបៀបរបបអង្កេតនេះ ធ្វើឱ្យលំបាកក្នុងការរកជួបកម្មករឈ្មោះដដែលដើម្បីសំភាសគាត់ជាថ្មីទៀត ។ ទោះយ៉ាងនេះក្តី កម្មករសំណង់មានជំនាញ ៧៨% បញ្ជាក់ថា ចំនួនកម្មករបានកើនឡើង ។ រឿងនេះមានច្រើន ជាពិសេសចំពោះកម្មករគ្មានជំនាញដែលក្លាយជាមានជំនាញ ក្រោយពីបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយកម្មករសំណង់មានជំនាញមួយពេលយូរមក ។ ក្នុងអង្កេតនេះ ៣៥% នៃកម្មករសំណង់បានសំភាសន៍ ជាអ្នកនៅលីវ ហើយភាគច្រើនមានអាយុតិចជាង ២៥ឆ្នាំ ។ កម្មករមានជំនាញភាគច្រើនជាជនចំណាកស្រុកបណ្តោះអាសន្នមកពីតំបន់ជនបទ ។

ចំពោះកម្មករគ្មានជំនាញ នៅខែឧសភា ២០០៦ ចំណូលប្រចាំថ្ងៃពិតធ្លាក់ចុះ ២១% ធៀបនឹងនៅកំឡុងពេលដូចគ្នាឆ្នាំ២០០៥ ប៉ុន្តែកើន ៧% ធៀបនឹងអង្កេតលើកមុន នៅខែកុម្ភៈ ។ កម្មករគ្មានជំនាញភាគច្រើនត្អូញត្អែរថា ចំណូលរបស់ពួកគេគ្មានស្ថិរភាព ដូច្នេះពួកគេមិនអាចសន្សំប្រាក់បានច្រើនសំរាប់ផ្ញើទៅផ្ទះទេ ។ ជាទូទៅ ពួកគេធ្វើការបានប្រហែល ១៥ថ្ងៃ នៅខែឧសភា ២០០៦ និងប្រហែល ៧ម៉ោង/ថ្ងៃ ។ ប្រហែល ៥០% នៃកម្មករគ្មានជំនាញ មានអាយុតិចជាង ២៥ឆ្នាំ ហើយ ៧៥% ធ្លាប់បានចូលរៀនបឋមសិក្សា ២០% ធ្លាប់បានរៀននៅមធ្យមសិក្សា និង ៥% ទៀតមិនបានរៀនសោះ ។

> *កម្មករគ្មានជំនាញភាគច្រើន ត្អូញត្អែរថា ចំណូលរបស់ពួកគេគ្មានស្ថិរភាព ដូច្នេះពួកគេមិនអាចសន្សំប្រាក់បានច្រើនសំរាប់ផ្ញើទៅផ្ទះទេ ។ ជាទូទៅ ពួកគេធ្វើការបាន ប្រហែល ១៥ថ្ងៃ នៅខែឧសភា ឆ្នាំ២០០៦ និងប្រហែល ៧ម៉ោង/ថ្ងៃ ។ ប្រហែល ៥០% នៃកម្មករគ្មានជំនាញ មាន អាយុតិចជាង ២៥ឆ្នាំ ហើយ ៧៥% ធ្លាប់បានចូលរៀនបឋមសិក្សា ២០% ធ្លាប់បានរៀននៅមធ្យមសិក្សា និង ៥% ទៀត មិនបានរៀនសោះ ។*

នៅខែឧសភា ចំណូលប្រចាំថ្ងៃពិតរបស់អ្នកលក់បន្លែតូចតាច ធ្លាក់ចុះ ២៤,៣% មកត្រឹម ៦.៥០០រៀល ធៀបនឹង ៨.៦០០រៀល នៅកំឡុងពេលដូចគ្នាឆ្នាំ២០០៥ ។ ចំណូលវាធ្លាក់ចុះដោយសារថ្លៃបន្លែគ្មានស្ថិរភាព និងកំណើនចំនួនអ្នកលក់បន្លែ ។ អ្នកលក់បន្លែបានឆ្លើយសំភាសន៍ ៨២% រាយការណ៍ថា ចំនួនអ្នកលក់បន្លែកើនឡើង ដោយសារអ្នកលក់បន្លែត្រាច់ចរពីខេត្តកណ្តាល និងកំពង់ស្ពឺ ដែលមករកស៊ីនៅភ្នំពេញ ពីព្រោះមានលក្ខខណ្ឌមិនអំណោយផលនៅភូមិស្រុករបស់ពួកគេ ។ អ្នកលក់បន្លែភាគច្រើន ត្រូវចំណាយពេលយ៉ាងច្រើននៅឯទីផ្សារ រួមទាំងការក្រោកពីដំណេកនៅម៉ោង៣ព្រឹក ដើម្បីទៅទិញបន្លែសំរាប់លក់ផង ។ អ្នកលក់តូចតាច ប្រមាណ ៨៥% និយាយថា ក្នុងកំរិតចំណូលនេះ ពួកគេមិនអាចសន្សំអ្វីសំរាប់ពង្រីកការរកស៊ីបានទេ ។ អង្កេត ក៏បង្ហាញដែរថា មានក្មេងស្រីជាច្រើន អាយុពី ១០ ទៅ ១៥ឆ្នាំ ទូលកញ្ច្រែង ផ្លែឈើ និងបន្លែ ដើរលក់ ។ តាមសំភាសន៍មិនផ្លូវការជាមួយក្មេងស្រីទាំងនេះ បានរកឃើញថា ពួកគេរកបានពី ១.៥០០រៀល ទៅ ២.០០០រៀលក្នុងមួយថ្ងៃ ប៉ុន្តែ អ្នកខ្លះត្រូវចំណាយពេលកន្លះថ្ងៃ និងខ្លះទៀតពេញមួយថ្ងៃ ដើម្បីជួយការងារក្នុងគ្រួសារ ។ ក្មេងស្រីលក់បន្លែខ្លះនិយាយថា ជាទូទៅ ពួកគេធ្វើការរកស៊ី ក្រោយពេលចប់ម៉ោងនៅសាលារៀន ប៉ុន្តែ ខ្លះទៀតត្រូវធ្វើដំណើរចេញពីភូមិកំណើតជាមួយគ្រួសារតាំងពីព្រលឹមរាល់ថ្ងៃ ដូច្នេះហើយត្រូវតែឈប់រៀន ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសសំរាម នៅខែឧសភា ធ្លាក់ចុះ ១៤,៤% មកត្រឹម ៤.៥០០រៀល ធៀបនឹង ៥.៣០០រៀល នៅខែដូចគ្នា ឆ្នាំ២០០៥ ។ តាំងពីដើមឆ្នាំ២០០៦ ចំណូលប្រចាំថ្ងៃរបស់អ្នករើសសំរាម បន្តធ្លាក់ចុះរហូត ហើយនៅខែឧសភា អ្នកឆ្លើយសំភាសន៍ ៩២% លើកឡើងថា ចំណូលរបស់ពួកគេបានធ្លាក់ចុះ និង ៨% ផ្សេងទៀតលើកថា នៅថេរដដែល ។ តាមយោបល់អ្នកឆ្លើយសំភាសន៍ ការធ្លាក់ចុះចំណូលនេះ បណ្តាលពីការចុះថ្លៃរបស់អេតចាយ ធៀបនឹងរយៈពេល ៣ខែចុងក្រោយ ។ អ្នករើសអេតចាយ

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

៦៥% ដែលបានឆ្លើយសំភាសន៍ គឺជាជនចំណាកស្រុកមកពីជនបទ ហើយ ៣៥% ទៀតច្រើនជាអ្នករស់នៅក្បែរកន្លែងចាក់សំរាមតែម្ដង ។ ជនចំណាកស្រុកភាគច្រើន មកជាមួយគ្រួសាររបស់ពួកគេ ហើយមួយភាគធំ ជួលផ្ទះស្នាក់នៅក្នុងភូមិក្បែរកន្លែងចាក់សំរាម ។ គេបានរាយការណ៍ថា ជនចំណាកស្រុកចំនួន ៥៨% គ្មានដីធ្លីទេ ហើយ ៣១% មានដីតិចជាង ១ ហិកតា ។ អ្នករើសអេតចាយដែលឆ្លើយសំភាសន៍ បានត្អូញត្អែរថា ចំណូលប្រចាំថ្ងៃរបស់ពួកគេ គ្មានស្ថិរភាពទេ ហើយពួកគេរកបានសំរាប់តែមួយរស់ប៉ុណ្ណោះ ។

នៅខែឧសភា ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ គឺ ៧.៨៦០រៀល រីកើន ៨,៦% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៥ ប៉ុន្ដែធ្លាក់ចុះ ១៤,៤% ធៀបនឹងអង្កេតលើកមុន នៅខែកុម្ភៈ ។ កម្មករកាត់ដេរ នៅខែឧសភា ចំណាយអស់ជាមធ្យម ៣៦ដុល្លារ បូកទាំងម្ហូបអាហារផង ។ មានកម្មករតែ ១៧,៥% ប៉ុណ្ណោះដែលនិយាយថា អាចសន្សំប្រាក់បានខ្លះក្នុងចំណូលនេះ ។ កម្មករប្រហែល ៦០% បានផ្ញើប្រាក់ទៅឱ្យក្រុមគ្រួសាររបស់ខ្លួន ។ អង្កេតបង្ហាញថា កម្មករកាត់ដេរ ៧៥% គ្មានជំនាញទេ មុនពេលពួកគេទៅធ្វើការក្នុងរោងចក្រ ២១% និយាយថា បានទទួលការបណ្ដុះបណ្ដាលពីក្រុមហ៊ុនបណ្ដុះបណ្ដាលឯកជន និង ៤% ទៀតប្រាប់ថា បានទទួលការបណ្ដុះបណ្ដាលនៅផ្ទះ ។ យោងតាមលទ្ធផលអង្កេត កម្មករកាត់ដេរ ១០% ជាកម្មករអណ្ដែត និង ៩០% ជាកម្មករពេញសិទ្ធិ ។

ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នកធាក់ស៊ីក្លូ និងអ្នកលីសែង កើន ១០,៦% និង ៤,៥% នៅខែឧសភា ឆ្នាំ២០០៦ ធៀបនឹងអង្កេតដូចគ្នា ឆ្នាំ ២០០៥ ។ ប៉ុន្ដែ ចំនួនពាក់កណ្ដាលនៃអ្នកធាក់ស៊ីក្លូ និងអ្នកលីសែង ប្រាប់ថា ចំណូលរបស់ពួកគេ អាចដោះស្រាយបានតែមួយចំណែកតូចនៃតំរូវការក្នុងការទ្រទ្រង់ជីវភាពគ្រួសារប៉ុណ្ណោះ ។ ជាទូទៅ អ្នកធាក់ស៊ីក្លូចំណាយ ៤.៤០០រៀល/ថ្ងៃ ហើយអ្នកលីសែងចំណាយ ៣.៧០០រៀល/ថ្ងៃ លើម្ហូបអាហារ គឺច្រើនជាងឆ្នាំមុន ១៦% និង ៩% ។ ទាំងអ្នកធាក់ស៊ីក្លូ នឹងអ្នកលីសែង ជាជនចំណាកស្រុកពីតំបន់ជនបទ ហើយពួកគេធ្វើការ ២៥ថ្ងៃក្នុងខែឧសភា និងប្រហែល ៧ខែក្នុងមួយឆ្នាំ ។

**កំណត់សំគាល់**

១. ប្រភព: គណនាចេញពីទិន្នន័យរបស់វិជ្ជាស្ថានជាតិស្ថិតិ

*រៀបរៀងដោយ ប៉ុន ដូរីណា និងផាន់ ដាលីស*


## Cambodia Development Review – 2006 Subscription Rates

**Domestic Subscription (Individual)**

❑ English edition ($14) ❑ Khmer edition (5,000r) Payment by ❑ cash ❑ cheque ❑ Telegraphic Transfer

Total payment enclosed ______

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❑ English edition ($60 for five copies) ❑ Khmer edition (20,000r for five copies)

Payment by ❑ cash ❑ cheque ❑ Telegraphic Transfer. Total payment enclosed ______

**International Subscription (Individual)**

❑ Thailand, Laos, Vietnam ❑ English edition ($25)* ❑ Khmer edition ($15)*

❑ Asia and Europe ❑ English edition ($30)* ❑ Khmer edition ($20)*

❑ Americas and Africa ❑ English edition ($35)* ❑ Khmer edition ($25)*

At present CDRI can accept payment from overseas only by US-dollar dominated cheque or By Telegraphic Transfer.

Total payment enclosed ______

**Payment options:**

1. By Telegraphic Transfer – Please add $10 for bank charges to the above Total Cost. Transfer to:
   - Account Name: CDRI
   - Account Number: 133451
   - Bank Name: ANZ Royal Bank
   - Bank Address: Phnom Penh, Cambodia
   - Swift Code: ANZBKHPP
   - Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York, Swift Code: CHASUS33, CHIP UID 004966
2. By Cheque - Please add (overseas) $50 (local) $2 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications at the address shown at the mashead.

Title: ❑ Mr ❑ Ms ❑ Dr ❑ Other: ______ First name: ______ Last name: ______

Position: ______ Organisation / Company: ______

Address (CCC Box if applicable): ______

City / Province: ______ Country: ______

Telephone: ______ Fax: ______

e-mail: ______ ❑ Tick this box to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Please make cheques payable to the Cambodia Development Resource Institute. Do not send cash through the post. Please inform the Publications Section at CDRI if your contact details change.

## តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000* | 2001* | 2002* | 2003* | 2004* | 2005 | | | | 2006 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | ទ្រព្យសកម្មជាប់លាប់ ( លានដុល្លារ) | | | | | | | |
| កសិកម្ម | 51.6 | 63.9 | 9.8 | 0.4 | 40.3 | 3.7 | 12.3 | 3.2 | 4.0 | 10.4 | 9.1 | 126.5 |
| ឧស្សាហកម្ម | 650.5 | 162.6 | 109.4 | 105.2 | 67.7 | 137.2 | 189.2 | 418.8 | 62.1 | 349.7 | 82.0 | 40.1 |
| *កាត់ដេរ* | *126.5* | *67.7* | *81.5* | *26.5* | *27.2* | *68.1* | *133.9* | *44.9* | *23.2* | *56.5* | *27.3* | *30.5* |
| សេវាកម្ម | 154.7 | 222.6 | 150.1 | 118.4 | 145.3 | 168.4 | 92.0 | 53.3 | 30.0 | 44.1 | 28.1 | 60.7 |
| *សណ្ឋាគារ និងទេសចរណ៍* | *112.0* | *171.8* | *79.8* | *73.8* | *47.1* | *124.1* | *55.9* | *46.4* | *0.0* | *33.6* | *22.6* | *0.0* |
| សរុប | 856.8 | 449.1 | 269.2 | 224.0 | 253.3 | 309.3 | 293.5 | 475.3 | 96.1 | 404.2 | 119.2 | 227.3 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | |
| សរុប | - | - | - | - | - | - | - | 2798.2 | -79.8 | 320.6 | -70.5 | 90.7 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | |
| សរុប | 15.0 | -47.6 | -40.0 | -19.5 | 10.5 | 31.1 | -12.4 | 650.8 | -15.2 | 392.9 | 628.1 | -52.2 |

** revised and including expansion project approvals. Source: Cambodian Investment Board.*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | លានដុល្លារ | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 21.2 | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 30.3 | 14.3 | 6.6 | 19.2 | 5.4 | 10.1 |
| ផ្ទះល្វែង | 227.3 | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 167.6 | 48.6 | 69.1 | 41.3 | 45.1 | 39.9 |
| ផ្សេងៗ | 27.0 | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 65.6 | 43.1 | 28.6 | 16.0 | 21.3 | 17.4 |
| សរុប | 275.4 | 326.8 | 205.4 | 196.2 | 219.8 | 198.9 | 263.4 | 106.1 | 104.4 | 76.5 | 71.8 | 67.3 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | |
| សរុប | - | - | - | - | - | - | - | 65.5 | -1.6 | -26.7 | -6.1 | -6.2 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | |
| សរុប | 6.9 | 18.7 | -37.2 | -4.5 | 12.0 | -9.5 | 32.5 | 45.5 | 114.8 | -1.8 | 12.0 | -36.5 |

*Source: Department of Cadastre and Geography of the Municipality of Phnom Penh*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 784.4 | 941.1 | 1056.2 | 1268.2 | 1453.2 | 1708.1 | 2108.1 | 463.0 | 515.0 | 730.0 | 644.8 | 603.2 |
| រួមមាន: សំលៀកបំពាក់ | 378.0 | 554.0 | 962.1 | 1202.2 | 1355.8 | 1628.4 | 2027.0 | 444.9 | 497.6 | 709.8 | 601.0 | 568.5 |
| - ទៅសហរដ្ឋអាមេរិក | 74.1 | 486.0 | 714.1 | 840.9 | 943.4 | 1099.8 | 1270.9 | 312.5 | 335.9 | 489.5 | 408.1 | 402.5 |
| - ទៅសហគមន៏អឺរ៉ុប | - | - | 228.1 | 323.3 | 356.3 | 414.7 | 590.8 | 89.2 | 106.0 | 162.5 | 145.3 | 110.6 |
| - ប្រទេសផ្សេងទៀត | 82.0 | 68.0 | 19.9 | 38.0 | 56.1 | 113.8 | 165.3 | 43.1 | 55.7 | 57.8 | 47.5 | 55.3 |
| កសិកម្ម | - | - | 94.2 | 66.0 | 97.3 | 79.7 | 81.2 | 18.1 | 17.3 | 20.2 | 43.8 | 34.7 |
| - កៅស៊ូ | - | - | 29.6 | 25.9 | 29.7 | 35.1 | 38.3 | 7.3 | 6.2 | 9.8 | 13.4 | 7.8 |
| - ឈើ | - | - | 32.9 | 22.3 | 16.0 | 10.2 | 11.1 | 3.3 | 2.9 | 2.1 | 2.0 | 2.1 |
| - ត្រី | - | - | 5.4 | 6.0 | 4.3 | 2.8 | 10.6 | 1.5 | 1.1 | 0.8 | 6.6 | 1.9 |
| - ផ្សេងៗ | - | - | 26.2 | 11.8 | 47.4 | 31.6 | 21.3 | 6.0 | 7.1 | 7.5 | 21.9 | 22.9 |
| ការនាំចូលសរុប | 1112.2 | 1237.4 | 1417.7 | 1501.4 | 1707.8* | 1824.9 | 2149.0 | 520.7 | 666.4 | 632.3 | 691.1 | 690.7 |
| រួមមាន: - សាំង | - | - | - | - | 25.9 | 33.2 | 30.2 | 10.3 | 9.3 | 9.9 | 10.7 | 10.9 |
| - ម៉ាស៊ូត | - | - | - | - | 100.8 | 109.6 | 109.4 | 21.6 | 25.8 | 24.6 | 21.1 | 32.5 |
| - សំភារៈសំណង់ | - | - | - | - | 12.9 | 80.8 | 95.3 | 32.3 | 37.1 | 38.7 | 26.2 | 37.0 |
| - ផ្សេងៗ | - | - | - | - | 1568.2 | 1601.3 | 1914.0 | 456.5 | 594.2 | 559.1 | 633.1 | 610.3 |
| ជញ្ជីងពាណិជ្ជកម្ម | -327.8 | -296.3 | -361.5 | -233.2 | -254.6 | -116.8 | -40.9 | -57.7 | -151.4 | 97.7 | -46.3 | -87.5 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | - | -14.5 | 11.8 | 42.6 | -15.3 | -5.4 |
| ការនាំចេញសរុប | - | - | - | - | - | - | - | -15.1 | 11.2 | 41.7 | -11.7 | -6.4 |
| ការនាំចូលសរុប | - | - | - | - | - | - | - | -5.0 | 28.0 | -5.1 | 9.3 | -0.03 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 66.4 | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 24.5 | 16.0 | 3.8 | 10.3 | 15.5 | 27.8 |
| ការនាំចេញសរុប | 59.0 | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 23.4 | 15.9 | 4.1 | 9.2 | 18.3 | 30.3 |
| ការនាំចូលសរុប | 1.6 | 11.3 | 14.6 | 5.9 | 13.7 | 6.9 | 17.8 | 13.7 | 9.9 | 20.5 | 26.1 | 32.6 |

*Imports include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | | 2006 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | អ្នកដំណើរពាន់នាក់ | | | | | | |
| តាមផ្លូវអាកាស | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 626.1 | 231.7 | 169.8 | 202.8 | 251.5 | 275.4 |
| តាមផ្លូវគោក និងទឹក | 100.2 | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 428.9 | 148.9 | 124.0 | 120.4 | 164.5 | 181.9 |
| សរុប | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 701.1 | 1055.0 | 380.6 | 293.8 | 323.2 | 416.0 | 457.3 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | |
| សរុប | - | - | - | - | - | - | - | 0.5 | -22.8 | 10.0 | 28.7 | 9.9 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | |
| សរុប | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 49.6 | 51.6 | 41.8 | 9.8 | 20.2 |

*ប្រភព: ក្រសួងទេសចរណ៍ ។*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៨-២០០៦ (ពាន់លានរៀល)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 920 | 1326 | 1528 | 1529 | 1744 | 1765 | 2127 | 551.6 | 621.9 | 624.0 | 827.8 | 595.9 |
| ចំណូលចរន្ត | - | - | - | 1521 | 1728 | 1733 | 2107 | 551.3 | 611.5 | 609.5 | 701.6 | 593.2 |
| ចំណូលពន្ធ | 676 | 956 | 1096 | 1096 | 1227 | 1220 | 1577 | 455.1 | 466.0 | 436.2 | 553.8 | 484.7 |
| ពន្ធគយ | 376 | 432 | 376 | 376 | 424 | 395 | 513 | 129.4 | 129.7 | 123.7 | 189.8 | 135.5 |
| ចំណូលមិនមែនពន្ធ | 204 | 348 | 424 | 424 | 501 | 513 | 530 | 96.2 | 145.5 | 173.2 | 147.8 | 108.5 |
| អាជីវកម្មព្រៃឈើ | 20 | 36 | 28 | 29 | 15 | 7 | 2 | 1.3 | 1.5 | 0.3 | 0.1 | 0.5 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 88 | 108 | 124 | 122 | 123 | 120 | 94 | 21.9 | 32.0 | 30.9 | 38.0 | 11.4 |
| ចំណូលជាមូលធន | 36 | 12 | 8 | 9 | 16 | 31 | 19 | 0.3 | 10.4 | 14.6 | 126.3 | 2.7 |
| ចំណាយសរុប | 1296 | 1792 | 2332 | 2332 | 2948 | 2757 | 2932 | 706.3 | 713.7 | 912.9 | 998.9 | 855.6 |
| ចំណាយជាមូលធន | 368 | 624 | 976 | 977 | 1388 | 1171 | 1163 | 326.3 | 315.9 | 335.4 | 350.3 | 266.9 |
| ចំណាយចរន្ត | 980 | 1164 | 1356 | 1355 | 1560 | 1586 | 1769 | 380.0 | 397.8 | 577.0 | 648.6 | 588.8 |
| អប់រំ និងសុខាភិបាល | 132 | 280 | 344 | 343 | 454 | 473 | 518 | 52.5 | 92.3 | 202.1 | 228.4 | 80.3 |
| ការពារជាតិ និងសន្តិសុខ | 448 | 464 | 404 | 405 | 438 | 411 | 423 | 74.9 | 73.9 | 116.7 | 71.4 | 78.1 |
| ក្រសួងផ្សេងៗទៀត | 332 | 412 | 636 | 637 | 668 | 702 | 828 | 252.6 | 231.7 | 258.2 | 348.8 | 430.4 |
| ឱនភាពជាទូទៅ | -380 | -476 | -804 | -803 | -1204 | -992 | -805 | -154.7 | -91.9 | -288.3 | -171.0 | -259.8 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 268 | 416 | 768 | 766 | 1249 | 886 | 864 | 266.7 | 255.7 | 335.8 | 269.0 | 184.0 |
| ហិរញ្ញប្បទានក្នុងស្រុក | 112 | 60 | 36 | 37 | -45 | 106 | 148 | -111.9 | -163.9 | -47.5 | -97.9 | 75.8 |

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001* | 2002 | 2003 | 2004 | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 14.4 | 20.7 | 21.5 | 14.5 | 16.6 | 15.8 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 14.8 | 4.0 | -0.8 | 0.2 | 3.3 | 1.1 | 3.9 | 5.6 | 6.4 | 4.6 | 6.6 | 6.1 |
| - ម្ហូបអាហារ | 14.1 | 7.6 | -3.4 | -2.5 | 1.8 | 1.5 | 6.4 | 7.9 | 9.8 | 6.0 | 10.6 | 10.6 |
| - ដឹកជញ្ជូន | 15.1 | 3.5 | 6.6 | -4.2 | 0.3 | 4.9 | 9.7 | 12.3 | 11.1 | 11.9 | 10.2 | 9.7 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ* | - | - | 3840.8 | 3916.3 | 3912.1 | 3973.3 | 4016.3 | 4027.0 | 4054.3 | 4134.3 | 4154.3 | 4094.8 |
| រៀលក្នុង ១ បាតថៃ* | - | - | 95.8 | 88.2 | 91.1 | 95.8 | 99.9 | 104.4 | 101.3 | 100.2 | 101.4 | 103.5 |
| រៀលក្នុង ១០០ ដុងវៀតណាម* | - | - | 27.1 | 26.6 | 25.6 | 25.6 | 25.5 | 25.1 | 25.3 | 25.9 | 26.1 | 25.4 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 40.4 | 36.0 | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 52.6 | 52.5 | 55.4 | 57.0 | 64.2 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 883 | 1065 | 1105 | 1329 | 1521 | 1508 | 3442 | 2350 | 2500 | 2767 | 2921 | 2867 |
| ថ្លៃសាំង (រៀល/លីត្រ) | 1378 | 1613 | 1760 | 2113 | 2084 | 2150 | 2633 | 3050 | 3300 | 3633 | 3750 | 3767 |

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៨-២០០៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q1 | Q2 | Q3 | Q4 | 2006 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 1726 | 2019 | 2589 | 3080 | 3737 | 4027 | 4797 | 4883 | 5084 | 5391 | 5475 | 6410 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -496 | -576 | -759 | -876 | -849 | -698 | -467 | -385 | -455 | -397 | -450 | -699 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 178 | 103 | 3 | -75 | -119 | -128 | -209 | -252 | -343 | -404 | -421 | -755 |
| ឥណទានចំពោះផ្នែកឯកជន | 655 | 763 | 898 | 936 | 1059 | 1337 | 1817 | 1983 | 2166 | 2386 | 2394 | 2778 |
| រូបិយវត្ថុទូទៅ M2 | 1230 | 1443 | 1831 | 2204 | 2888 | 3328 | 4329 | 4498 | 4629 | 4994 | 5025 | 5711 |
| រូបិយវត្ថុ M1 | 543 | 531 | 540 | 609 | 813 | 937 | 1153 | 1198 | 1215 | 1279 | 1323 | 1449 |
| រូបិយវត្ថុផ្សេងៗ | 687 | 911 | 1291 | 1594 | 2075 | 2391 | 3176 | 3300 | 3414 | 3715 | 3702 | 4262 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 15.2 | 30.0 | 22.9 | 20.4 | 19.8 | 16.1 | 27.0 |
| រូបិយវត្ថុ M1 | 41 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 19.0 | 16.8 | 18.6 | 14.7 | 20.9 |
| រូបិយវត្ថុផ្សេងៗ | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 15.2 | 32.8 | 20.3 | 21.7 | 20.2 | 16.6 | 33.6 |

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2002 | 2003 | 2004 | 2005 | | | 2006 | | 2005 | 2006 | |
| | វិច្ឆិកា | | | | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8975 | 8572 | 7614 | 7726 | 7857 | 7768 | 7873 | 8546 | 4.7 | -7.7 | 10.6 |
| អ្នកលីសែង | 6233 | 7044 | 6676 | 6895 | 7056 | 6000 | 6473 | 6519 | 7375 | -4.0 | -6.0 | 4.5 |
| អ្នកលក់បន្លែតូចតាច | 5256 | 6566 | 6532 | 6947 | 8574 | 5938 | 8385 | 6186 | 6492 | 5.4 | -3.1 | -24.3 |
| អ្នករើសអេតចាយ | 2718 | 3685 | 3944 | 4446 | 5270 | 4335 | 4801 | 4984 | 4512 | 11.3 | -7.4 | -14.4 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4365 | 4932 | 4448 | 4287 | 4648 | 3893 | 4670 | 4243 | -2.8 | 4.5 | -1.0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4304 | 4177 | 4139 | 3822 | 4009 | 4224 | 4127 | 4541 | -3.0 | 3.3 | 18.8 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 8904 | 9577 | 9277 | 7235 | 8756 | 8659 | 9184 | 7860 | -8.7 | -0.3 | 8.6 |
| អ្នករត់ម៉ូតូឌុប | 8,610 | 12,184 | 10,092 | 9204 | 11,130 | 9406 | 9645 | 8884 | 8790 | 14.8 | -24.5 | -23.1 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6453 | 6558 | 6382 | 8130 | 6069 | 6691 | 5974 | 6407 | 4.3 | 3.9 | -21.2 |
| កម្មករសំណង់មានជំនាញ | 13,127 | 12,605 | 13,111 | 12,679 | 12,320 | 10,273 | 11,253 | 11,750 | 9833 | -4.9 | -18.2 | -20.2 |

*សំគាល់: ចំនួនអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។ * ចំនួលអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្តល់ឱ្យទេ ។ ប្រភព: តារាង៥: ទិន្នន័យបណ្តោះអាសន្នឆ្នាំ ២០០៤-០៥ និង Q1 ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៦: * លេខកែតំរូវ CDRI, IMF, NIS, ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៧: NBC / តារាង៨: វបសអ ។*

*តពីទំព័រទី ២៤* **ពត៌មានថ្មីៗពី...**

Lawrence Haddad ជានាយកនៃ IDS ។ សាស្ត្រាចារ្យ Lawrence Haddad បានមកភ្នំពេញ ដើម្បីចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ វិបសអ ក្នុងនាមជាសមាជិកថ្មី ។ វាគ្មិនមួយចំនួនរួមទាំង លោកបណ្ឌិត ហង់ ជួនណារ៉ុន ជាប្រធាននៃក្រុមប្រឹក្សាភិបាល វិបសអ បានធ្វើការពិភាក្សាដ៏គួរឱ្យចាប់អារម្មណ៍ និងមានសារៈសំខាន់ដែលផ្ដោតជាចំបងទៅលើគោលនយោបាយជំរុញការអភិវឌ្ឍន៍ជនបទ និងកសិកម្ម ព្រមទាំងបញ្ហាប្រឈមនៃកំណើនវិសមភាពនៅក្នុងសង្គមកម្ពុជា ។

នៅថ្ងៃ ២៨ សីហា វិបសអ រៀបចំកិច្ចពិភាក្សាតុមូល ដើម្បីពិភាក្សាពីលទ្ធផលនៃការស្រាវជ្រាវស្ដីពី កម្មវិធីប្រមូលផលដើមដៃ (EHP) ដែលជាចំណែកមួយនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ។ អ្នកស្រាវជ្រាវ វិបសអ សង្កេតឃើញថា EHP ផ្ដល់នូវឱកាសដ៏សំខាន់ដល់កសិករកម្ពុជាក្នុងការផលិតបន្ថែមទៀតសំរាប់ធ្វើពាណិជ្ជកម្ម ប៉ុន្តែកសិករទាំងនោះត្រូវប្រឈមនឹងបញ្ហាមួយចំនួនទាក់ទិននឹងចំណាយផលិតកម្មខ្ពស់ និងម៉ាឃីតទីង ។ អ្នកតំណាងមកពីរដ្ឋាភិបាល សង្គមស៊ីវិល និងវិទ្យាស្ថានស្រាវជ្រាវនានា បានចូលរួមពិភាក្សាយ៉ាងរស់រវើក ដោយមានដាក់បញ្ចូលទាំងបទពិសោធន៍នៃ EHP នៅថៃ និងវៀតណាម ធ្វើជាឯកសារយោង ។ ការស្រាវជ្រាវ និងសិក្ខាសាលានេះ បានទទួលការជួយឧបត្ថម្ភពី អុកស្វាមអាមេរិក ។

ក្រុមបណ្ដាញវិភាគអភិវឌ្ឍន៍ (DAN) នៃ វិបសអ បានចូលរួមក្នុងសិក្ខាសាលានៅខេត្តដាណាង ប្រទេសវៀតណាម នាខែសីហា ជាមួយស្ថាប័នស្រាវជ្រាវ DAN ដទៃទៀតមកពីកម្ពុជា ឡាវ ថៃ វៀតណាម និងខេត្តយូណាន ប្រទេសចិន ។ កិច្ចប្រជុំមានគោលដៅលើកបង្ហាញពីការរកឃើញដំបូងៗ ពីករណីសិក្សារបស់ប្រទេសនីមួយៗ ស្ដីពីទេសចរណ៍គាំទ្រអ្នកក្រនៅមហាអនុតំបន់មេគង្គ ។ ករណីសិក្សានៅកម្ពុជា លើកឡើងពីក្រុងសៀមរាប និងបញ្ចូលអង្កេតលើគ្រួសារចំនួន ៥០៦គ្រួសារ មកពី ៨ភូមិ នៅជុំវិញទីរួមខេត្តសៀមរាប ។ ការស្រាវជ្រាវបង្ហាញថា អ្នកក្រមួយចំនួននៅជនបទ បានទទួលប្រយោជន៍ពីសកម្មភាពពាក់ព័ន្ធនឹងទេសចរណ៍ ប៉ុន្តែមិនច្រើនដូចការរំពឹងទុកទេ ដោយសារពួកគេត្រូវប្រកួតប្រជែងជាមួយអ្នកភូមិមានៗ និងអ្នកចំណូលស្រុក ដែលជាអ្នកអាចទទួលបានការងារមានចំនូលខ្ពស់ជាង ។ របាយការណ៍ពេញលេញ ស្ដីពីទេសចរណ៍គាំទ្រអ្នកក្រនៅមហាអនុតំបន់មេគង្គ នឹងត្រូវលើកយកមកពិភាក្សាក្នុងសិក្ខាសាលាផ្សព្វផ្សាយ DAN ដែលប្រារព្ធធ្វើនៅក្រុងសៀមរាប នាខែធ្នូ ។ គំរោងនេះ ជួយឧបត្ថម្ភដោយ Rockefeller Foundation ។

កម្មវិធីសេដ្ឋកិច្ចនិងបរិស្ថាននៅអាស៊ីអគ្នេយ៍ (EEPSEA) នាបច្ចុប្បន្នជួយគាំទ្រ វិបសអ ក្នុងការងារកសាងសមត្ថភាពស្រាវជ្រាវចំនួន ៣ សំខាន់ៗទាក់ទិននឹងសេដ្ឋកិច្ចបរិស្ថាន ។ ទី១ គឺការសិក្សាខ្នាតតូចស្ដីពី "ប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា: ស្ថាប័ន បញ្ហា និងដំណោះស្រាយសំរាប់បង្កើនការទទួលបានទឹកស្អាត" ។ ក្រុមអ្នកស្រាវជ្រាវ ៤រូប មកពីផ្នែកផ្សេងៗគ្នា កំពុងសិក្សាលើប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យម ចំនួន៣នៅតាកែវ ។ គំរោងទី២ ផ្ដោតលើ "ការវិភាគចំណាយ និងផលចំណេញនៃការអភិវឌ្ឍន៍ចំការកៅស៊ូនៅកម្ពុជា" ។ ការសិក្សានេះ នឹងវាយតំលៃពីចំណាយ និងចំណេញនៃការប្រែក្លាយដីព្រៃធម្មជាតិទៅជាចំការកៅស៊ូ ។ គំរោងទី៣ មានឈ្មោះថា "ការវាយតំលៃខាងបរិស្ថាន: តំលៃនៃឧទ្យានជាតិបូកគោ សំរាប់ការលំហែកំសាន្តផ្អែកលើបរិស្ថាន" ។ ការសិក្សានេះ មានគោលដៅពិនិត្យមើល ថាតើកំរៃចូលទស្សនាបច្ចុប្បន្ន បង្ហាញពីតំលៃឧទ្យានជាតិបានត្រឹមត្រូវរឺទេ និងមើលពីកត្តាដែលជះឥទ្ធិពលដល់បំណងរបស់អ្នកទេសចរក្នុងការបង់កំរៃចូលទស្សនា ព្រមទាំងចំណាយលើការធ្វើដំណើរមកកំសាន្តនៅឧទ្យានជាតិ ។

## ផ្នែកសន្តិសុខមនុស្ស ការកសាងសន្តិភាព និងការបំប្លែងទំនាស់

### *១. ការកសាងសន្តិភាព និងការបំប្លែងទំនាស់*

ពីខែមិថុនា ដល់សីហា ក្រុមអ្នកបណ្ដុះបណ្ដាល បន្តផ្ដល់ការបណ្ដុះបណ្ដាលពីការងារកសាងសន្តិភាព វគ្គ២ និងវគ្គ៣នៅភ្នំពេញ ។ បន្ទាប់មកមានការវាយតំលៃនៅខេត្តស្ទឹងត្រែងពីតំរូវការបណ្ដុះបណ្ដាលពិសេស ស្ដីពីធ្វើការរួមគ្នាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ហើយអាចបើកវគ្គនៅខែតុលា ២០០៦ ។

### *២. យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា (COPCEL ដំណាក់កាលទី២)*

ព្រឹត្តិការណ៍ចំបងមួយនៃ COPCEL ក្នុងកំឡុងពេលនេះ គឺការរៀបចំកិច្ចប្រជុំ COPCEL ថ្នាក់ខេត្តនៅតំបន់ ៥ ព្រមទាំងកិច្ចប្រជុំ COPCEL ជាបន្តបន្ទាប់នៅភ្នំពេញ ។ ពីថ្ងៃ១៤ ដល់ ១៨ ខែសីហា វិបសអ បានរៀបចំកិច្ចប្រជុំនៅថ្នាក់ខេត្តចំនួន ៥ គឺបន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង ។ វិបសអ បានទទួលការគាំទ្រយ៉ាងខ្លាំងក្លា និងការចូលរួមពីបណ្ដាអាជ្ញាធរខេត្តទាំងអស់ និងភាគីពាក់ព័ន្ធនានា ។ អ្នកចូលរួមប្រជុំនៅខេត្តនីមួយៗដែលមានពី ១១០ ទៅ ១២០នាក់ បានលើកឡើងយ៉ាងត្រង់ៗបើកចំហ និងមានការពិចារណាលើបញ្ហានានានៅក្នុងការបោះឆ្នោត និងបានបង្ហាញការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើ COPCEL ។ គណៈប្រតិភូពី UNDP និង SIDA ដឹកនាំដោយលោក Douglas Gardner ជាតំណាង និងអ្នកសំរបសំរួល អង្គការសហប្រជាជាតិ បានចូលរួមកិច្ចប្រជុំ COPCEL ថ្នាក់ខេត្ត នៅកំពង់ឆ្នាំង នាថ្ងៃ១៨ សីហា និងបានបង្ហាញពីការគាំទ្រចំពោះកិច្ចប្រជុំនេះ ។ លោក Larry Strange នាយកប្រតិបត្តិនៃ វិបសអ បានជួបជាមួយអភិបាលខេត្តទាំង ៥ ហើយទស្សនកិច្ចនេះ បានជួយកសាងទំនាក់ទំនងកាន់តែខ្លាំងក្លា និងកិច្ចសហប្រតិបត្តិការយ៉ាងល្អសំរាប់ COPCEL និងបញ្ហាផ្សេងទៀតរវាងវិទ្យាស្ថាន និងអាជ្ញាធរខេត្ត ។

## ផ្នែកបោះពុម្ពផ្សាយ

ពីខែមិថុនា ដល់សីហា ផ្នែកបោះពុម្ពផ្សាយបានឆ្លងកាត់ការកែប្រែសំខាន់មួយបន្ទាប់ពីការចាកចេញទៅសិក្សានៅហ្វីលីពីនរយៈ ២ឆ្នាំ របស់ប្រធានផ្នែក ។ ការរៀបចំសាជាថ្មីនេះ អាចជួយឱ្យបុគ្គលិកដែលនៅសល់តិចនាក់អាចបំពេញតាមតំរូវការខាងសេវាផ្សព្វផ្សាយបាន ។ ក្រៅពីឯកសារផ្សព្វផ្សាយជាប្រចាំ ដូចជា ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា (ប្រចាំត្រីមាស) និងរបាយការណ៍ថ្មីៗស្ដីពីសេដ្ឋកិច្ច (ប្រចាំខែ) មានការបោះពុម្ព និងចែកផ្សាយនូវរបាយការណ៍ជាភាសាខ្មែរស្ដីពី ការផ្សារភ្ជាប់វិស័យទេសចរណ៍ទៅនឹងការកាត់បន្ថយភាពក្រីក្រ: ករណីសិក្សានៅខេត្តសៀមរាប ។ ឯកសារសំខាន់មួយទៀតគឺ សន្ទានុក្រមសេដ្ឋកិច្ចដែលបានកែសំរួល ត្រូវបានរៀបចំចប់សព្វគ្រប់ និងបានដាក់ឱ្យពិនិត្យផ្ដល់យោបល់ ។ សន្ទានុក្រមបោះពុម្ពថ្មីនេះ ដែលនឹងផ្សព្វផ្សាយនៅពេលដ៏ខ្លីខាងមុខ មាន ២ផ្នែក ។ ផ្នែកទី១ ជាឯកសារកែសំរួលពីសន្ទានុក្រមសេដ្ឋកិច្ចអង់គ្លេស-ខ្មែរ ឆ្នាំ១៩៩៥ ។រីឯ ផ្នែកទី២ ជាសន្ទានុក្រមខ្មែរ-អង់គ្លេសថ្មី ដែលមានប្រយោជន៍សំរាប់ពន្យល់អត្ថន័យពាក្យបច្ចេកទេសខ្មែរ ស្របតាមការវិវត្តន៍ថ្មីនៃក្នុងអក្សរសាស្ត្រខ្មែរ និង-អាចជួយឱ្យការប្រើពាក្យខ្មែរ មានការឯកភាពគ្នា ។

# ព័ត៌មានថ្មីៗ ពី វបសអ

## ផ្នែកគ្រប់គ្រង

នៅថ្ងៃ ១ កក្កដា វបសអ បានធ្វើការផ្លាស់ប្តូរសំខាន់ៗក្នុងអង្គការលេខ យោងតាមរបាយការពិនិត្យសើរើគំរូខាងស្ថាប័ននៅឆ្នាំ២០០៥ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាលក្នុងកិច្ចប្រជុំនៅខែធ្នូ ២០០៥ ។ ស្របតាមការតាំងចិត្តក្នុងការកសាងក្រុមអ្នកគ្រប់គ្រងជាជនកម្ពុជា និងក្នុងការកែលំអរចនាសម្ព័ន្ធផ្នែកស្រាវជ្រាវ វបសអ បានបង្កើតមុខនាទីថ្មី ៥ សំរាប់អ្នកគ្រប់គ្រងកម្មវិធី រីការស្រាវជ្រាវ និងមុខនាទីថ្មី ១ សំរាប់ប្រធានទំនាក់ទំនងសាធារណៈ ដោយមានការជ្រើសរើសប្រកបដោយការប្រកួតប្រជែង ។ អ្នកគ្រប់គ្រងថ្នាក់កណ្តាលទាំងនេះ រួមជាមួយអ្នកគ្រប់គ្រងពីមុនៗនៅផ្នែកហិរញ្ញវត្ថុ បោះពុម្ពផ្សាយ បណ្ណាល័យ រដ្ឋបាល និង IT និង ក្រុមអ្នកគ្រប់គ្រងជាន់ខ្ពស់ បង្កើតបានជាគណៈកម្មាធិការ គ្រប់គ្រងនៃ វបសអ ។ លោក ច័ន្ទ សុផល ជំនាញការខាងភាពក្រីក្រ នឹងត្រឡប់មក វបសអ នៅថ្ងៃទី ១ តុលា ក្នុងនាមជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកបណ្តាញស្រាវជ្រាវ និងការសិក្សាខាងភាពក្រីក្រ បន្ទាប់ពីបញ្ចប់ការងារជាមួយ ក្រុមការងារភាពក្រីក្ររបស់ធនាគារពិភពលោក ។ សូមអានវេបសាយ វបសអ សំរាប់ព័ត៌មានបន្ថែមទាក់ទិននឹងកម្មវិធីផ្សេងៗ និងបុគ្គលិកជាន់ខ្ពស់របស់ វបសអ ។

ជំហានបន្ទាប់នៃការអភិវឌ្ឍន៍ខាងស្ថាប័ន វបសអ នឹងរៀបចំផែនការកសាងសមត្ថភាព ដោយផ្អែកលើការវាយតំលៃពីតំរូវនៃស្ថាប័ន និងបុគ្គលិកនីមួយៗ ដោយតភ្ជាប់ទៅនឹងចំណុចអភិវឌ្ឍន៍សមត្ថភាពជំនាញឯកទេស ដែល វបសអ កំពុងដាក់បញ្ចូលទៅក្នុងគ្រប់កម្មវិធី និងគំរោងថ្មីសំខាន់ៗ ។ រឿងនេះ នឹងលើកបង្ហាញក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយនៅចុងខែមករា ២០០៧ សំរាប់យកទៅអនុវត្តក្នុងផែនការយុទ្ធសាស្ត្រ ២០០៦-១០ ។ ផែនការកសាងសមត្ថភាព នឹងផ្តោតលើតំរូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ និងការកសាងសមត្ថភាពអ្នកគ្រប់គ្រងថ្នាក់កណ្តាល និងបុគ្គលិកជាន់ខ្ពស់ ប៉ុន្តែវានឹងផ្តល់ប្រយោជន៍ដល់បុគ្គលិកគ្រប់រូប ។

ទីប្រឹក្សាខាងយេនឌ័រ បានទទួលតួនាទីសំខាន់ៗ ៣ នៅ វបសអៈ (១) ត្រូវសើរើគ្រប់ផែនការ និងសំណើកម្មវិធីនិងគំរោងសំខាន់ៗ ដើម្បីធានាថាយេនឌ័រ ត្រូវបានដាក់បញ្ចូលជាប្រធានបទស្រាវជ្រាវ (២) ត្រូវកសាងការយល់ដឹង និងជំនាញខាងយេនឌ័រនៅទូទាំង វបសអ និង (៣) ត្រូវជួយថ្នាក់គ្រប់គ្រង ក្នុងការរៀបចំយុទ្ធសាស្ត្រខាងយេនឌ័រ ដើម្បីជួយដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៦-១០ ។

វបសអ បានយល់ព្រមតាមការអញ្ជើញឱ្យចូលជាសមាជិកនៃបណ្តាញអភិវឌ្ឍន៍អាស៊ីបូព៌ា ដែលជាបណ្តាញក្នុងតំបន់នៃបណ្តាញអភិវឌ្ឍន៍សាកលរបស់ធនាគារពិភពលោក។ សមាជិកភាពនេះ ផ្តល់ឱកាសបន្ថែមឱ្យ វបសអ ដើម្បីចងបណ្តាញជាមួយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយនៅអាស៊ីបូព៌ា និងធ្វើការសហប្រតិបត្តិការស្រាវជ្រាវ ។ វាជួយបំពេញបន្ថែមការចូលរួមរបស់ វបសអ នៅក្នុងបណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ដែលសំរបសំរួលដោយ វបសអ និងបានទទួលជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពី Rockefeller Foundation ព្រមទាំងនៅក្នុង ARTNeT ដែលជាបណ្តាញបណ្តុះបណ្តាល និងស្រាវជ្រាវនៅអាស៊ីប៉ាស៊ីហ្វិក ស្តីពីពាណិជ្ជកម្មដឹកនាំដោយ UNESCAP និងបានទទួលជំនួយឧបត្ថម្ភពីមជ្ឈមណ្ឌលធនធានសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (IDRC) របស់កាណាដា ។

## ផ្នែកស្រាវជ្រាវ

នៅថ្ងៃ ២២ មិថុនា វបសអ និងវិទ្យាស្ថានសិក្សាពីការអភិវឌ្ឍន៍ (IDS) នៅសាកលវិទ្យាល័យ Sussex បានរៀបចំកិច្ចពិភាក្សាតុមូលជាមួយ វបសអ ក្នុងឱកាសខួបអនុស្សាវរីយ៍ទី៤០ របស់ IDS ។ ប្រធានបទនៃកិច្ចពិភាក្សា គឺ "ការរីកចំរើនឱកាសការងារ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាៈ បញ្ហាប្រឈមរយៈពេលខ្លីនិងមធ្យម និងផលប៉ះពាល់នៃការស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍" ។ កិច្ចពិភាក្សា ត្រូវបានសហការសំរបសំរួលដោយលោក Larry Strange ជានាយកប្រតិបត្តិនៃ វបសអ និងសាស្ត្រាចារ្យ

*តទៅទំព័រទី ២៣*


**ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា**

*ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១០ លេខ៣ ខែកក្កដា-កញ្ញា ឆ្នាំ២០០៦



**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

(៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh

website: http://www.cdri.org.kh



*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដងមួយឆ្នាំជាភាសាខ្មែរ និងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពល ដល់ប្រទេសកម្ពុជា ។ *អត្ថបទតាមដានសេដ្ឋកិច្ច* ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះបីជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

គ្រឹះស្ថានផ្សាយៈ វបសអ

គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិរិទ្ធ

កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា

ជំនួយការកែសំរួលៈ យេន សុផានី និង គីម ចិត្រា

រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព CDRI



រក្សាសិទ្ធិ ២០០៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។


ISBN 978-99950-52-05-8 / ISSN 1560-7607


ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។